ក្រសួងអប់រំ យុវជន និង កីឡា

# ១៥ ឯកសារណែនាំ

# បញ្ឈប់ពលកម្មកុមារ

## ការពារសិទ្ធិកុមារតាមរយៈការអប់រំ_សិល្បៈ និងប្រព័ន្ធផ្សព្វផ្សាយ

នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

អង្គការពលកម្មអន្តរជាតិ

២០០៧

# អារម្ភកថា

ពលកម្មកុមារ គឺជាការកេងប្រវ័ញ្ចលើជនដែលងាយរងគ្រោះបំផុតនៅក្នុងសង្គមជាពិសេសកុមារ។ មានកុមារ ២៤៦ លាននាក់អាយុក្រោម ១៨ ឆ្នាំបានធ្វើការងារប្រចាំថ្ងៃនៅជុំវិញពិភពលោក។ ហើយស្ទើរតែ $\frac{2}{3}$ នៃកុមារទាំងនេះស្មើរ ១៨០ លាននាក់ ស្ថិតនៅក្នុងស្ថានភាពគំរាមកំហែងដល់អាយុជីវិត និងគ្រោះថ្នាក់បំផុត។ កុមារជាច្រើនពុំទទួលបានការអប់រំ និងទទួលរងនូវការឈឺចាប់ពីការធ្វើបាបលើរាងកាយ ការជួញដូរផ្លូវភេទ និងអារម្មណ៍ ហើយកុមារខ្លះត្រូវពិការអវៈយវៈ ឬក៏ស្លាប់មុនពួកគេពេញវ័យដែលទាំងនេះគឺជាលទ្ធផលផ្ទាល់ពីការធ្វើពលកម្មរបស់ពួកគេ។ ក្មេងខ្លះទៀត និងត្រូវទទួលរងនូវការភ័យរន្ធត់អស់មួយជីវិត។

ពលកម្មកុមារគឺជាបាតុភូតមួយដែលត្រូវគេមើលរំលង ដោយសារតែកុមារធ្វើការនៅក្នុងការងារដែលលាក់កំបាំងដូចជាការធ្វើការងារផ្ទះ និងការធ្វើបេស្យាចារ ឬការងារកំបាំងផ្សេងៗទៀត ហើយទាំងនេះក៏ដោយសារតែសង្គមមានបំណងបិទភ្នែកហើយមើលរំលង។

តាមរយៈកម្មវិធីអន្តរជាតិ ស្តីពីការបំបាត់ពលកម្មកុមារ (IPEC) នោះអង្គការពលកម្មអន្តរជាតិបានកំពុងតម្រង់ទិសដៅលើកិច្ចប្រឹងប្រែងជាសកល ដើម្បីធ្វើឱ្យពលកម្មកុមារក្លាយជារឿងមួយស្ថិតជាអាទិភាព។ ដោយសារតែមូលហេតុ ឫសគល់នៃពលកម្មកុមារ គឺមានច្រើនបែបច្រើនយ៉ាង និងស្មុគ្រស្មាញផងនោះ យើងទាំងអស់គ្នា ត្រូវដោះស្រាយបញ្ហានេះតាមរយៈការធ្វើសច្ចាប័ន និងការអនុវត្តនូវសិទ្ធិសញ្ញាជាអន្តរជាតិនានា និងកម្មវិធីជាក់ស្តែងនៅមូលដ្ឋាន ព្រមទាំងធ្វើការគៀងគរនូវផ្នែកសំខាន់ៗរបស់សង្គមផងដែរ។

ជាពិសេសមនុស្សដែលមានវ័យក្មេងមានតួនាទីយ៉ាងសំខាន់ ក្នុងការបំផុសការយល់ដឹងបញ្ហានានានៃយុត្តិធម៌សង្គម និងការបញ្ជ្រាបឥទ្ធិពលរបស់ពួកគេចូលទៅក្នុងសហគមន៍ ដើម្បីនាំឱ្យមានការផ្លាស់ប្តូរសង្គម។ កុមារ មនុស្សជំទង់ និងមនុស្សវ័យក្មេងបានធ្វើឱ្យមានសមាមាត្រដ៏សំខាន់មួយនៃអត្រាប្រជាជនរបស់ពិភពលោកតែពួកគេមានសម្លេងតិចតួចណាស់ ក្នុងការបញ្ចេញមតិលើការងារនេះ។ មុនពេលដែលពួកគេក្លាយជាមនុស្សពេញវ័យនោះ ពួកយើងបានបំពាក់បំប៉នយ៉ាងរឹងមាំដល់ពួកគេនូវរបៀបនៃការគិត ការមើលឃើញ និងការធ្វើការងារដែលជាក្តីរំពឹងទុកដ៏មានតម្លៃដែលពួកគេ។ ការផ្តល់អំណាចដល់មនុស្សវ័យក្មេង ការផ្តល់ឱ្យពួកគេនូវទំនួលខុសត្រូវ និងការទទួលស្គាល់នូវតម្លៃនៃការចូលរួមចំណែករបស់ពួកគេ នោះយើងសង្ឃឹមថាសកម្មភាពនានាប្រកបដោយផ្លែផ្កា និងការតាំងចិត្តដែលពួកគេត្រូវធ្វើដូចជាយុទ្ធនាការដើម្បីលុបបំបាត់ពលកម្មកុមារជាដើម។

ដោយស្មារតីយល់ឃើញដូចខាងលើនេះហើយ ទើប IPEC បានចាប់ផ្តើមនូវជំហានថ្មីមួយលើការគៀងគរសង្គម និងការអប់រំបែបថ្មីមួយ "សម្រែកបញ្ឈប់ពលកម្មកុមារ" ដើម្បីជួយដល់អ្នកផ្តល់ការអប់រំនៅ

ទូទាំងពិភពលោក ដោយលើកកម្ពស់ការយល់ដឹង និងបំផុសការយល់ដឹងពីពលកម្មកុមារដល់ស្រទាប់មនុស្សវ័យក្មេង និងសមាគមន៍របស់ពួកគេ។ ស្ក្រីម គឺជាពាក្យបំពេញនៃឃ្លា " ការគាំទ្រសិទ្ធិកុមារតាមរយៈការអប់រំសិល្បៈ និងការផ្សព្វផ្សាយតាមប្រព័ន្ធឃោសនា" ហើយវាក៏ឆ្លុះបញ្ចាំងផងដែរនូវការឈឺចាប់ដែលគ្មានគេដឹងពូនៃការធ្វើការរបស់កុមារនិងតម្រូវការចាំបាច់ដែលត្រូវផ្តល់ឱ្យពួកគេនូវសម្លេងមួយ។ តាមរយៈវិធីសាស្ត្រនៃការបង្រៀនដែលមានលក្ខណៈច្នៃប្រឌិតទាំងនេះ កម្មវិធីស្ក្រីមមានគោលបំណងផ្តល់ជាដំណឹងដល់មនុស្សវ័យក្មេងនូវពិភពលោកមួយ ដែលពួកគេរស់នៅនិងភាពអយុត្តិធម៌ដែលកំពុងតែកើតមានដោយផ្តោតលើពលកម្មកុមារ ដើម្បីឱ្យមនុស្សវ័យក្មេងទាំងនេះអាចបញ្ចេញមតិតាំងនាមឱ្យកុមារពលកម្មនៅគ្រប់ទីកន្លែងទាំងអស់។ វាគឺជាការអម្រែកទំនួលខុសត្រូវនៅលើស្មាមនុស្សវ័យក្មេងទាំងនេះ និងការជួយជ្រោមជ្រែងពួកគេក្នុងការបង្កើតនូវការឆ្លើយតបដ៏សមរម្យនានា។

សម្រែកស្ក្រីមគឺត្រូវបានរៀបចំឡើងភាគច្រើនជាគំរូដែលមានលក្ខណៈជាសិល្បៈសម្តែង និងបង្ហាញភាពជាក់ស្តែង។ ល្ខោនរឿងគឺជាឧបករណ៍ដ៏មានឥទ្ធិពល និងសំខាន់ជាពិសេសសម្រាប់បញ្ជ្រាបដល់មនុស្សពេញវ័យ។ ល្ខោនត្រូវបាននិយាយជាភាសាសកលមួយដែលបញ្ជូនចេញពីរនាំងវប្បធម៌ និងភូមិសាស្ត្រ ហើយល្ខោនត្រូវបានគេប្រើតាំងពីយូរយា មកហើយក្នុងប្រវត្តិសាស្ត្រជាយន្តការមួយសម្រាប់ការផ្តល់យោបល់ដល់សង្គម។ ហេតុដូចនេះហើយកម្មវិធីនេះបានធ្វើ ការលើកកម្ពស់លើការងារសិល្បៈ ដើម្បីជាយានួសម្រាប់មនុស្សវ័យក្មេងស្វែងរកនូវអារម្មណ៍របស់ពួកគេ និងការយល់ឃើញ និងដើម្បីឱ្យពួកគេបញ្ជូនសារនេះទៅកាន់សហគមន៍។ ការយល់ពីភាពពិតនៃការធ្វើការដ៏គួឱ្យរន្ធត់របស់កុមារ គេចាំបាច់ត្រូវតែមានមូលដ្ឋានយល់ដឹងពីគោលការណ៍ជាមនុស្ស ដោយការជួយជ្រោមជ្រែង និងការណែនាំមនុស្សវ័យក្មេង ហើយពួកគេអាចទទួលបានចំណេះ និងជំនាញ ហើយគេអាចរៀបចំល្ខោនសម្តែងបានដោយតម្រូវវទៅនិងវប្បធម៌ និង សង្គមជាភាសាផ្ទាល់ខ្លួនរបស់ពួកគេ។

ដៃគូជាច្រើនរបស់យើងបានផ្តល់ក្តីសង្ឃឹមដល់យើងថា ស្ក្រីម នឹងត្រូវបានផ្សព្វផ្សាយទូទាំងពិភពលោក។

ក្នុងនាមកុមាររាប់លាននាក់ដែលត្រូវបានគេកំពុងតែជួញដូរពលកម្មនោះ យើងសូមឱ្យបណ្តារដ្ឋទាំងឡាយដែលជាសមាជិកគ្រឹះស្ថានអប់រំទាំងអស់ អង្គការគ្រូបង្រៀន និយោជក កម្មករ អង្គការក្រៅរដ្ឋាភិបាល សហគមន៍គ្រូបង្រៀន បុគ្គលិកគ្រប់រូបដែលធ្វើការពាក់ព័ន្ធនិងមនុស្សវ័យក្មេងនេះ សូមមេត្តាប្រើប្រាស់ស្ក្រីមដើម្បីនិងជួយធ្វើឱ្យមនុស្សវ័យក្មេងៗទាំងនោះយល់ដឹងកាន់តែប្រសើរ និងខ្លាំងខ្លា។

នាយកខាងផ្នែកផ្សព្វផ្សាយ និងកសាង

គោលនយោបាយសម្រាប់ IPEC

# សេចក្តីថ្លែងអំណរគុណ

កម្មវិធីអន្តរជាតិ ស្តីពីការលុបបំបាត់ពលកម្មកុមារ IPEC ត្រូវបានបង្កើតឡើងក្នុងដើមឆ្នាំ ១៩៩០ ជាផ្នែកមួយនៃកិច្ចប្រឹងប្រែងជាសកលរបស់អង្គការពលកម្មអន្តរជាតិ ILO ដើម្បីប្រយុទ្ធប្រឆាំងនៃការជួញដូរពលកម្មកុមារ។ មានភាពរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងកិច្ចប្រឹងប្រែងលុបបំបាត់ពលកម្មកុមារ តែទុកជាយ៉ាងណាក៏ដោយ វានៅតែបញ្ហាមួយជាសកលនៅឡើយ ទុកជាមានការតាំងចិត្តកើនឡើងក្នុងជួររដ្ឋាភិបាលនានា និងដៃគូនានាក៏ដោយ។ ការលុបបំបាត់ពលកម្មកុមារអាចធ្វើទៅបាន លុះត្រាការដាក់អាទិភាពជាបន្ទាន់មួយក្នុងសកម្មភាពសហប្រតិបត្តិការអន្តរជាតិ ផ្សារភ្ជាប់ទៅនឹងការកាត់បន្ថយភាពក្រីក្រ និងបញ្ជ្រាបចូលទៅក្នុងកម្មវិធីនានារបស់មូលនិធិថវិកាអន្តរជាតិ IMF ធនាគារពិភពលោក ស្ថាប័ននានារបស់អង្គការសហប្រជាជាតិ និងម្ចាស់ជំនួយជា ឧបតោភាគី និងចម្រុះ។ ស្ថិតក្នុងក្របខ័ណ្ឌបែបនេះ ការតាំងចិត្ត និងភាពម្ចាស់ការជាលក្ខណៈជាតិមួយៗគឺជាដៃគូរដ៏សំខាន់ឆ្ពោះទៅរកភាពជាមេដឹកនាំ និងការផ្តល់មូនិធិជាអន្តរជាតិ។ ភាពជាម្ចាស់ការជាលក្ខណៈជាតិមួយៗ និងជួយឱ្យប្រទេសនិមួយៗបង្កើតនូវកម្មវិធីដែលមានពេលកំណត់ TBP របស់ខ្លួនដោយការធ្វើឱ្យក្លាយជាសកម្មភាពគត់ម៉ត់ស្របទៅតាមច្បាប់ និងការប្តេជ្ញាចិត្ត។

IPEC ឥឡូវនេះកំពុងប្រតិបត្តិការលើ ៧៥ ប្រទេសទូទាំងពិភពលោក ប៉ុន្តែគេត្រូវការប្រតិបត្តិការចាំបាច់បន្ថែមទៀតជាពិសេសផ្នែកការតស៊ូមតិ ដែលតាមរយៈនេះ យើងនឹងបង្កើននូវការយល់ដឹងច្រើនឡើងៗលើបញ្ហាពលកម្មកុមារនៅក្នុងចំណោមសហគមន៍នានា។ តាមរយៈដំណើរការនៃស្គ្រីម មនុស្សវ័យក្មេង និងបណ្តុះនូវគំនិតប្រកបដោយសីលធម៌ដ៏រឹងមាំមួយដោយស្គាល់ពីការកេងប្រវ័ញ្ចនានាមកលើខ្លួនគេផ្ទាល់ និងមិត្តៗដែលមានអាយុស្របាលពួកគេក្នុងបណ្តាប្រទេសផ្សេងៗទៀត។ គេចាំបាច់ត្រូវផ្តល់តួនាទីដ៏មានខ្លឹមសារនានាក្នុងគ្រប់ទម្រង់ទាំងអស់ក្នុងការធ្វើសេចក្តីសម្រេចចិត្តលើគោលនយោបាយដល់មនុស្សវ័យក្មេង។ ការធ្វើដូចនេះនឹងជួយ ពួកគេឱ្យបំពេញនូវសក្តានុពលភាពរបស់ពួកគេ ដើម្បីឱ្យក្លាយជាអ្នកចូលរួមផ្សព្វផ្សាយក្នុងយុទ្ធនាការជាសកលប្រកបដោយប្រសិទ្ធភាព ដើម្បីលុបបំបាត់ពលកម្មកុមារ។ លើសពីនេះទៅទៀត និងជួយពួកគេឱ្យក្លាយជាភ្នាក់ងារសម្រាប់ការផ្លាស់ប្តូរសង្គមស្ថិតនៅក្នុងសហគមន៍ផ្ទាល់ខ្លួនរបស់ពួកគេរស់នៅ។ ភាពរីកចម្រើនក្នុងការពាក់ព័ន្ធ និងការធ្វើសមាហរណកម្មរបស់ពួកគេនៅក្នុងយុទ្ធនាការ គឺជាវត្ថុចំបងគន្លឹះសម្រាប់ស្គ្រីម។

យុទ្ធនាការជាសកលដើម្បីលើកកម្ពស់ការយល់ដឹងពីពលកម្មកុមារ ដែលឧបត្ថម្ភដោយរដ្ឋាភិបាលអ៊ីតាលីនោះ ក៏បានលើកកម្ពស់ផងដែរនូវស្គ្រីម និងផ្តោតលើចំនុចសំខាន់ៗចំនួន ៣ គឺការកសាងទំនាក់ទំនងឱ្យសកម្មជាងមុន ប្រព័ន្ធផ្សព្វផ្សាយជាតិ និងមូលដ្ឋានការផ្តល់អំណាចដល់យុវជន និងការលើកកំពស់និងគាំទ្រដល់យុវជនឱ្យចូលរួមនៅក្នុងយុទ្ធនាការ និងការពង្រឹងសហប្រតិបត្តិការសមាហរណកម្មផ្នែកទាំងបីនេះគឺមានការ

ពាក់ព័ន្ធ និងជួយជ្រោមជ្រែងគ្នាទៅវិញទៅមក។ បើសិនផ្នែកនីមួយៗនៅដាច់តែឯងនោះ គឺផ្នែកនីមួយៗមានតួនាទី សំខាន់ស្មើគ្នាក្នុងការជម្រុញឱ្យយុទ្ធនាការលុបបំបាត់ពលកម្មកុមារមានដំណើរការទៅមុខ។ ការរួមគ្នានៃផ្នែកទាំងបីវានឹងបង្កើតនូវកម្លាំងផ្លាស់ប្តូរដ៏មានអនុភាព និងប្រសិទ្ធភាព សកម្មភាពច្របាច់បញ្ចូលគ្នានៃផ្នែកទាំងនេះគឺមានគោលបំណងបង្កើតឱ្យមាននូវការផ្លាស់ប្តូរតវិយាបថជាក់ស្តែង ដោយរួមទាំងការចូលរួមយ៉ាងសកម្មរបស់កម្មករ និយោជក អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នអប់រំ ព្រមទាំងស្វែងរកនូវគន្លឹះដើម្បីសម្រេចឱ្យបានលទ្ធផល ប្រកបដោយនិរន្តរភាពតាមរយៈភាពជាមេដឹកនាំខាងការទូត និងនយោបាយ។ បទពិសោធន៍សាកល្បងជាច្រើន នៅក្នុងបណ្តាប្រទេសមួយចំនួនបានអះអាងថាស្រ្តីម គឺជាកត្តាលីករមួយប្រកបដោយសក្តានុពល ដើម្បីបង្កើតនូវការច្របាច់បញ្ចូលគ្នាចម្រុះក្នុងចំណោមសមភាគទាំងអស់។

យើងសូមថ្លែងអំណរគុណដល់ប្រពន្ធ័ផ្សព្វផ្សាយស្ថាបន័អប់រំរួមទាំងស្ថាបន័អប់រំគំនិតឧត្តមសិក្សា និងវិទ្យាស្ថានស្រាវជ្រាវនានា ដែលបានឆ្លើយតបជាវិជ្ជមាន ចំពោះការអញ្ជើញឱ្យចូលរួមចំណែកជួយដល់ IPEC ហើយពួកយើងសង្ឃឹមថាក្រោមការជួយឧបត្ថម្ភរបស់ពួកគេ យើងនិងបន្តិតចំណងបន្ថែមទៀតជាមួយពួកគេ។ កម្មវិធីស្រ្តីមផ្តល់នូវផ្នែកសហប្រត្តិបត្តិការថ្មីដែលមានការពាក់ពន្ធ័គ្នាសម្ភាពនានាដែលដូចជា ការបណ្តុះបណ្តាលគ្រូ សិទ្ធិមនុស្ស ការអភិវឌ្ឍន៍ សិក្សាសង្គម និង នរវិទ្យា ការទំនាក់ទំនង និងប្រពន្ធ័ផ្សព្វផ្សាយ ។ IPEC និងទទួលបានការសិក្សាស្រាវជ្រាវនានា និងការពាក់ពន្ធ័ក្នុងការលើកកម្ពស់ និងការអនុវត្តន៍ស្រ្តីមក៏ប៉ុន្តែសកម្មភាពនៃការទទួលរង្វាន់ល្អិកណាអារម្មណ៏ថ្មីនិងគំនិតថ្មីនិងត្រូវបើកចំហដល់សិស្សនិងអ្នកអប់រំដូចគ្នា។

យុទ្ធនាការបើកឱ្យទទួលស្គាល់ផងដែរ ថាប្រពន្ធ័ផ្សព្វផ្សាយថ្នាក់មូលដ្ឋានថ្នាក់ជាតិ ថ្នាក់តំបន់ និងជាលក្ខណៈអន្តរជាតិបានដើរតួនាទីដ៏សំខាន់ក្នុងការលើកកំពស់នូវការយល់ដឹងពីពលកម្មកុមារនៅក្នុងសង្គម។ ជាការចាំបាច់ណាស់ក្នុងប្រទេសមួយ គេត្រូវផ្សព្វផ្សាយព័ត៍មានដែលត្រឹមត្រូវពាក់ពន្ធ័នឹងពលកម្មកុមារក្នុងរបៀបមួយដែលប្រសិទ្ធិភាពនិងដែលមានភាពងាយស្រួលក្នុងការទទួលព័តិមានដូចជាតាមរយៈទូរទស្សន៍ វិទ្យុ និងសារព័តិមាន។ សិក្ខាសាលាបណ្តុះបណ្តាលខាងផ្នែកប្រព័ន្ធផ្សព្វផ្សាយថ្នាក់តំបន់ត្រូវបានធ្វើជាបន្តបន្ទាប់ ហើយដែលការធ្វើនេះបានផ្តល់ជាលទ្ធិផលជាបញ្ជីអ្នកយកព័តិមានមួយ ដែលពួកគេមានឆន្ទៈដាស់សតិចំណាប់អារម្មណ៏របស់មហាជនក្នុងប្រភេទនៃការកេងប្រវ័ញ្ច និងផលប៉ះពាល់ដ៏ធ្ងន់ធ្ងរនៃពលកម្មកុមារ។

សូមអរគុណចំពោះការគាំទ្រ និងការតាំងចិត្តរបស់បុគ្គលនិង ក្រុមការងារដែលបានធ្វើ ស្រ្តីម មានដំណើរការ។ ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់រដ្ឋាភិបាលអ៊ីតាលីដែលបានធ្វើ ស្រ្តីម ដំណើរការ និងសូមអគុណផងដែរចំពោះលោក Nick Grise Grise Wood ដែលបានពង្រាងកម្មវិធីសិក្សានេះ និងបានសម្របសម្រួលក្នុងដំណាក់កាលសាកល្បង ដែលលោកបូជានូវកម្លាំងស្មារតីនិងការតាំងចិត្តធ្វើឱ្យស្រ្តីមទទួលបានជោគជ័យ។ ខ្ញុំសូមអគុណជាពិសេសចំពោះលោកស្រី Alice Ouédraogo ជានាយកកម្មវិធី IPEC ផ្នែកផ្សព្វផ្សាយ និងកសាង

គោលនយោបាយដែលបានផ្ដល់ការគាំទ្រដ៏ថ្លៃថ្លាសម្រាប់កម្មវិធីទាំងមូល និងសូមថ្លែងអំណរគុណផងដែរចំពោះលោក Geir Myrstad ជាមន្ត្រីកម្មវិធីជាន់ខ្ពស់របស់ IPEC សម្រាប់ការគាំទ្រ និងផ្ដល់យោបល់។ លោកស្រី Christina Jackson Grisewood បានផ្ដល់នូវគំនិតនានា និងជំនាញ ហើយបានធ្វើការពិនិត្យផ្ទៀងផ្ទាត់ ដើម្បីឱ្យកម្មវិធីសិក្សាមានប្រសើរឡើង។ លើសពីនេះទៅទៀត ខ្ញុំសូមអរគុណចំពោះលោកស្រី Marthe Reintte ដែលបានជួយពួកយើងធ្វើការប្រកបដោយភាពរីករាយក្នុងរយៈពេលវែង ដោយភាពក្រមិច ក្រមើមរបស់គាត់ និងលោកស្រី Laura Addali ដែលបានប្រឹងប្រែងជួយក្នុងដំណាក់កាលដំបូងនៃ ស្ក្រឹម និង បន្តជួយពួកយើងក្នុងការរៀបចំកម្មវិធីនៅ(ប្រទេសអ៊ែលសាវ៉ាឌ័រ)។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់សហការីទាំងអស់ក្នុង កម្មវិធី IPEC Geneera ដែលគាំទ្រ និងជម្រុញឱ្យមានការបង្កើតឡើងនូវ ស្ក្រឹម ជាពិសេសគឺលោកស្រី Arteta និង Sule Caglar ។

ស្ក្រឹម គឺនិយាយពីការផ្ដល់អំណាចដល់មនុស្សវ័យក្មេង ហើយក្នុងស្មារតីនេះវាត្រូវបានបង្កើតឡើងដោយមនុស្សវ័យក្មេងសម្រាប់មនុស្សវ័យក្មេង។ ក្នុងន័យនេះ ខ្ញុំសូមសម្ដែងនូវអំណរគុណចំពោះមនុស្សវ័យក្មេង និង ធនធានមនុស្សនានាដែលបានជួយជ្រោមជ្រែង IPEC នៅក្នុងដំណាក់កាលសាកល្បងកម្មវិធីនេះ នៅក្នុងសាធារណៈរដ្ឋអៀរឡង់ និងនេប៉ាល់ដែលរួមមាន :

- និស្សិត នាយកសាលា បុគ្គលបង្រៀនរបស់វិទ្យាល័យសហគមន៍ Scrift នៃខេត្ត Clare ប្រទេសអៀរឡង់ក្នុងរវាងឆ្នាំ ២០០០/២០០១។
- លោកស្រី Anne Jones បានចូលរួមយ៉ាងសកម្មគ្រប់សកម្មភាពទាំងអស់នៅក្នុងប្រទេសអៀរឡង់ និងលោក Ray Gonway សម្រាប់ការងារផលិតខ្សែវីដេអូ ស្ដីពីគរុកោសល្យក្នុងការប្រើវីដេអូ ស្ក្រឹម ក្នុងការបង្រៀន។
- លោកស្រី Larry Oloughlin និងលោកស្រី Denize Moroney សម្រាប់ការចូលរួមចំណែកមិនអាចកាត់ថ្លៃបានក្នុងគម្រោងនៃប្រទេសអៀឡង់។
- ក្រុមយុវជនក្មេង និងធនធានមនុស្សមកពីកុមារពលកម្មនៅក្នុងអង្គការ Nepal Concerned Centher ក្នុងទីក្រុង Kathmandu ប្រទេសនេប៉ាល់។
- ក្រុមសិស្សសាលា នាយក និងនាយករងសាលា និងបុគ្គលិកបង្រៀនរបស់សាលា Shuvatara ក្នុងក្រុង Kathmandu ។
- លោក Sunil pokharel និងលោកស្រី Hazel Ray សម្រាប់ការងារដ៏សំខាន់របស់ពួកគេនៃគម្រោងក្នុងប្រទេសនេប៉ាល់។

- លោក Khisha shreha Neppaleya និងសហការីថតកុនរបស់លោកសម្រាប់ការងារ វីដេអូនៅក្នុងប្រទេសនេប៉ាល់ ។

ដំណាក់កាលសាកល្បងនៅក្នុងប្រទេសនេប៉ាល់ត្រូវបានអនុវត្តដោយប្រឈមមុខ និងឧបសគ្គធ្ងន់ធ្ងរមួយចំនួនដោយសារតែស្ថានភាពនយោបាយ ។ ហើយខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះលោកស្រី Leyla Tegmo Reddy លោកស្រី Aditee Maskey លោក Bimal Rawal លោក Casper Edmonds និងបុគ្គលិករបស់ការិយាល័យ ILO នៅក្នុង Kathmandu ចំពោះភាពតស៊ូជំនះនូវឧបសគ្គទាំងនេះ ។

ស្គ្រីម បានធ្វើឱ្យមានការកត់សម្គាល់មួយនៅ មជ្ឈឹមបូព៌ា ជាពិសេសនៅក្នុងប្រទេស Jordon ។ ខ្ញុំសូមឆ្លៀតឱកាសនេះថ្លែងអំណរគុណចំពោះក្រុមសិស្សសាលាគន្ធប្បដីនន្ទ (ត្រូវតាមច្បាប់សាសនា) ជាតិនៅក្នុង Amman ព្រមទាំងនាយកសាលារបស់ពួកគេគឺលោក Azmi Shahin លោក Muhir Al-hour សាស្ត្រាចារ្យ Ayman Massanat និងលោកស្រី Nihayat Dabdub សម្រាប់ការតាំងចិត្តរបស់ពួកគេចំពោះកម្មវិធី ។

ការពាក់ព័ន្ធរបស់មនុស្សវ័យក្មេងក៏ត្រូវបានបញ្ចូលផងដែរ ដើម្បីរៀបចំកញ្ចប់អប់រំ ស្គ្រីម នេះ ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះ លោកស្រី Valeria Marra ជានាយិកាមជ្ឈមណ្ឌលបណ្តុះបណ្តាលអន្តរជាតិរបស់ ILO ខាងផ្នែកផលិតកម្ម និង ការរៀបចំផ្សព្វផ្សាយ ដែលមានទីតាំងនៅទីក្រុង Turin នៃប្រទេសអ៊ីតាលីសម្រាប់ការងាររបស់គាត់ លើគម្រោងដែលមានការពាក់ព័ន្ធជាមួយសិស្សពូកែមួយចំនួនរបស់វិទ្យាស្ថានអឺរ៉ុបសម្រាប់ការរចនានៅក្នុង Turin ដើម្បីរៀបចំ ស្គ្រីម ។ ក្នុងន័យនេះខ្ញុំសូមថ្លែងអំណរគុណដ៏ស្មោះអស់ពីចិត្តចំពោះលោក ស្រី Irene Alasia លោកស្រី Melody Amerio លោកស្រី Boaghio និងលោកស្រី Marcella Torco ដែលពួកគេទាំងនេះបានផ្តល់ឱ្យពួកយើងនូវបង្អួចមួយចូលទៅក្នុងព្រលឹងនៃ ស្គ្រីម ។ ខ្ញុំក៏សូមអរគុណផងដែរ ចំពោះគ្រូបង្រៀនរបស់ពួកគេគឺ លោក Janusz Kantewski , Carsten Askeimer និងលោកស្រី Launa Raveru និងក្រុមការងារគម្រោងដែល មកពីមជ្ឈមណ្ឌលបណ្តុះបណ្តាល Turin ដែលរួមមានលោក Enzo Fortarezza (នាយកផ្នែកសិល្បៈ) លោកស្រី Denise Zoccola (អ្នកប្រតិបត្តិការបោះពុម្ពតាមម៉ាស៊ីនកុំព្យូទ័រ Desktop) និងលោកស្រី Michde Maclvre(ជំនួយការ) ។

១-ខ្ញុំសូមសម្តែងពាក្យពេចន៍ ពិសេស ដើម្បីជាការថ្លែងអំណរគុណចំពោះ កុមារទាំងឡាយនៃក្រុមភ្លេង Suzuki Orchestra របស់ Turim ព្រមទាំងនាយកក្រុមភ្លេង Antonio ដែលធ្វើការមិនចេះហត់ និង Lee Mosca ដែលបានចូលរួមវិភាគទានបរិច្ចាគនូវទេពកោសល្យផ្នែកតន្ត្រី ដែលគួរឱ្យកត់សម្គាល់របស់ខ្លួនក្នុងគោល បំណងលើកកម្ពស់ការយល់ដឹងអំពីពលកម្មកុមារ និងសិទ្ធិកុមារជាទូទៅ ។

២-ក៏សូមថ្លែងអំណរគុណជាពិសេសចំពោះលោក Didier Bregnagដែលធ្វើកិច្ចប្រឹងប្រែងមិនចេះនឿយហត់បង្កើតជាលទ្ធផលឱ្យមានបញ្ជីរូបថតរបស់ IPEC ដែលទាក់ទងទៅនឹង CD-ROM បំណកស្រាយអំពី ស្គ្រីម ដ៏ពិសេសមួយដែលត្រូវបញ្ចូលនៅក្នុងកញ្ចប់នៃការអប់រំ ស្គ្រីម ។

៣-បំនងប្រាថ្នាចង់បាននូវកញ្ចប់ផ្នែកអប់រំមួយចំនួន និងមេរៀនជាច្រើន បានមកពីការងាររបស់លោកគ្រូដែលមានជម្រើសលើកលែងពីររូបគឺ Michal Pasternak និងលោក Tim Williams ។ គំនិតរបស់ពួកគេសម្រាប់ពិធីល្ខោនអំពីពលកម្មកុមារនៅឆ្នាំ១៩៩៦ បាននាំមកនូវសហគមន៍មហោស្រពអន្តរជាតិ (ISTA)ឱ្យចូលរួមក្នុងកិច្ចព្រមព្រៀងជាមួយ IPEC ហើយបានជួយយើងឱ្យយល់ពីសក្តានុពលនៃរឿងល្ខោនក្នុងដំណើរការលើកកម្ពស់ការយល់ដឹង ។

៤-ដូចនេះបុគ្គល និងអង្គការជាច្រើនបានផ្តល់ពេលវេលាដោយឥតគិតកម្រៃ និងកម្លាំងកាយរបស់ខ្លួនដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍កម្មវិធី ស្រ្គីម ។

យើងសូមទទួលស្គាល់នូវកិច្ចប្រឹងប្រែងរបស់លោកអ្នក ។ ព្រោះតែលោកអ្នកទាំងអស់គ្នានេះហើយទើបបានជា ស្រ្គីមទទួលបាននូវជីវិតរស់នៅ និងទទួលបានស្លាបដើម្បីធ្វើការហោះហើរបាន ។

៥-ស្រ្គីមគឺជាទ្វារដែលជនវ័យក្មេងចាប់ផ្តើមចេញដំណើររបស់ខ្លួនឆ្លងកាត់ ឆ្ពោះទៅរកការយល់ដឹង ការស្គាល់ និងសកម្មភាព ។ មនុស្សដែលបង្ហាញទ្វារនោះដល់ពួកគេ ហើយបង្ហាញពីររបៀបបើកដល់ពួកគេគឺជារូបអ្នកនេះឯងដែលជាអ្នកអប់រំពិភពលោកនេះ ។ ទទួលយកវិធានការនោះ ហើយជួយយើងក្នុងគោលបំណងពង្រីកនូវពិភពលោក ដើម្បីច្បូតយកភាសាដែលកំបាំងហ៊ុំព័ទ្ធដោយសំបកដ៏ធំក្រាស់ ដែលគ្របដណ្តប់កុមារពលកម្មរបស់ពិភពលោក និងជួយដល់សង្គមដើម្បីធ្វើកន្ទើយចំពោះភាពមិនខុសគ្នាដល់ការឈឺចាប់របស់កុមារទាំងនេះ ។

ជាការបញ្ចប់គឺកុមារទាំងអស់នេះហើយដែលខ្ញុំគិតដល់ ។ ការឈឺចាប់ដ៏ស្ងាត់ស្ងៀមរបស់ពួកគេគឺស្ថិតនៅចំកណ្តាលបេះដូងនៃ ស្រ្គីម ហើយសូមអង្វរករដល់យើងទាំងអស់គ្នាឱ្យចាត់វិធានការឡើង ។

ហត្ថលេខា

Maria Gabrilla Lay
នាយកគំរោង
អង្គការពលកម្មអន្តរជាតិ

## ការថ្លែងអំណរគុណរបស់អ្នកនិពន្ធ

ការបោះពុម្ពផ្សាយជាច្រើន អត្ថបទកាសែត ឯកសារ និងអត្ថបទផ្សេងៗទៀតបានផ្តល់ពត៌មានមិនអាចកាត់ថ្លៃបាន សម្រាប់ធ្វើជាគំនិតកសាងសៀវភៅក្នុងកម្មវិធី ស្រ្គីម នេះ ។

ចំពោះរឿងនេះ អ្នកនិពន្ធសូមអរគុណជាពិសេសចំពោះស្ថាប័នជាច្រើនដូចតទៅ ILO/IPEC, UNICEF អប់រំអន្តរជាតិ IE អង្គភាពអភិវឌ្ឍន៍កម្មវិធី Mary Immaculate colleg Limerick Irlande ជំនួយគ្រឹះសាសនាសមាគមល្ខោន អន្តរជាតិ មហោស្រពល្ខោន ស្តីពីពលកម្មកុមារ ក្រុង Geneve ឆ្នាំ ១៩៩៦ ជាមធ្យោបាយសម្រាប់គ្រូ និងសិស្ស ។

នៅទីបញ្ចប់ ខ្ញុំសូមបង្ហាញមនុស្ស ២នាក់ដែលខំជួយយ៉ាងខ្លាំងក្នុងនិពន្ធសៀវភៅទាំងអស់នេះ គឺលោក Tim Williams ជាបុគ្គលិកសិក្សា និងជាទីប្រឹក្សាសិល្បៈល្ខោន អ្នកនិពន្ធដ៏ល្បីល្បាយផ្នែកខាងល្ខោន ។ លោកបាននិពន្ធ "សៀវភៅសម្តែងតួ " Role play និងសៀវភៅរឿង ។ លោក Larry O'Loughlin ជាអ្នកនិពន្ធថ្នាក់ពិភពលោក ជាបុគ្គលិកសិក្សា ។ ការងារសម្រេចបាននៅក្នុងប្រទេស Irland នាំឱ្យមានគំនិតបង្កើតអត្ថបទអក្សរសាស្រ្តឡើង ។

# សេចក្តីផ្តើម

ពលកម្មកុមារ ត្រូវបានចាត់ទុកថា គឺជាការបំពានមួយដ៏អាក្រក់បំផុតរបស់សិទ្ធិមនុស្ស។ វាធ្វើឱ្យកុមារបាត់បង់ភាពពេញលេញ និងការរីករាយរបស់ពួកគេ ពលកម្មនេះរារាំងកុមារមិនឱ្យចេញពីភាពក្រីក្រ និងការអស់សង្ឃឹមតកូនតចៅ។ ពលកម្មកុមារជាប្រភពនៃការឈឺចាប់រងទុក្ខផុតកំពូល។ វារាតត្បាតសង្កត់សង្កិនអ្នកទាំងឡាយណាដែលគ្មានលទ្ធភាពការពារខ្លួន។ វាធ្វើឱ្យរង្គោះរង្គើការកសាងមនុស្ស ដើម្បីអនាគតល្អលើភពផែនដីយើងនេះ។

ដោយសារកម្មវិធីអន្តរជាតិលុបបំបាត់ពលកម្មកុមារ IPEC និងដោយសារអង្គការផ្សេងៗដែលធ្វើការដើម្បីសម្រេចគោលដៅដូចគ្នានេះ កុមារមួយចំនួនត្រូវបានដកចេញពីកន្លែងពលកម្មរបស់ពួកគេ រួចត្រូវបានបញ្ជូនទៅសាលាឬទៅឱ្យឪពុកម្តាយរបស់គេ។ប៉ុន្តែនៅមានការងារធ្វើច្រើនទៀត គឺត្រូវផ្តាច់ឫសគល់នៃពលកម្មកុមារ។ យើងចាំបាច់ត្រូវផ្លាស់ប្តូរអាកប្បកិរិយា និងការយល់ដឹងរបស់កុមារ ឬអាកប្បកិរិយារបស់មនុស្សតែម្តង។ ដើម្បីសម្រេចគំនិតខាងលើនេះ យើងត្រូវតែផ្តល់អំណាចទៅឱ្យមនុស្សពិសេសយុវជន។ ដោយផ្អែកទៅលើគំនិតនេះ ហើយទើប IPEC បានផ្សព្វផ្សាយកម្មវិធី ស្ក្រីម បញ្ឈប់ពលកម្មកុមារ S= ឧបត្ថម្ភគាំទ្រ C= កុមារ R= សិទ្ធិតាមរយៈ E= អប់រំ A= សិល្បៈ និង M= ប្រព័ន្ធផ្សព្វផ្សាយ) ដូចច្នេះ ស្ក្រីម មានន័យថា "ឧបត្ថម្ភគាំទ្រសិទ្ធិកុមារតាមរយៈអប់រំសិល្បៈ និងប្រព័ន្ធផ្សព្វផ្សាយកម្មវិធី ស្ក្រីម មានគោលបំណងផ្តល់ចំណេះដឹង និងសមត្ថកិច្ចដល់យុវជន ដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរមុខមាត់សង្គម។ គំនិតមូលដ្ឋានរបស់ ស្ក្រីម គឺបង្កើតសៀវភៅអប់រំមួយឈុត ដើម្បីអប់រំយុវជនឱ្យចូលទៅយុទ្ធនាការពិភពលោកលុបបំបាត់ពលកម្មកុមារ។ គំនិតចម្បងគឺសម្របសម្រួលសៀវភៅឈុតទៅតាមបរិបទភូមិសាស្ត្រ និងវប្បធម៌តាមក្របខ័ណ្ឌផ្លូវការ ឬក្រៅផ្លូវការ។ សៀវភៅទាំងនេះមានគោលដៅជាពិសេសឆ្ពោះទៅរកយុវជន ពីព្រោះពួកគេនឹងក្លាយទៅជាមនុស្សចាស់ពេញវ័យដែលនៅពេលនោះពួកគេនឹងក្លាយទៅជាអ្នកទទួលខុសត្រូវ ហើយពួកគេនឹងមានឥទ្ធិពលទៅលើមនុស្សដទៃទៀតមិនត្រឹមតែអ្នកនៅជិតៗ ក៏ប៉ុន្តែទៅលើមនុស្សក្នុងពិភពលោកទាំងមូលទៀតផង។ ពួកគេស្ថិតនៅក្នុងដំណាក់កាលមួយនៃជីវិតដែលនៅពេលនោះពួកគេត្រូវការគំនិតសមស្របជាវិជ្ជមានប្រកបដោយន័យស្ថាបនា ព្រមទាំងកំហឹងឈឺចាប់ ជិតជាប់ក្នុងអារម្មណ៍របស់យុវជនប្រឆាំងនឹងពលកម្មកុមារ។

នៅពេលខាងមុខនេះ IPEC សង្ឃឹមថាកម្មវិធី ស្ក្រីម នឹងត្រូវបានប្រើប្រាស់នៅគ្រប់លំដាប់ថ្នាក់នៃការអប់រំនៅតាមសាលាក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ហើយត្រូវបានគេប្រើប្រាស់ពេញមួយជីវិតតែម្តង។

យើងសង្ឃឹមថាសៀវភៅអប់រំនេះ នឹងជួយយុវជនឱ្យយល់ដឹងអំពីការរស់នៅរបស់គេក្នុងសង្គមក្នុងបរិបទថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ។ ពួកគេត្រូវយល់ដឹងថាពួកគេជាជនរួមជាតិនៃពិភពលោក ដូច្នេះពួកគេត្រូវតែទទួលព័ត៌មានគ្រប់គ្រាន់ ស្តីពីសង្គមដែលពួកគេរស់នៅ ស្តីពីអំពើអយុត្តិធម៌ដែលចេះតែមានមិនដែលដាច់។ ពួកគេត្រូវការយល់ដឹងអត្ថន័យច្បាស់លាស់នៃពាក្យ ការទទួលខុសត្រូវ ការគោរព និងការប្តេជ្ញាចិត្ត។ ពួកគេត្រូវការស្គាល់តួនាទីរបស់គេក្នុងយុទ្ធនាការពិភពលោក ដើម្បីលុបបំបាត់ពលកម្មកុមារ។

## ទស្សនៈនៃកម្មវិធី ស្គ្រីម

សៀវភៅទាំងអស់នៃ កម្មវិធីនេះ ត្រូវគេប្រើប្រាស់ជាមួយសិល្បៈ ចក្ខុទស្សន៍ អក្សរសាស្ត្រ និង ល្ខោន ដោយផ្អែកលើវិធីសាស្ត្រយុទ្ធនាការ និងប្រព័ន្ធផ្សេងៗ។ គោលដៅគឺតម្រូវឱ្យលើកកម្ពស់សមាហរណកម្មនិងការអប់រំសហគមន៍ព្រមទាំងប្រគល់អំណាចទៅឱ្យយុវជនតួនាទីរបស់គេក្នុងឋានៈជាភ្នាក់ងារធ្វើឱ្យសង្គមមានការប្រែប្រួល។ នេះគឺជាកម្មវិធីប្រកបដោយបំណងយ៉ាងធំធេង ប៉ុន្តែបើយើងមិនមានបំណងធំធេងយ៉ាងនេះទេ យើងមិនធ្វើសកម្មភាពខ្លាំងក្លាដើម្បី បំបាត់ ឬកាត់បន្ថយពលកម្មកុមារដែលចេះតែរីកចម្រើនធំឡើងក្នុងពិភពលោកឡើយ។ ជាញឹកញាប់កុមារទាំងនេះធ្វើការក្នុងលក្ខខណ្ឌគួរភ័យខ្លាចប្រកបដោយគ្រោះថ្នាក់។ ក្នុងឆ្នាំ ២០០២ ILO បានផ្សព្វផ្សាយរបាយការណ៍មួយថ្មីមានចំណងជើងថា "អនាគតគ្មានពលកម្មកុមារ"។ កុមារជិត ១៨០ លាននាក់ ត្រូវបានគេធ្វើអាជីវកម្មក្នុងទម្រង់ការងារដ៏អាក្រក់សាហាវព្រៃផ្សៃ។ ដើម្បីឱ្យមានឥទ្ធិពល ឬផលប៉ះពាល់លើស្ថិតិដ៏ធ្ងន់ធ្ងរនេះ យើងត្រូវតែមានគ្នាច្រើន និងខ្លាំងក្នុងគោលដៅរបស់យើង ដោយយើងត្រូវតែបញ្ចូលមនុស្សទាំងនៅក្នុងគោលដៅពិសេសមនុស្សក្មេងៗ យុវជនដើរតួសំខាន់ណាស់ក្នុងយុទ្ធនាការពិភពលោកលុបបំបាត់ពលកម្មកុមារ។ ប៉ុន្តែជារឿងមិនល្អ កុមារត្រូវគេមិនចាប់អារម្មណ៍យកចិត្តទុកដាក់ថា ពួកគេគឺជាប្រភពកម្លាំងខ្លាំងសម្រាប់គំនិតអន្តរជាតិផ្សព្វផ្សាយក្នុងវិស័យនេះ។ ឥឡូវនេះពួកយើងទាំងអស់គ្នាត្រូវតែប្រមូលផ្តុំការខំប្រឹងប្រែង របស់យើងបង្វែរទៅរកពួកគេ។



គំនិតផ្តួចផ្តើមរបស់ IPEC គឺត្រូវមានលក្ខណៈពិភពលោក ហើយត្រូវមានអ្នកសម្តែងតួឱ្យច្រើននៅក្នុងពិភពលោកដែលមានប្រភពចេញពីសមាគមន៍ទូលំទូលាយ ។ មូលដ្ឋាននៃការរីកចម្រើនមានប្រភពចេញមកពីរចនាសម្ព័ន្ធ និងសកម្មភាពត្រីភាគីរបស់ ILO ។ ការនិយមត្រីភាគីនេះមានកំណើតចេញពីរបាយការណ៍ពិសេសរបស់ដៃគូរក្នុង ILO ដែលនៅក្នុងនោះ សហជីព និយោជក និងរដ្ឋាភិបាលចូលរួមតាក់តែង បទដ្ឋាន (norme) អន្តរជាតិសម្រាប់ការងារ និងការពារសិទ្ធិពលករក្នុងពិភពលោក ។ គំរូរបស់ IPEC លើកទឹកចិត្តដល់ការចូលរួមរបស់ភាគីសំខាន់ៗ ក្នុងរាល់សកម្មភាពអប់រំ ក្នុងនោះមានជាពិសេស អាជ្ញាធរមូលដ្ឋាន រដ្ឋាភិបាលចលនាសហជីព អង្គការ និយោជក អង្គការក្រៅរដ្ឋាភិបាល បុគ្គលិកសិក្សាក៏ដូចជាឪពុកម្តាយ និងគ្រួសារ ។ កុមារពលកម្មត្រូវតែទទួលផលចំណេញពីគំនិតផ្តួចផ្តើមនេះច្រើនជាងក្រុមផ្សេងទៀត ហើយការចូលរួមរបស់គេសំខាន់ខ្លាំងណាស់ ដើម្បីធ្វើឱ្យសម្រេចកម្មវិធី ស្ក្រីម នេះ ។



ការអប់រំតាមរយៈដៃគូ (ដូចជា យុវជនអប់រំយុវជន) គឺជាគោលបំណងផ្សេងទៀតរបស់សៀវភៅ ។ នេះគឺមធ្យោបាយដែលមានប្រសិទ្ធភាពជាងដែលយើងប្រាថ្នាឈានឱ្យទៅដល់ក្រុមយុវជន ហើយពន្យល់ឱ្យពួកគេយល់ថាពលកម្មកុមារ គឺជាការបំផ្លិចបំផ្លាញអមនុស្សធម៌ និងឱ្យយល់ថាពលកម្មកុមារត្រូវតែចប់ ។

ក្នុងដំណាក់កាលសាកល្បងក្នុងប្រទេស Irland យុវជនដែលបានចូលរួមក្នុងកម្មវិធី ស្ក្រីម បានអនុវត្តបានសម្រេចសៀវភៅមួយក្នុងចំណោមសៀវភៅទាំងឡាយ (សៀវភៅឈ្មោះផ្ទាំងផ្គុំរូបភាព Collage ) ជាមួយនឹងសិស្សចំណេះទូទៅនៃសាលាបឋមសិក្សានៅតាមមូលដ្ឋាន នៅពេលប្រើវិធីសាស្ត្រនេះ យើងអាចពន្យល់អំពីបញ្ហាដែលផ្តល់វិភាគទានដល់ពលកម្មកុមារ ។ តើវាមានប្រយោជន៍ដល់កិរិតណាទៅ រឿងដែលសង្គមទាំងមូលទទួលបន្ទុកលុបបំបាត់ពលកម្មកុមារ ហើយធានាឱ្យមានការគោរពសិទ្ធិកុមារ ។ ម្យ៉ាងទៀតវិធីសាស្ត្រអាចប្រមូលផ្តុំការគាំទ្រយ៉ាងសកម្មពីសំណាក់មិត្តភ័ក្ត្ររាប់ពាន់ រាប់ម៉ឺននាក់ ។ អ្នកទាំងនេះនឹងធានាបន្តការប្រយុទ្ធប្រឆាំងពលកម្មកុមារនៅថ្ងៃអនាគត ។

លក្ខណៈចម្បងនៃគំនិតរបស់ IPEC គឺធ្វើឱ្យ IPEC ត្រូវបានគេទទួលស្គាល់ពេញពិភពលោក ហើយយល់ដឹងច្បាស់អំពីចំនួនអ្នកចូលរួមមកពីសហគមន៍ដ៏ទូលំទូលាយ គំរូជាមូលដ្ឋាននៃដំណើរការនេះផុសចេញមកដោយផ្ទាល់ពីរចនាសម្ព័ន្ធ និងសកម្មភាពត្រីភាគីរបស់ ILO ។ សកម្មភាពត្រីភាគីនេះមានកំណើតចេញមកពីរបាយការណ៍ពិសេសរបស់ដៃគូនៃសង្គមក្នុងអង្គការ ILO ត្រីភាគីនោះគឺពលករទាំងឡាយ និយោជកទាំងឡាយ ហើយនិងរដ្ឋាភិបាលទាំងឡាយរួមគ្នាបង្កើតបទដ្ឋានពលកម្មអន្តរជាតិ និងការពារសិទ្ធិពលករក្នុងពិភពលោកទាំងមូល។ គំរូរបស់ IPEC ជំរុញឱ្យមានការចូលរួមពីភាគីសំខាន់ៗចូលទៅក្នុងគ្រប់ទិដ្ឋភាព និងសកម្មភាពអប់រំក្នុងនោះមានជាពិសេសអាជ្ញាធរមូលដ្ឋាន ចលនាសហជីព អង្គការនិយោជិក អង្គការក្រៅរដ្ឋាភិបាល អ្នកអប់រំក៏ដូចជាឪពុកម្ដាយ និងគ្រួសារផងដែរ។ កុមារពលកម្មទាំងឡាយទទួលផលចំណេញច្រើនពីគំនិតផ្តួចផ្តើមនេះជាងក្រុមកុមារផ្សេងទៀត ហើយការចូលរួមរបស់ពួកគេ គឺសំខាន់ខ្លាំងណាស់ ដើម្បីធ្វើឱ្យសម្រេចគោលបំណងរបស់កម្មវិធីស្ក្រឹម។



ការអប់រំធ្វើឡើងដោយមនុស្សមានអាយុប្រហាក់ប្រហែលគ្នា បានសេចក្តីថាយុវជនអប់រំយុវជន គឺជាគោលបំណងផ្សេងទៀតរបស់សៀវភៅទាំងនេះ។ នេះគឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពខ្លាំងជាងអ្វីដែលយើងប៉ងប្រាថ្នា ពោលគឺចង់ឈានទៅឱ្យដល់យុវជនទាំងឡាយ ហើយនិងពន្យល់ពួកគេឱ្យយល់ថាការងាររបស់កុមារ គឺជាការបំផ្លិចបំផ្លាញ ហើយអមនុស្សធម៌ ហើយពលកម្មកុមារនេះត្រូវតែលែងមានតទៅទៀត។ ឧទាហរណ៍ដូចជាក្នុងដំណាក់កាលសាកល្បងក្នុងប្រទេស Irland យុវជនដែលបានចូលរួមក្នុងកម្មវិធីស្ក្រឹម បានបង្ហាត់បង្រៀនសៀវភៅមួយដែលមានចំណងជើងថា "ផ្ទាំងផ្គុំរូបភាព" (Collage) ក្នុងចំណោមសៀវភៅទាំងឡាយដល់សិស្សបឋមសិក្សានៅតាមមូលដ្ឋាន។ នៅពេលប្រើវិធីសាស្ត្រនេះ យើងអាចពន្យល់ឱ្យយល់នូវបញ្ហាទាំងឡាយដែលចូលរួមវិភាគទានដល់ពលកម្មកុមារឱ្យយល់ថាសង្គមទាំងមូលទទួលការខុសត្រូវដល់វិបត្តិអំពីការលុបបំបាត់ពលកម្មកុមារ ហើយចង់ធានាចំពោះការគោរពសិទ្ធិកុមារ។ ម្យ៉ាងទៀតវិធីសាស្ត្រអាចភ្ជាប់របាយការណ៍សកម្មរបស់ជនរាប់ពាន់ រាប់ម៉ឺននាក់ដែលធានាការប្រយុទ្ធជាបន្តប្រឆាំងនឹងពលកម្មកុមារសម្រាប់ការជំនាន់ក្រោយ។

# ឈុតសៀវភៅអប់រំកម្មវិធី ស្គ្រីម

ការបោះពុម្ពដំបូងនៃម៉ូឌុលគរុកោសល្យ ស្គ្រីម មាន ៤ ក្បាល។ ម៉ូឌុល "ណែនាំអ្នកប្រើប្រាស់" នេះហើយនិង CD-ROM របស់ IPEC មានរូបភាពកុមាររាប់រយដែលត្រូវបានគេធ្វើអាជីវកម្មសេដ្ឋកិច្ចទម្រង់ផ្សេងៗពីគ្នា។ រូបភាពទាំងអស់នោះអាចយកទៅប្រើក្នុងសកម្មភាពខ្លះនៃកម្មវិធីស្គ្រីម ដូចជាម៉ូឌុល "រូបភាព" ជាដើម។ រូបភាពចម្លងបោះពុម្ព ដែលធ្វើឱ្យចាប់អារម្មណ៍ខ្លាំង ត្រូវបានដាក់បញ្ចូលក្នុងឈុតម៉ូឌុលគរុកោសល្យផងដែរ។

ត្រូវកត់សម្គាល់ថាថាស CD-ROM ពិសេសគំរូគរុកោសល្យរបស់ IPEC ត្រូវបានរក្សាផ្តាច់មុខសម្រាប់ឱ្យអ្នកអប់រំ ដែលអនុវត្តឱ្យមានដំណើរការនូវសៀវភៅទាំងឡាយនៃឈុតម៉ូឌុលគរុកោសល្យ ស្គ្រីម ។ ILO មិនអនុញ្ញាតឱ្យប្រើប្រាស់ម៉ូឌុលជំនួយស្មារតីនេះ សម្រាប់ការអនុវត្តន៍ផ្សេងទៀតក្រៅពីសកម្មភាព ស្គ្រីម ឡើយ។ ក្នុងករណីដែលអ្នកចង់ប្រើប្រាស់រូបភាព ដើម្បីសកម្មភាពផ្សេងពីសកម្មភាព ស្គ្រីម សូមមេត្តាទាក់ទង ផ្ទាល់ជាមួយនឹងអ្នកគ្រប់គ្រងរូបភាព របស់ ILO ដើម្បីផ្តល់ឱ្យអ្នកនូវលក្ខខណ្ឌដែលត្រូវថតចម្លងឡើងវិញ។ ដើម្បីដឹងអាស័យដ្ឋាន សូមមើល ជំពូក ស្តីពីការទាក់ទង (Contac) នៅក្រោម។

ម្យ៉ាងទៀតវីដេអូគរុកោសល្យដែលផ្អែកលើមូលដ្ឋានសាកល្បង២លើកធ្វើនៅ Irland និងនៅ Nepal នឹងត្រូវដាក់ជូនដល់ IPEC សម្រាប់ប្រើប្រាស់។

បញ្ជីឈ្មោះម៉ូឌុលមាន :



**១_ព័ត៌មានជាមូលដ្ឋាន** : ម៉ូឌុលនេះមានប្រធានបទមូលដ្ឋានស្តីពីពលកម្មកុមារ។ វាពន្យល់ដល់កុមារនូវភាពធំធេង និងភាពស្មុគស្មាញនៃបញ្ហាដោយរបៀបសាមញ្ញ ហើយការងាយយល់ ហើយវាផ្តល់ទៅឱ្យកុមារនូវស្ថិតិ ហេតុការ និងតួលេខសម្រាប់ប្រធានបទ។



**២_ផ្ទាំងផ្តុំរូបភាព** : ម៉ូឌុលនេះសម្រាប់ធ្វើឱ្យសម្រេចនូវផ្ទាំងផ្តុំរូបភាពពីរយ៉ាង : រូបភាពទី១ ស្តីពីពាណិជកម្មបែបបុរាណ រូបភាពទី២ ស្តីពីពលកម្មកុមារ។ ម៉ូឌុល "ផ្ទាំងផ្តុំរូបភាព" នេះជំរុញឱ្យផ្តោត អារម្មណ៍ខ្លាំងទៅលើទស្សនីយភាព និងសិល្បៈ ហើយមិនសូវបង្ហាញនូវសារៈសំខាន់នៃប្រព័ន្ធផ្សព្វផ្សាយសម្រាប់ពលកម្មកុមារឡើយ។

**៣-ការស្រាវជ្រាវ និងព័ត៌មាន** ៖ ម៉ូឌុលនេះធ្វើបន្ថែមព័ត៌មានស្តីពីពលកម្មកុមារដោយបញ្ចូលអនុសញ្ញាអន្តរជាតិសំខាន់ៗហើយ ម៉ូឌុលនេះបង្រៀនឱ្យចេះធ្វើការស្រាវជ្រាវស៊ីជម្រៅទៅលើប្រធានបទ។



**៤-សម្ភាសន៍ និងអង្កេត** ៖ ម៉ូឌុលនេះសម្រាប់បង្រៀនអំពីរបៀបដឹកនាំការធ្វើអង្កេតការសួរសំណួរដល់មនុស្សដែលពាក់ព័ន្ធនឹងពលកម្មកុមារ។ ម៉ូឌុលនេះបង្កលក្ខណៈងាយស្រួលដល់ការចូលរបស់សហគមន៍ និងទាញអារម្មណ៍សហគមន៍ឱ្យផ្តោតទៅលើបញ្ហាតែម្តង។ វាផ្តល់បច្ចេកទេសសួរក្នុងការសម្ភាសន៍ ហើយលើកទឹកចិត្តអ្នកស្រាវជ្រាវឱ្យចេះស្រាវជ្រាវក្នុងផ្នែកផ្សេងៗនៃសង្គម និងសេដ្ឋកិច្ច។



**៥-រូបភាពពលកម្មកុមារ** ៖ ម៉ូឌុលនេះសម្រាប់បង្ហាញរូបភាពកុមារពលកម្ម។ វាធ្វើឱ្យមានការចាប់អារម្មណ៍យល់ដឹងអំពីទុកដ៏ធ្ងន់ធ្ងររបស់កុមារ ។ វាធ្វើឱ្យមានការភ្ញាក់រលឹកទទួលខុសត្រូវចំពោះវាសនារបស់កុមារ និងឱ្យមានស្មារតី និងមធ្យោបាយកែលំអសង្គម។



**៦-ការសម្តែងតួ** ៖ ម៉ូឌុលនេះបង្ហាញតួនាទីកុមារពលកម្ម និងអ្នកពាក់ព័ន្ធ (ឪពុកម្តាយ និយោជក មន្ត្រី)។ វាសម្រាប់ឱ្យយុវជនមានភាពថ្មីកក្នុងការសម្តែងរឿងល្ខោនក្នុងក្របខ័ណ្ឌអប់រំ។ វាបង្រៀនយុវជនឱ្យហាត់សម្តែងល្ខោនតាមខ្លឹមសារតម្រូវឱ្យរហូតដល់ពេលយុវជនយល់ជ្រួតជ្រាបអំពីពលកម្មកុមារ។



**៧-ការប្រកួតសិល្បៈ** ៖ ម៉ូឌុលនេះសម្រាប់ឱ្យយុវជនចូលរួម ឬរៀបចំការប្រកួតសិល្បៈស្តីពីពលកម្មកុមារ។ វាលើកកម្ពស់ការសម្តែងសិល្បៈ ហើយពង្រឹងការចូលរួម និងចំណាប់អារម្មណ៍របស់សហគមន៍។



**៨-ការនិពន្ធរឿង** ៖ ម៉ូឌុលនេះសម្រាប់តាក់តែងរឿង ឬប្រវត្តិសាស្ត្រដោយប្រើខ្លឹមសារ ឬប្រធានបទសាមញ្ញ។ វាជម្រុញការសម្តែងតាមការសរសេរ និងបង្ហាញអារម្មណ៍ដែលផ្តោតខ្លាំងទៅបញ្ហាពលកម្មកុមារ។ វាពង្រីកផងដែរនូវសមត្ថភាពសរសេររឿង និងធ្វើការទំនាក់ទំនង។ វាពាក់ព័ន្ធជួយដល់ម៉ូឌុលផ្សេងទៀត ដូចជាម៉ូឌុលល្ខោននៅក្នុងម៉ូឌុលនោះគេត្រូវប្រើការសរសេរអក្សរ។





**៩.ការពិភាក្សា** : ម៉ូឌុលនេះបង្រៀនឱ្យចេះជ្រើសរើស រៀបចំ ដឹកនាំការពិភាក្សាលើបញ្ហាពលកម្មកុមារ ដកស្រង់ចេញពីម៉ូឌុល ដែលមានចំណងជើងថា : ការស្រាវជ្រាវ និងព័ត៌មាន ការតាក់តែងអក្សរសាស្ត្រ និង ការសម្តែងតួ.....។ ម៉ូឌុលនេះពង្រីកសមត្ថភាពនិយាយទៅកាន់សាធារណៈជន ចូលរួមការពិភាក្សា ហើយ និងធ្វើការទំនាក់ទំនង។ វាអាចធ្វើឱ្យសហគមន៍ភ្ញាក់រលឹកចាប់អារម្មណ៍ផងដែរ។



**១០.ប្រព័ន្ធផ្សព្វផ្សាយ** : ម៉ូឌុលនេះសម្រាប់ឱ្យស្គាល់ប្រព័ន្ធផ្សព្វផ្សាយជាសាកល។ វាបង្ហាញរបៀបបង្កើតចំណងទាក់ទងជាមួយប្រព័ន្ធផ្សព្វផ្សាយ ក្នុងឱ្យគេចុះផ្សាយទៅទំព័រមុខគេ។ វាបង្រៀនឱ្យសរសេរសេចក្តីថ្លែងការ ប្រកាសជូនដំណឹងសម្រាប់សាព័ត៌មានឱ្យចេះតាមដានត្រួតពិនិត្យការផ្សព្វផ្សាយ ចេះត្រៀមខ្លួនសម្ភាសន៍តាមវិទ្យុ និង ទូរទស្សន៍ ។ វាបង្ករលក្ខណៈងាយស្រួលឱ្យសហគមន៍ចូលរួម និងមានការចាប់អារម្មណ៍យ៉ាងខ្លាំង។





**១១.ល្ខោន** : ម៉ូឌុលនេះបង្រៀនឱ្យចេះតែង និង សម្តែងរឿងល្ខោនស្តីពីពលកម្មកុមារ។ វាលើកទឹកចិត្តដល់យុវជនឱ្យសម្តែងសិល្បៈ។ វាជាមធ្យោបាយសម្រាប់ឱ្យសហគមន៍ចូលរួម និង ចាប់អារម្មណ៍។



**១២.ពិភពការងារ** : ម៉ូឌុលនេះនាំឱ្យយល់ដឹងច្បាស់លាស់អំពីកង់ ឬកម្លាំងដែលធ្វើឱ្យរោងចក្រមានចលនា និងសកម្មភាពម៉ូឌុលនេះអួតសរសើរត្រីភាគីនិយម ហើយជួយដល់ការអភិវឌ្ឍសង្គម។ វាចាប់ផ្តើមពន្យល់អំពីតួនាទី ដែលត្រូវបំពេញដោយផ្នែកផ្សេងៗនៃសហគមន៍ និងបង្ហាញនូវអន្តរកម្មផ្សេងៗដែលនាំទៅរកការចំណេញដល់សង្គម។



**១៣.សមាហរណកម្មសហគមន៍** : ម៉ូឌុលនេះមានគោលដៅជំរុញឱ្យមានការចូលរួមពីសហគមន៍ក្រៅដល់គម្រោង ស្តីពីពលកម្មកុមារ។ វាពង្រឹងតួនាទីរបស់យុវជនដែលត្រូវបានចាត់ទុកជាកម្លាំងចលនានៃសង្គម និងការផ្លាស់ប្តូរសង្គម។

សៀវភៅផ្សេងទៀតនឹងត្រូវបានតាក់តែង និងបញ្ចូលទៅក្នុងកម្មវិធីលំដាប់លំដោយ។ តន្ត្រី និង កីឡាគឺជាកម្លាំងមួយយ៉ាងខ្លាំងអាចធ្វើឱ្យយុវជនចាប់ចិត្ត និងមានគំនិតច្នៃប្រឌិត។ សៀវភៅដែលមានខ្លឹមសារជុំវិញរឿងនេះកំពុងតែនិពន្ធ។ ទន្ទឹមនិងសិល្បៈល្ខោន តន្ត្រីបានឆ្លងកាត់រាល់របាំងទាំងឡាយ ហើយពង្រីកអត្តសញ្ញាណវប្បធម៌ ហើយបានដើរតួយ៉ាងសំខាន់រួចទៅហើយ ក្នុងការនិពន្ធកម្មវិធី Scream នេះ។ តន្ត្រី និងចម្រៀងបញ្ចូលទៅក្នុង Scream ជាពិសេសទៅក្នុងសៀវភៅ "ការសម្តែងល្ខោន" និង "សមាហរណកម្មសហគមន៍ "។

លើសពីការនិពន្ធសៀវភៅថ្មីទៀត សៀវភៅដែលមានស្រាប់ក៏ត្រូវបានកែលំអរជាប្រចាំតាមគោលការណ៍បទពិសោធន៍ដែលទទួលបាន។ សៀវភៅថ្មី និងសៀវភៅកែលំអរ និងត្រូវដាក់សម្រាប់ឱ្យប្រើប្រាស់តាមគេហទំព័ររបស់ IPEC ដើម្បីឱ្យទទួលព័ត៌មានជានិច្ចអំពីដំណើរការជោគជ័យរបស់កម្មវិធី ស្គ្រីម ព្រមទាំងសកម្មភាពផ្សេងៗរបស់ IPEC ។ យើងនឹងសាកល្បងជាលំដាប់លំដោយរាល់សៀវភៅដែលបាននិពន្ធរួច។ រឿងនេះជួយយើងឱ្យចម្រាញ់យកវិធីល្អៗ និងសកម្មភាពដើម្បីឱ្យងាយស្រួលប្រើប្រាស់។ យើងមិនត្រឹមតែទទួលអារម្មណ៍ថាសៀវភៅទាំងនេះជាឧបករណ៍គរុកោសល្យបានសម្រេចជោគជ័យទេ ប៉ុន្តែយើងបានរកឃើញគំនិតថ្មីសម្រាប់តាក់តែងសៀវភៅថ្មីផ្សេងទៀត។ ម្យ៉ាងទៀតតំណាក់កាលបទពិសោធន៍ត្រូវបានគេប្រើ ដើម្បីបង្កើតវីដេអូ ក្នុងបំណងជួយអ្នកអប់រំដែលចង់ប្រើប្រាស់សៀវភៅជាមួយក្រុមរបស់គេ។ វីដេអូផ្តល់នូវទស្សនៈរួមក្នុងការប្រើ វិធីសាស្ត្រគរុកោសល្យ ហើយផ្តល់នូវគំនិតប្រើប្រាស់ម៉ូឌុលទាំងនេះ ព្រមទាំងរបៀបប្រើប្រាស់ផង។

ម៉ូឌុលនេះត្រូវបានតាក់តែងឡើងនៅពេលដែលធនធាននៅតិចនៅឡើយ។ យើងមានជំនឿថានៅក្នុងបរិបទជាតិ និងតំបន់ខ្លះវាប្រាកដជាពិបាកប្រើប្រាស់ម៉ូឌុលខ្លះ។ ដើម្បីធ្វើឱ្យការពិបាកនេះរួមតូចម៉ូឌុលទាំងឡាយត្រូវតែទន់ភ្លន់ បត់បែន។ ប្រសិនបើអ្នកមិនមានមធ្យោបាយអនុវត្តទេ សូមអ្នកកុំអនុវត្តម៉ូឌុលទាំងនេះ។ សូមកុំភ្លេចថាអ្នកអាចសម្របសម្រួលសម្ភារឱ្យតាមបរិបទរបស់អ្នក។ ម៉ូឌុលនេះជាកម្មសិទ្ធិរបស់អ្នកអប់រំ និងក្រុមដែលត្រូវសម្រេចថាត្រូវដោយរបៀបណានោះ។

ប័ណ្ណដែលមានឈ្មោះថា "ការដាក់ឱ្យដំណើរការ" ខាងក្រោមនេះប្រាប់របៀបប្រើប្រាស់ម៉ូឌុលនេះ គឺប្រាប់រយៈពេលការបញ្ចូលគ្នានូវខ្លឹមសារម៉ូឌុលដោយគិតទៅតាមស្ថានភាពដែលផ្សេងគ្នា។

ម៉ូឌុលឈុតកម្មវិធី ស្គ្រីម ជារួមអាចខ្លី ឬវែងទៅតាមពេលវេលាដែលអ្នកមាន។ អ្នកអាចអនុវត្តម៉ូឌុលតាមគោលបំណងជាក់ស្តែងរបស់អ្នក ដូចជាការបង្កើតរឿងល្ខោនក្នុងក្របខ័ណ្ឌអប់រំផ្លូវការស្តីពីសិទ្ធិមនុស្ស។ អ្នកអាចអនុវត្តម៉ូឌុលតែមួយ ប្រសិនបើអ្នកចង់ អ្នកអាចប្រើប្រាស់ម៉ូឌុលនេះច្រើន ឬទាំងអស់ក៏បាន តាមលទ្ធភាព និងស្ថានភាព។ ម៉ូឌុលទាំងអស់មានខ្លឹមសារទន់ភ្លន់ បត់បែន។ ប៉ុន្តែដើម្បីឱ្យផលប៉ះពាល់ និងការប្រើប្រាស់មានប្រសិទ្ធភាព យើងសូមឱ្យអនុវត្តតាមភាពសមហេតុសមផលខ្លះ យើងត្រូវចាប់ផ្តើមការអនុវត្តតាមព័ត៌មានមូលដ្ឋាន រួចមកតាមរយៈសិល្បៈ តាមរយៈយុទ្ធនាការ និងតាមរយៈការងារជាប្រព័ន្ធ។

ទិដ្ឋភាពដែលមានរយៈពេលវែង តម្រូវឱ្យអនុវត្តកម្មវិធីទាំងមូល ឬសៀវភៅទាំងអស់ គឺចាប់ផ្តើមធ្វើឱ្យគេចាប់អារម្មណ៍ចំពោះបញ្ហា បង្កើតឥទ្ធិពលចិត្តសាស្ត្រទៅលើស្ថានភាពបច្ចុប្បន្នរហូតដល់ការធ្វើឱ្យចង់ផ្លាស់ប្តូរសង្គមពេលក្រោយបង្អស់ធ្វើសកម្មភាពតែម្តង។ យើងសូមឱ្យអ្នកអាចយល់ខ្លឹមសារម៉ូឌុលឱ្យច្បាស់ មុនពេលចាប់ផ្តើមអនុវត្តកម្មវិធី សូមឱ្យពេលវេលារបស់អ្នកឱ្យបានច្បាស់លាស់ព្រមទាំងវិធីសាស្ត្រលំដាប់លំដោយនៃការអនុវត្តស្របតាមតម្រូវការជាក់ស្តែង។

ម៉ូឌុលឈុតនេះនឹងផ្តល់នូវលទ្ធភាពធ្វើយុទ្ធនាការបំផុសការយល់ដឹងប្រកបដោយប្រសិទ្ធភាពនៅក្នុងសហគមន៍។ យើងសង្ឃឹមថាដោយផ្អែកទៅលើពេលវេលា និងការប្រើប្រាស់រីកដាលកាន់តែធំម៉ូឌុលនឹងត្រូវផលិតកាន់តែច្រើន ហើយខ្លឹមសារត្រូវបានកែលំអកាន់តែប្រសើរឡើង។

## របៀបដែលម៉ូឌុលទាំងនេះមានដំណើរការ



ម៉ូឌុលនីមួយៗចាប់ផ្តើមឡើងដោយសង្ខេបដែលបង្ហាញពីវត្ថុបំណង "លទ្ធផលរំពឹងទុក" និង "ការកំណត់ពេលវេលា"។ ពេលវេលាអនុវត្តអាចបត់បែន។ តាមធម្មតាអ្វីដែលជាការផ្តល់យោបល់គឺឆ្លុះបញ្ចាំង ពេលវេលាតិចបំផុតសម្រាប់អនុវត្តម៉ូឌុលណាមួយឱ្យបានត្រឹមត្រូវ មិនខ្វះខ្វាយពេលវេលា។ ពេលវេលាបង្រៀនត្រូវផ្អែកលើបទដ្ឋាន ៤០ នាទី ដែលជាពេលវេលាត្រូវបានប្រើក្នុងសាលាជាច្រើនក្នុងពិភពលោក។ ពេលវេលាធ្វើមាន ៨០ នាទី។ ជួនកាលមានការពិបាកបង្រៀនក្នុងរយៈ ពេល ៤០ នាទី ដូច្នេះអ្នកអាចប្រើពេលវេលាបន្តបន្ទាប់គ្នា (ពេលមានរយៈពេល ៨០នាទី) ប្រសិនបើអ្នកមិនស្ថិតនៅក្នុងសាលាក្នុងប្រព័ន្ធ អ្នកមានការងាយស្រួលក្នុងការកំណត់ពេលវេលាតាមតម្រូវការ។

ប្រសិនបើកត្តាពេលវេលាជាកត្តាសំខាន់ ប្រសិនបើអ្នកមានពេលបង្រៀនពេលណាមួយកំណត់ជាមួយក្រុមយុវជនរបស់អ្នក សូមបញ្ជាក់ពេលបង្រៀនក្នុងរយៈពេលកំណត់ ហើយចាប់ផ្តើមបង្រៀនវិញនៅលើកក្រោយ។ បញ្ឈប់ការបង្ហាញដែលយុវជនបានរៀបចំដោយផ្ចិតផ្ចង់ អាចធ្វើឱ្យបាត់លំនឹង និងភាពស្វាហាប់របស់ក្រុមដែលអ្នកត្រូវតែលើកទឹកចិត្ត។ អំណោយផលនៃម៉ូឌុលនេះមានស្ថិតស្ថេរនៅក្នុងហេតុការដែលម៉ូឌុលទាំងនេះមិនពាក់ព័ន្ធនឹងពេលវេលាអនុវត្ត ឬនិងកម្មវិធីបង្ខិតបង្ខំឡើយ។ ដូច្នេះសូមអ្នកកុំភ័យ ប្រសិនបើអ្នកមិនអាចបញ្ចប់ម៉ូឌុលណាមួយក្នុងរយៈពេលកំណត់ ប្រសិនបើអ្នកទទួលការបង្ខិតបង្ខំផ្នែកខាងពេលវេលា សូមអ្នកផ្តល់ទៅឱ្យក្រុមជាមុននូវការណែនាំទូទៅមួយ ស្តីពីកាលវេលាកំណត់រាល់ការបង្ហាញនីមួយៗ (បរិយាយ)។

"**ការរៀបចំ**" ផ្តល់នូវការដំបូន្មានមួយចំនួនអំពីអ្វីដែលត្រូវធ្វើ មុនពេលធ្វើសកម្មភាពក្នុងនោះមានការស្វែងរកពតិមានមូលដ្ឋាន ការទទួលបាននូវសំភារៈ ការបង្កើតទំនាក់ទំនងជាដើម។ ក្នុងវិធានការមានលទ្ធភាព សូមឱ្យយុវជនចូលរួមការត្រៀមរៀបចំនេះដោយមិនបង្ហាញអ្វីទាំងអស់ដល់ពួកគេតែម្តងទៅលើឆាកឡើយ ប៉ុន្តែផ្ទុយទៅវិញត្រូវផ្តល់លទ្ធភាពទៅពួកគេ ដើម្បីដើរតួយ៉ាងស្វាហាប់។ ការធ្វើការរបៀបនេះពង្រឹងការចូលរួម និង ស្មារតីរបស់ពួកគេចំពោះគម្រោង។

បញ្ជីសម្ភារសំខាន់ៗ នៅក្នុងម៉ូឌុលនីមួយៗត្រូវបានផ្តល់តាម "អ្វីដែលអ្នកត្រូវការ"។ ប៉ុន្តែអ្វីៗដែលពណ៌នានៅក្នុងម៉ូឌុលនេះមិនសំខាន់នឹងចាំបាច់ណាស់ណាទេ។ ប្រភពដែលសំខាន់តែមួយគត់គឺយុវជនខ្លួនឯងតែម្តង។



របស់ផ្សេងទៀតអាចជំនួសបាន ឬធ្វើឡើងមិនចាំបាច់មានអ្វីទាំងអស់ កាលណាសម្ភារត្រូវតែមានជាការចាំបាច់ មានផ្នែកមួយក្នុងម៉ូឌុលនីមួយៗស្តីពីបញ្ហារក "ជំនួយពីក្រៅ"។ មានបទពិសោធន៍ ឬមានសមត្ថភាពដោយរៀបរៀងទៅនឹងវិធីសាស្រ្តដែលត្រូវគេប្រើក្នុងម៉ូឌុលទាំងឡាយ ហើយប្រសិនបើអ្នកទទួលជំនួយពីមនុស្សដែលមានបទពិសោធន៍ ឬសមត្ថភាពនេះ ដើម្បីសរសេររឿងល្ខោន ឬ តាក់តែងអក្សរសាស្រ្តអ្នកត្រូវឆ្លៀតយកឱកាសនោះ។ ម្យ៉ាងទៀតនៅពេលស្វែងរកជំនួយ អ្នកឈានទៅដល់គោលបំណងមួយក្នុងចំណោមគោលបំណងទាំងឡាយនៃម៉ូឌុលទាំងនោះ គឺបំណងចង់ធ្វើឱ្យមានការចូលរួមពីសមាជិកនៃសហគមន៍ ចង់សម្រួលឱ្យមានការចាប់អារម្មណ៍ពីសហគមន៍ ឬបង្កើនផលប៉ះពាល់នៃគម្រោង។ ប៉ុន្តែការស្វែងរកជំនួយពីខាងក្រៅមិនមែនជាកត្តាសំខាន់សម្រាប់អនុវត្តម៉ូឌុលទាំងនេះឡើយ។ សូមធ្វើតាមការណែនាំក្នុងម៉ូឌុលនេះ អ្នកនឹងទទួលបាននូវលទ្ធផលយ៉ាងប្រពៃ។



ការពណ៌នាអំពី "សកម្មភាពជាក់ស្តែង" អំពី "វិធីសាស្ត្រ" ហើយនឹងអំពីការ "រៀបចំក្រុម" បង្កើតបានផ្នែកមួយដ៏សំខាន់នៃម៉ូឌុលទាំងនេះ។ អ្នកប្រើប្រាស់មានព័តិមានស្តីពីការអនុវត្តម៉ូឌុលណាមួយ ឬស្តីពីរបៀបរៀបចំក្រុម។ កាលណាបានទទួលព័តិមាន និងរបៀបបែបបទរួចហើយ អ្នកអាចអនុវត្តធ្វើសកម្មភាពតែម្តង។ សកម្មភាពទាំងនេះមានពណ៌នាយ៉ាងពិស្តារួចហើយនៅក្នុងម៉ូឌុលដោយមានការណែនាំប្រកបដោយលក្ខណៈសប្បាយរីករាយ។ **"កំណត់សម្គាល់សំខាន់សម្រាប់អ្នកប្រើប្រាស់"** មានចំណុចសំខាន់ៗជាពិសេស។

នៅទីបំផុតនៅក្នុងជំពូក **"វាយតម្លៃ"** ម៉ូឌុលឈានទៅដល់លទ្ធផលដែលគេសង្ឃឹមទុក។ នៅពេលចប់ម៉ូឌុលនីមួយៗឈានទៅដល់បញ្ហារបៀបបែបបទដោយសារម៉ូឌុលផ្សេងទៀត ឬសកម្មភាពផ្សេងទៀត។

## ការរៀបចម្លងម៉ូឌុល

**ចំណងជើងនៃម៉ូឌុល** : សេចក្តីសង្ខេបខ្លីច្បាស់លាស់នៃម៉ូឌុល នៃគោលបំណង និងពេលវេលាអនុវត្ត ក្នុងនោះមានចំនួនពេលវេលាបង្រៀនសំខាន់ៗ។

**ហេតុផល** : ការពណ៌នាគោលដៅនៃម៉ូឌុល របៀបចូលរួមក្នុងដំណើរការសរុប និងអំណោយផលសម្រាប់យុវជន និងសម្រាប់គម្រោងទាំងមូល។

**ការរៀបចំ** : ការរៀបចំជួយអ្នកអប់រំឱ្យត្រៀមខ្លួនជាមុនក្នុងការបង្រៀនក្នុង "ថ្នាក់រៀន"។ ចំណងជើងរងមាន "ជំនួយពីខាងក្រៅ" "ការជួបផ្ទាល់ជាមុន"។ ការងារទាំងនេះប្រែប្រួលទៅតាមលក្ខណៈរបស់ម៉ូឌុល។

ផ្នែកនេះចែកចេញជាបញ្ជីសំភារៈចាំបាច់ (សំភារៈមានប្រយោជន៍)។

**ការចាប់ផ្តើម:** ពេលបង្រៀនដំបូងដែលនាំមកព័តិមានមូលដ្ឋានបង្ហាញឱ្យឃើញភ្ញៀវទាំងឡាយ។ល។ ចំណងជើងរងមានការណែនាំ ស្តីពីការរៀបចំក្រុមរបៀបដាក់ទីតាំងនៃបរិបទឱ្យស្របតាមបំណងរបស់យុវជន។

**សកម្មភាព** : សកម្មភាពនីមួយត្រូវបានពណ៌នាយ៉ាងពិស្តារជាដំណាក់ៗ។

**អ្វីដែលត្រូវធ្វើ និងមិនត្រូវធ្វើ** : បញ្ជីនេះជួយអ្នកឱ្យដកស្រង់ផ្នែកណាមួយដែលអាចចេញពីម៉ូឌុលនេះ ហើយជៀសវាងឱ្យផុតពីអន្ទាក់ (ឧបសគ្គ)

**ការពិភាក្សាបញ្ចប់** : ការពិភាក្សាបញ្ចប់នេះផ្តល់នូវការសង្ខេប និងប្រតិសកម្ម ដើម្បីឱ្យអ្នកអប់រំធ្វើការសង្ខេបនៃសកម្មភាព និងផ្តល់លទ្ធភាពឱ្យយុវជនសម្តែងចេញមកនូវអ្វីដែលគេបានធ្វើជាមួយនឹងស្មារតីរបស់គេ។

**ការវាយតម្លៃ និងសកម្មភាពបន្ត** : ផ្នែកនេះជួយអ្នកឱ្យចេះវាយតម្លៃការរីកចម្រើនជ័យជំនះបរាជ័យមេរៀនទទួលបានពីក្រុមវាយតម្លៃអ្វីៗដែលអាចធ្វើបានចំពោះម៉ូឌុលណាដែលគេអាចអនុវត្ត។

## គំនិតគោលដើម្បីទទួលជ័យជំនះ

មុននឹងសម្រេចយកបន្ទាត់ដឹកនាំ សូមលោកអ្នកពិចារណាឱ្យជ្រាលជ្រៅអំពីមូលហេតុផ្ទាល់ខ្លួនដែលដឹកនាំអ្នកឱ្យអានផ្នែកនេះរហូតមក ។ យើងត្រូវការពិចារណាលើអ្វីដែលជម្រុញអ្នកឱ្យអនុវត្តម៉ូឌុលទាំងនេះ ឬឱ្យអនុវត្តតាមកម្មវិធីជាទូទៅ ។ ដោយផ្អែកទៅលើមូលហេតុអ្វីដែលអ្នកកំពុងពិគ្រោះយោបល់ការបោះពុម្ពផ្សាយនេះ តើអ្វីបានជម្រុញអ្នកឱ្យគិតដល់ការប្រើប្រាស់ម៉ូឌុលទាំងនោះ តើបរិបទអ្វីដែលនៅក្នុងនោះអ្នកត្រូវធ្វើការ? ហេតុផលរបស់អ្នកគឺការចូលរួមរបស់អ្នកយ៉ាងណាខ្លះក្នុងយុទ្ធនាការលុបបំបាត់ពលកម្មកុមារ ការទទួលខុសត្រូវរបស់អ្នកមានកំរិតដល់ណា ហើយនិងការចូលរួមរបស់អ្នកចំពោះយុវជន ទាំងឡាយមានកំរិតដល់ណា?



ប្រសិនបើមានលក្ខណៈដ៏សំខាន់ខ្លាំងពីរ ហើយដែលជ្រួតជ្រាបក្នុងម៉ូឌុលទាំងនេះ ដោយបង្កើតនូវគោលគំនិតសំខាន់ៗដើម្បីធ្វើឱ្យសម្រេចជោគ ជ័យនោះការចូលរួមនិងការគោរព ។ ការចូលរួមផ្ទាល់របស់អ្នកនៅចំមុនពេលការអនុវត្តដ៏មានជោគជ័យនៃម៉ូឌុលទាំងនេះ ស្តីពីយុទ្ធនាការពិភពលោក ដើម្បីលុបបំបាត់ពលកម្មកុមារ ការលើកកំពស់ និងការគោរពសិទ្ធិរបស់កុមារ ក៏ដូចជាសិទ្ធិរបស់យុវជនដែលអ្នកធ្វើការជាមួយ ការចូលរួមនេះគឺជាកត្តាសំខាន់ជាងគេបង្អស់ ដើម្បីបង្កើតឡើងវិញនៅការចូលរួម និងហេតុផលនៅក្នុងក្រុមយុវជន ។

នៅក្នុងដំណើរការវាយតម្លៃ ក្នុងដំណាក់កាលនៃការពិសោធន៍ការធ្វើអធិប្បាយពន្យល់អំពីក្រុមកុមារនៅក្នុងបរិបទអប់រំជាផ្លូវការ គឺតម្រូវឱ្យវាយតម្លៃហេតុការដែលគំនិតរបស់យុវជនត្រូវបានគេស្រាវជ្រាវរកឃើញ និងត្រូវបានគេវាយតម្លៃ ។ អ្វីយុវជនមានអារម្មណ៍ហើយពួកគេបាននិយាយនោះ គឺមានសារៈសំខាន់ណាស់ព្រោះថាមានអារម្មណ៍បានធ្វើអន្តរាគមន៍ដល់ពួកគេ និង ការធ្វើអត្ថាធិប្បាយរបស់ពួកគេត្រូវបានគេស្គាល់ ។ ម៉ូឌុលទាំងនេះមានមូលដ្ឋានផ្អែកទៅលើគោលការណ៍ដែលយុវជនទាំងឡាយដើរតួសំខាន់ក្នុងយុទ្ធនាការលុបបំបាត់ពលកម្ម ម្យ៉ាងទៀតសៀវភៅទាំងអស់ឱ្យតម្លៃសិទ្ធិកុមារ ហើយនិងតួនាទីរបស់យុវជនក្នុងឋានៈជាអ្នកធ្វើឱ្យសង្គមមានការផ្លាស់ប្តូរ ។ ដូច្នេះប្រសិនបើយើងជឿជាក់ថា យុវជនទាំងឡាយគឺជាស្នូលនៃយុទ្ធនាការនោះ យើងត្រូវផ្តល់ឱ្យពួកគេនូវការគោរពដែលពួកគេសាកសម និងទទួលពិសេសនៅពេលដែលពួកគេទទួលខុសត្រូវដល់ពួកគេ ។

ម៉ូឌុលទាំងនោះផ្តល់ឱ្យយុវជននៅព័ត៌មាន និងចំណេះដឹងយ៉ាងច្រើន។ ម៉ូឌុលទាំងនោះធ្វើឱ្យមានការរីកស្រស់បំព្រងដល់សង្គម និងបុគ្គល។ នៅក្នុងប្រទេសខ្លះ យុវជនទាំងឡាយអាចខ្វះសេចក្តីទុកចិត្ត និងការឱ្យតម្លៃខ្លួនឯង ជាពិសេសក្នុងរយៈពេលវ័យជំទង់។ ផ្នែកមួយនៃដំណើរការអប់រំតម្រូវឱ្យពង្រឹងទិដ្ឋភាពសំខាន់ទាំងពីនៃជីវភាពរបស់យុវជន។ យុវជនខ្លួនឯងផ្ទាល់ និងក្លាយទៅជាអ្នកដែលដឹកនាំដំណើរការអនុវត្តតាមរយៈស្រាវជ្រាវយុទ្ធនាការរបស់ពួកគេការសម្តែងសិល្បៈល្ខោនរបស់ពួកគេ ការតាក់តែងអក្សរសាស្ត្ររបស់ពួកគេ ស្នាដៃសិល្បៈរបស់ពួកគេ និងតាមរយៈសាលិខិតដែលពួកគេផ្ញើជូនដល់សហគមន៍ដ៏ទូលំទូលាយ។ យុវជន និងក្លាយទៅជាអ្នកអប់រំតាមវេនរបស់ពួកគេ។ ពួកគេអប់រំដៃគូរបស់គេ និងសមាជិកផ្សេងទៀតនៃសហគមន៍របស់គេ។ ពួកគេជាម៉ាស៊ីនដែលធ្វើឱ្យសង្គមប្រែប្រួល។

## ត្រូវស្គាល់ក្រុមគោលដៅរបស់អ្នក

ក្រុមគោលដៅ គឺជាសមាសភាគដ៏សំខាន់ជាងគេបង្អស់នៃកម្មវិធីអប់រំនេះ។ ចូលអ្នកគិតដោយយកចិត្តទុកដាក់ដល់យុវជន ដែលចូលរួមដំណើរការអប់រំជាមួយអ្នក។ ជាការពិតណាស់ក្រុមយុវជនមានភាពខុសប្លែកគ្នាខ្លាំងណាស់ គួរឱ្យកត់សម្គាល់ទៅតាមកន្លែងភូមិសាស្ត្រ ហើយនិងបរិបទដែលនៅនឹងកន្លែងធ្វើការ។ ឧទាហរណ៍ ដូចជាយុវជនខ្លះនៅក្នុងក្រុមអាចជាកុមារពលកម្មតែម្តង។ ចូរអ្នកពិចារណាចំពោះបញ្ហាខាងក្រោមនេះ និងបញ្ហាដែលអ្នកលើកឡើងដោយខ្លួនអ្នក ពីព្រោះអ្នកនិងក្លាយទៅជាកម្លាំងចលករដើមគេបង្អស់។ វាអាចឱ្យអ្នកសន្និដ្ឋានថាបញ្ហាខ្លះមិនស្របតាមស្ថានភាពរបស់អ្នក ចូរអ្នកកុំបារម្ភ ហើយចូលអ្នកប្រើប្រាស់បញ្ហាដែលសម្របសម្រួលប្រសើរជាងគេ ចំពោះបរិបទរបស់អ្នក ហើយសូមអ្នកស្នើឡើងបញ្ហាផ្ទាល់របស់អ្នក។ អ្នកត្រូវស្គាល់គោលដៅជាមុខសញ្ញាមាននៅក្នុងគ្រប់ទិសទី ចូរអ្នកធ្វើការទំនាក់ទំនងជាមួយគោលដៅនោះ ចូរអ្នកយល់គោលដៅឱ្យបានច្បាស់លាស់ ចូរអ្នកទទួលឱ្យបាននូវការគោរពសេចក្តីទុកចិត្តរបស់គោលដៅ។ ការអនុវត្តម៉ូឌុលទាំងនេះ និងមានភាពងាយស្រួលអំពីលំហូព័ត៌មានដូចជា :

- ពួកគេគឺជាអ្នកណា? ពួកគេឈ្មោះអ្វី?
- មានក្មេងប្រុសប៉ុន្មាន ហើយនិងក្មេងស្រីប៉ុន្មាន?
- អាយុប៉ុន្មាន?
- តើអ្នកស្គាល់ពួកគេដោយរបៀបណា? តើអ្នកស្គាល់ពួកគេទាំងអស់គ្នាឬទេ?

- ប្រភពពួកគេមកពីណា? ពួកគេរស់នៅក្នុងស្ថានភាពបែបណា? ឧទាហរណ៍ បរិស្ថានសង្គមសេដ្ឋកិច្ចរបស់ពួកគេយ៉ាងដូម្តេច?
- កំរិតវប្បធម៌របស់ពួកគេយ៉ាងណាដែរ ប្រសិនបើមាន ? តើពួកគេនៅរៀននៅឡើយ? ពួកគេជាអ្នកចេះអក្សរឬ រៀនសូត្របានមធ្យម?
- អ្នកអាចពណ៌នាលក្ខណៈចិត្តសាស្ត្រ នឹងរូបកាយដោយរបៀបណាដែរពួកគេត្រូវបានគេរាប់អាន ទាក់ទង ជាជនមិនគួរទុកចិត្ត ជាមនុស្សខ្ជិល ជាមនុស្សសប្បាយចិត្ត ជាមនុស្សក្រៀមក្រំគេមើលងាយ ជាមនុស្សអប់រំមិនល្អឬ?
- តាមការស្គាល់របស់អ្នក តើមាននរណាម្នាក់ក្នុងក្រុមត្រូវបានធ្វើអាជីវកម្មផ្លូវភេទ ឬការរំលោភផ្លូវភេទឬទេ ? តើយុវជនទាំងនោះមានតម្រូវការជាក់លាក់ឬទេ? តើពួកគេត្រូវទទួលការអប់រំផ្នែកចិត្តសាស្ត្រ ផ្នែកសរសៃប្រសាទ ឬផ្នែករូបកាយឬទេ? តើអ្នកបានពិភាក្សាជាមួយឪពុកម្តាយរបស់ពួកគេ អាណាព្យាបាលរបស់ពួកគេ មិត្តភក្តិរបស់គេជាមួយនិងក្រុមគ្រូពេទ្យដែលតាមដានពួកគេទេ? តើអ្នកសន្និដ្ឋានថាម៉ូឌុលអស់ទាំងនេះ ឬគម្រោងអាចធ្វើឱ្យពួកគេភ្ញាក់រលឹក និងឈឺចាប់កាន់តែខ្លាំងឬទេ តើអ្នក គិតថា និងគ្រប់គ្រងស្ថានភាពទាំងនេះដូចម្តេច?
- តើមានការពិភាក្សា និងការព្យាបាលដូចខាងលើជាមួយនឹងជនពិការផ្នែកផ្លូវចិត្ត ផ្នែករូបកាយឬទេ? អ្នកនឹងគ្រប់គ្រងជនពិការដូចម្តេច? តើពួកគេមានតម្រូវការ ឬការទាមទារច្បាស់លាស់ឬទេ? តើអ្នកស្ថិតនៅក្នុងវិធានការជួយពួកគេឬទេ?
- អ្នកពណ៌នាកំរិតចំណាប់អារម្មណ៍របស់ពួកគេចំពោះបញ្ហាសង្គមតាមរបៀបណាដែរ តើពួកគេចាប់ចិត្តចំពោះបញ្ហាសង្គមនេះដោយរបៀបណា ឬមួយពួកគេមិនខ្វល់ចំពោះបញ្ហាសង្គមនេះ?
- តើពួកគេមានសញ្ជាតិដូចគ្នា មានប្រភពជនជាតិដូចគ្នាឬប្រភពវប្បធម៌ដូចគ្នា ពួកគេមានភាសាដើមដូចគ្នាឬ? តើអាចមានរបាំងភាសារវាងពួកគេឬទេ?
- តើអ្នកកំណត់ច្បាស់លាស់នូវទំនាក់ទំនងក្រុមដោយរបៀបណា? តើមានសម្ពាធរវាងបុគ្គល និងបុគ្គលឬទេ តើមានទំនាក់ទំនងផ្ទាល់ខ្លួននៅក្នុងក្រុមឬទេ? តើអ្នកមើលឃើញស្ថានភាពបែបណាក្នុងការទំនាក់ទំនងអាចបណ្តាលឱ្យមានបញ្ហា ឬអាចទាមទារឱ្យមានការប្រុងប្រយ័ត្នជាពិសេសឬទេ?
- តើយុវជនដែលបានចេញទៅធ្វើការរួចហើយ ឬដែរត្រូវបានគេចាត់ទុកថាជាកុមារពលកម្មឬទេ? តើមាននរណាមួយដែលបានបង្ហាញសក្ខីភាពដោយផ្ទាល់ ស្តីពីពលកម្មកុមារឬទេ? ប្រសិនបើមាន តើកុមារទាំងនេះធ្វើការពេញម៉ោង ឬពាក់កណ្តាលម៉ោង? ជួនកាលសៀវភៅទាំងនោះបកស្រាយបញ្ហាមួយចំនួនទាក់ទងទៅនិងការរំលោភផ្លូវភេទឬអាជីវកម្មផ្លូវភេទរបស់កុមារ ។ ក្រុមរបស់អ្នកនិងដឹងថាក្មេងទាំងឡាយ គឺជាពលករដែលត្រូវបានគេរំលោភបំពាន ហើយនិងដឹងថា អាជីវកម្មផ្លូវភេទរបស់កុមារក្នុងគោលដៅពាណិជ្ជកម្ម គឺជាទម្រង់ការងារមួយដ៏អាក្រក់យុងឃ្នង ។

អ្នកសន្និដ្ឋានទិដ្ឋភាពនៃពលកម្មកុមារនេះប៉ះទង្គិចយុវជនទាំងឡាយយ៉ាងខ្លាំង ហើយយុវជនទាំងនោះ និងមិនសប្បាយចិត្តរឿងនេះឡើយ ប្រតិកម្មទាំងនេះត្រូវបានគេអបអរសាទរ ហើយប្រធានបទនេះមិនគប្បីត្រូវបានចាត់ទុកជាអាទិភាពមួយឡើយពីព្រោះវានិងបង្កហេតុឱ្យមានប្រតិកម្មយ៉ាងខ្លាំងក្លា។ វាអាចបណ្តាលឱ្យមានការសើចចំអក ប៉ុន្តែអ្នកគប្បីដឹងថា នេះគឺជាយន្តការគោរពក្នុងយុវជន នៅពេលយុវជនត្រូវបានប្រឈមមុខនឹងបញ្ហាលំបាកៗ ប្រធានបទគប្បីត្រូវបានបកស្រាយពន្យល់ឱ្យបានច្បាស់លាស់ជាពិសេសនៅក្នុងបរិបទវប្បធម៌ខ្លះ ដែលនៅក្នុងនោះការពិភាក្សាចំហស្តីពីបញ្ហាភេទមិនត្រូវបានគេលើកទឹកចិត្ត ឬ នៅក្នុងករណីដែលក្នុងនោះអ្នកដឹងឬស្មានថា ក្នុងចំណោមយុវជននៃក្រុមរបស់អ្នក មានយុវជនខ្លះធ្លាប់ជាអ្នកទទួលរងគ្រោះផ្នែកខាងការរំលោភភេទ លំហាត់ខ្លះក្នុងម៉ូឌុលនេះដូចជាការសម្តែងរឿង ឬការបង្កើតអក្សរសាស្ត្រអាចមានប្រសិទ្ធភាព ដើម្បីជួយយុវជនគ្រប់រូបឱ្យចេះគ្រប់គ្រងការឈឺចាប់ពីអតីតកាល។ ទោះបីប្រើវិធីណាក៏ដោយនេះជារឿងសំខាន់ចំពោះពួកគេដែលត្រូវដឹងថាអ្វីដែលគេបានជួបប្រទះ គឺមានគ្រោះថ្នាក់ និងអ្វីដែលពួកគេមិនត្រូវទទួលយក មិនត្រូវបណ្តាលឱ្យអ្នកផ្សេងទៀតទទួលរងគ្រោះ ជាពិសេសកុមារពលកម្ម។ អនុសញ្ញាអន្តរជាតិទាំងឡាយ ហើយនិងច្បាប់ជាតិហាមឃាត់រឿងនោះក៏ប៉ុន្តែសង្គមអាចធ្វេចមិនប្រមើលឡើយ។ ការរំលោភផ្លូវភេទបានកើតមានឡើងស្ងាត់ៗ នៅពីក្រោយទ្វារបិទ។ អាប្បកិរិយានានាត្រូវតែផ្លាស់ប្តូរ ដើម្បីបំបែក ឬកំទេចចោលនូវការរំលោភ និងអាជីវកម្មលើកុមារ។ យុវជនទាំងឡាយត្រូវតែដឹងថា ពួកគេមានសិទ្ធិ ហើយសិទ្ធិទាំងនេះត្រូវការពារដោយច្បាប់។

សូមអ្នកប្រុងប្រយ័ត្នចំពោះប្រតិកម្មដែលមិនមានអំណោយផលនៅពេលអ្នកចាប់ផ្តើមបកស្រាយបញ្ហារំលោភផ្លូវភេទ ប្រសិនបើអ្នកណាមួយក្នុងក្រុម ហាក់ដូចជាត្រូវបានរំខាន ស្ថិតនៅស្ងាត់ស្ងៀមនោះអ្នកអាចស្វែងរក ការប្រឹក្សាផ្ទាល់ជាមួយនិងអ្នកអាជីព។ ជាការសំខាន់រឿងដែលរក្សាឱ្យបានខ្ជាប់ខ្ជួននូវគោល ការចំហសម្រាប់ទំនាក់ទំនងជាមួយសេវាកម្មជំនួយ។ កង្វល់ដំបូងរបស់អ្នកគឺ កង្វល់ស្វែងរកសុខមាលភាពរបស់បុគ្គលក្នុងក្រុមរបស់អ្នក។

អ្នកនិងត្រូវការយ៉ាងខ្លាំងនូវការខំប្រឹងប្រែង និងហេតុផលដើម្បីទឹកចិត្ត ក្រុម

គោលដៅ ដើម្បីបង្កើតសេចក្ដីទុកចិត្តរបស់គេ និងការគោរពរបស់គេនៅពេលអ្នកដឹកនាំសកម្មភាពជាក់ស្ដែង។ យុវជនទាំងឡាយមានសមត្ថភាពចូលរួមយុទ្ធនាការដើម្បីលុបបំបាត់ពលកម្មកុមារ។ ដំណាក់កាលមួយដ៏លំបាកខ្លាំងនៃជីវិត គឺការគាបសង្កត់នៃដៃគូពីរបស់ពួកគេ គឺមានកម្លាំងខ្លាំងណាស់មិនត្រូវមើលស្រាលនោះទេ ហើយអ្នកអាចប្រើប្រាស់វា ដើម្បីអំណោយផលរបស់អ្នក។

ម៉ូឌុលទាំងនេះត្រូវបានព្រមព្រៀងទទួលយកដោយសារគំនិតដើមនៃសេណារីយ៉ូ (រៀបចំឆាក) ឱ្យបានចំណេញទ្វេរដង។ ហេតុរបស់អ្នកការចូលរួមមហិច្ឆិតាហើយនិងការកំណត់អត្ថន័យច្បាស់លាស់ត្រូវបានបញ្ជូនទៅឱ្យរបស់អ្នក។ កាលណាអ្នកធ្វើការជាមួយសៀវភៅនេះ យើងសូមឱ្យអ្នកធ្វើឱ្យក្រុមរបស់អ្នកមានថាមពលស្វាហាប់។ សូមធ្វើឱ្យពួកគេមានការរំភើបឡើង ហើយរារាំងពួកគេកុំឱ្យយកអាកប្បកិរិយាអវិជ្ជមានឡើយ អ្នកត្រូវដើរចុះឡើងនៅចន្លោះពួកគេ សូមអ្នកប្រើប្រាស់កាយវិការ ដើម្បីបង្ហាញការជឿជាក់របស់អ្នក។ សូមអ្នកដឹកនាំថាមពលរបស់ពួកគេទៅរកគោលបំណង និងទិសដៅរបស់សៀវភៅទាំងនេះ ហើយជម្រុញពួកគេមានស្មារតីចូលរួម។ សូមធ្វើឱ្យពួកគេយល់ថារឿងទាំងអស់នេះពាក់ព័ន្ធពួកគេ ហើយពួកគេត្រូវតែទទួលខុសត្រូវចំពោះរឿងនោះ។ ចាប់តាំងពីពេលដែលពួកគេមានអារម្មណ៍ថានេះគឺជាគម្រោងផ្ទាល់របស់គេពេលនោះអ្នកបានឈ្នះក្នុងសមរភូមិ។

## ភាពស្វាហាប់ និងការគ្រប់គ្រងក្រុម

ភាពស្វាហាប់និងការគ្រប់គ្រងក្រុមគឺជាមធ្យោបាយសំខាន់សម្រាប់លទ្ធផលសម្រេចនៃសៀវភៅនេះ។ នេះគឺជាទិដ្ឋភាពមួយដែលទាមទារការខំប្រឹងប្រែងយ៉ាងខ្លាំងរបស់អ្នក ហើយនិងការផ្ចង់ស្មារតីរបស់អ្នក មុននឹងក្នុងពេលធ្វើលំហាត់។ ប្រសិនបើសមាជិកទាំងឡាយក្នុងក្រុមធ្វើការរួមគ្នាមិនបានល្អ បែកខ្ញែកគ្នា ឬខ្វែងគំនិតនោះ ការងារ និងក្លាយទៅជាលំបាកជាងមុនខ្លាំងណាស់។



ចូរអ្នកយកចិត្តទុកដាក់ដោយប្រុងប្រយ័ត្នទៅលើភាពស្វាហាប់របស់ក្រុម។ ចូរអ្នកព្យាយាមប្រមូលផ្ដុំព័ត៌មានឱ្យច្រើនជាអតិបរិមាអំពីសមាជិករបស់ក្រុមអំពីប្រតិកម្ម អំពីច្របូកច្របល់គ្នា។ល។គោលបំណងគឺស្វែងរកការចូលរួមឱ្យបានច្រើនអតិបរិមា ហើយប្រសិនបើអ្នកប្រមូលផ្ដុំយុវជនដែលមានបញ្ហារវាងគ្នា និង

គ្នារឿងនោះនឹងនាំទៅរកប្រសិទ្ធភាពនៃលំហាត់ទាំងមូល។ ប្រសិនបើអ្នកមិនមាន ការយល់ដឹងអំពីសម្ពាធដែលអាចកើតមានឡើងនោះ សូមអ្នកទាក់ទងនរណាមួយ ដែលនៅក្នុងក្រុម ហើយដែលអ្នកស្គាល់។ អ្នកនោះគឺជាមនុស្សដែលអ្នកទុកចិត្ត ហើយ អ្នកគោរពការវិនិច្ឆ័យរបស់គេ។

លំហាត់ខ្លះទាមទារឱ្យបំបែកក្រុមតូចៗ។ ក្នុងករណីនេះប្រសិនបើអ្នកធ្វើការ ជាមួយនិងក្រុមចម្រុះណាមួយនោះ សូមអ្នកកុំបំបែកក្រុមតាមភេទ ប្រសិនបើក្មេង ប្រុស ក្មេងស្រីត្រូវទុកឱ្យនៅក្នុងក្រុមដែលមានប្រុសស្រី លទ្ធផលអាចមិនសូវមាន ប្រសិទ្ធភាព ជាពិសេសកាលណាមានការសម្តែងតួ ការសម្តែងល្ខោន ឬការសរសេរ អត្ថបទអក្សរសាស្ត្រ។ នៅពេលបញ្ចូលភេទឱ្យលាយឡំគ្នា អ្នកត្រូវជម្រុញការងារ របស់ក្រុមឱ្យទៅមុខជានិច្ច។ ត្រូវចេះផ្តល់អាទិភាពដល់ការអប់រំរវាងភេទ និងភេទ នៅពេលធ្វើសកម្មភាពអនុវត្តកម្មវិធី ហើយត្រូវធានា ឬដឹងច្បាស់ថាយុវជនទាំង ឡាយ យល់ដឹងនូវទស្សនសមាសភាព និងគោរពរវាងបុរសនិងនារី រវាងក្មេងប្រុស និងក្មេងស្រី ភាពវ័យជំទង់គឺអន្តរកាលក្នុងជីវិតរបស់យុវជន ជាពិសេសក្នុងរឿង អ្វីដែលពាក់ព័ន្ធការទំនាក់ទំនងជាមួយនឹងភាពផ្សេងៗទៀត។ ចាប់តាំងពីកុមារភាព មកយុវជនទាំងឡាយទទួលនូវសារដែលមានន័យល្អិតល្អន់ស្តីអំពីតួនាទីហើយនិងឋានៈ របស់បុរស និងស្ត្រីនៅក្នុងសង្គម បុរស និងស្ត្រីដែលកែលំអអាកប្បកិរិយានិងឫកពារ របស់គេ។ វប្បធម៌ ប្រពៃណី អាកប្បកិរិយា ហើយនឹង ឫកពារ ដែលលេចធ្លោចាក់ ឫសយ៉ាងជ្រៅនៅក្នុងរចនាសម្ព័ន្ធ និងការអភិវឌ្ឍន៍របស់សង្គម។ ជាការសំខាន់រឿង ដែលត្រូវលើកទឹកចិត្តក្មេងស្រី និងក្មេងប្រុសក្នុងក្រុមរបស់អ្នកឱ្យពិភាក្សាអំពីអ្វីដែល ដូចគ្នា និងអំពីអ្វីដែលដូចគ្នាពាក់ព័ន្ធនិងការចូលរៀនរបស់ពួកគេនិងទទួលយកការងារ របស់ពួកគេ។ ការពិភាក្សានេះបង្ខំឱ្យយុវជនឱ្យសម្លឹងមើលខ្លួនឯងនៅក្នុងកញ្ចក់ ពោលគឺអ្វីដែលបង្កើតនូវដំណាក់កាលដំបូងនៃការប្រមូលកម្លាំងរបស់សង្គម។



មុនពេល ដែលយុវជនទទួលយកតួនាទីជាភ្នាក់ងារធ្វើឱ្យសង្គមប្រែប្រួល យុវជនត្រូវ តែដឹងនូវអ្វី ដែលពួកគេចង់ផ្លាស់ប្តូរ ហើយនិងរបៀបដែលពួកគេទុកដាក់ខ្លួនដោយ ប្រៀបធៀបទៅនឹងបញ្ហាមិនទុកចិត្តសង្គម។ រឿងនេះត្រូវបានអនុវត្តបានជោគជ័យ ដោយប្រើវិធី ល្អិតល្អន់ខ្លាំងណាស់ វិធីពង្រឹងការទុកចិត្តចំពោះខ្លួនឯង ហើយនិងការ ទុកចិត្តក្នុងក្រុម និងវិធីផ្តល់អាទិភាពឱ្យមានបរិយាកាសគ្មានការបង្ខិតបង្ខំបរិយាដែល មិនវិនិច្ឆ័យដល់ពួកគេ ក៏ប៉ុន្តែគាំទ្រពួកគេរហូតដល់ពេលដែលពួកគេមានការភ្ញាក់រលឹក និងមានការយល់ដឹង។

# ឈុតម៉ូឌុល

ទោះបីយើងសង្កត់អត្ថន័យទៅលើសេរីភាពរបស់អ្នកក្នុងការប្រើប្រាស់ម៉ូឌុលទាំងនេះដោយបញ្ចូលគ្នា និងធ្វើឱ្យស៊ីសង្វាក់គ្នា តាមបំណងរបស់អ្នកក៏ដោយមិនចាំបាច់ចុះលេខរៀងនោះ ក៏មានការណែនាំឱ្យអ្នកមានលទ្ធភាពអនុវត្តតាមលំដាប់ម៉ូឌុលទាំងនោះ។ ម៉ូឌុលទាំងឡាយនោះអាចត្រូវបានគេយកទៅអនុវត្តប្រកបដោយប្រសិទ្ធភាព។ យើងផ្តល់យោបល់ ខ្លះៗដែលពាក់ព័ន្ធទៅនឹងការផ្លាស់ប្តូរដែលអាចធ្វើទៅបាន។ សូមមេត្តាកតសម្គាល់ថា នេះគឺជាការផ្តល់យោបល់ដែលកើតចេញមកពីបទពិសោធន៍។ យើងមានការយល់ដឹងច្បាស់លាស់អំពីអ្វីដែលអាចមាននៅក្នុងបរិបទណាមួយនៅក្នុងស្ថានភាព ឬនៅក្នុងប្រទេសណាមួយ ក៏ប៉ុន្តែអ្វីៗទាំងនោះក៏មិនអាចមានដំណើរការដូចគ្នាក្នុងប្រទេសផ្សេងទៀតឡើយ ឬមិនមានដំណើរការទាល់តែសោះ។ ទោះបីយ៉ាងនោះក៏ដោយ ការផ្តល់យោបល់បន្ទាប់ពីនេះអាចឱ្យយល់ថាមានវិធីសាស្ត្រមួយសម្រាប់ប្រើប្រាស់ឈានទៅដល់ដំណាក់កាលបង្រៀនអំពីម៉ូឌុលទាំងនេះ។

ចូរអ្នកចោទសួរខ្លួនឯង អំពីទិសដៅដែលអ្នកចង់ធ្វើឱ្យបានសម្រេចដោយប្រើប្រាស់ម៉ូឌុលអស់ទាំងនេះ។ តើខ្លួនអ្នកនិងក្រុមរបស់អ្នកប្រាថ្នាចង់បានអ្វី? តើទិសដៅទាំងនេះនិងដើរតួដ៏មានន័យ ដើម្បីកំណត់យករបៀបអនុវត្តសៀវភៅទាំងនេះ។ ក៏ប៉ុន្តែមានភាពសមហេតុផលមួយ ដែលនាំឱ្យមានការប្រើប្រាស់ម៉ូឌុលនេះកាន់តែច្រើនឡើងៗ។ ម៉ូឌុលដែលមានចំណងជើងថា "ព័ត៌មានជាមូលដ្ឋាន" មានសារៈសំខាន់ខ្លាំងណាស់ក្នុងដំណាក់កាលទី១។ យុវជនទាំងឡាយត្រូវតែយល់សំណួរ ដែលពាក់ព័ន្ធទៅនឹងពលកម្មកុមារ មុននឹងចាប់ផ្តើមធ្វើសកម្មភាព។

ម្យ៉ាងទៀតមានការហាមមិនឱ្យប្រើម៉ូឌុលដែលមានចំណងជើងថា "ការសម្តែងល្ខោន" ដោយមិនបានប្រើប្រាស់ម៉ូឌុលដែលមានចំណងជើងថា "រូបភាព" ម៉ូឌុល "ការសម្តែងតួ" នោះឡើយ។ មុននឹងប្រើប្រាស់ និងផ្សព្វផ្សាយសៀវភៅទាំងនេះតាមប្រព័ន្ធក្រុមរបស់អ្នកគួរតែអនុវត្តជាមុននូវម៉ូឌុលដែលមានចំណងជើងថា "ការនិពន្ធរឿង" ហើយនិងម៉ូឌុល "ការស្រាវជ្រាវ និងព័ត៌មាន" សិន។ ម៉ូឌុលទាំងនេះប្រៀបបានទៅនឹងអាគារសង់ជាប់ៗគ្នា (Building blocks) ឬហៅថា "ឈុតម៉ូឌុល"។

វាមិនមែនជាគំនិតមួយដ៏ល្អទេ រឿងដែលតម្រូវឱ្យចាប់ផ្តើមការរៀនសូត្រដោយប្រើប្រាស់សៀវភៅពិបាកដូចជាសៀវភៅ "ការស្រាវជ្រាវនិងព័ត៌មាន" ជាដើមពីព្រោះវាអាចធ្វើឱ្យក្រុមអ្នកធុញទ្រាន់ចាប់ពីដើមដំបូងនេះទៅ។ សូមចាប់ផ្តើមរៀនសូត្រម៉ូឌុលដែលនាំឱ្យ

សប្បាយដូចជាម៉ូឌុល "ផ្ទាំងផ្ដុំរូបភាព" ជាដើមពីព្រោះវាអាចនាំយុវជនឱ្យចេះពិចារណាទៅលើពលកម្មកុមារ និងលើអ្វីដែលផ្ទាំងផ្ដុំរូបភាព បង្ហាញឱ្យឃើញដោយមិនចាំបាច់អានអក្សរឡើយ ។

ឧទាហរណ៍ខាងក្រោមនេះនឹងជួយអ្នកក្នុងការជ្រើសសៀវភៅសម្រាប់រៀន។ សៀវភៅទាំងនោះមានគោលដៅប្លែកៗគ្នាស្របទៅតាមបរិបទវប្បធម៌ ប្រពៃណីធនធានដែលមាន និងពេលវេលា។ យើងសូមបញ្ជាក់ថា អ្វីដែលយើងបាននិយាយខាងលើនេះ គឺជាការណែនាំតែប៉ុណ្ណោះ។ កាលណាយើងទទួលបានបទពិសោធន៍ច្រើន និងកាន់តែស៊ីជម្រៅ យើងនឹងកែលំអសៀវភៅ "ណែនាំអ្នកប្រើប្រាស់" នោះឱ្យកាន់តែស៊ីជម្រៅថែមទៀត។

យើងបង្ហាញនូវឧទាហរណ៍មួយចំនួន ស្ដីពីការផ្លាស់ម៉ូឌុល ដើម្បីអនុវត្តចាប់តាំងពីគោលដៅពិសេស ឬអ្វីដែលអ្នកកំពុងតែធ្វើឱ្យបានសម្រេចក្នុងពេលវេលាមួយកំណត់ ឬដោយប្រើប្រាស់ធនធានមានកំណត់។

**ផ្អែកតាមគោលដៅ**

## ១.ដើម្បីបង្កើតរឿងល្ខោន

**ព័ត៌មានជាមូលដ្ឋាន** : ត្រូវមានគំនិតមូលដ្ឋាននៃពលកម្មកុមារនៅពេលចាប់ផ្ដើមបញ្ហា។



**ផ្ទាំងផ្ដុំរូបភាព** : ដើម្បីធ្វើឱ្យមានការយល់ដឹងតាមការមើលឃើញនៅពលកម្មកុមារ ហើយនិងខ្វះការផ្សព្វផ្សាយនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ ហើយនិងដើម្បីដឹកនាំក្រុមឱ្យពិចារណាចំពោះបញ្ហា និងអត្ថន័យរបស់វា។

**ការស្រាវជ្រាវ និងព័ត៌មាន** : ដើម្បីគាំទ្រឱ្យធ្វើលំហាត់បង្កើតការយល់ដឹងពីគំនិតផ្ដួចផ្ដើម។

**រូបភាព** : ដើម្បីលើកកំពស់ការយល់ដឹងអំពីពលកម្មកុមារ យុវជនគូររូបរបស់កុមារពលកម្ម ហើយបង្កើតស្មារតីទទួលខុសត្រូវចំពោះពួកគេ។

**ការសម្ដែងតួ** : ដើម្បីត្រលប់ចូលមកក្នុងរឿងរបស់កុមារពលកម្ម។ ត្រូវមានការយល់ដឹងអំពីបញ្ហាពលកម្មកុមារ យុវជនទាំងឡាយត្រូវឈានទៅរកការសំដែងសិល្បៈល្ខោន។

**ការនិពន្ធរឿង** : សម្រាប់ជម្រុញថាមពលច្នៃប្រឌិត ហើយនិងការនឹកស្រមៃដែលបានភ្ញាក់រលឹក។ ជាបឋមយុវជនទាំងឡាយត្រូវសរសេរកំណាព្យ ឬប្រវត្តិ។ រួចមកយុវជនទាំងឡាយនាំគ្នាចាប់ផ្ដើមសរសេរអត្ថបទល្ខោន។

**ល្ខោន** : ត្រូវសរសេរហើយសម្ដែងរឿងល្ខោនស្ដីពីពលកម្មកុមារ បន្ទាប់ពីមានមូលដ្ឋានសំខាន់ៗក្រុមយុវជនត្រូវត្រៀម និងតម្លើងរៀបចំរឿងល្ខោនរបស់គេ។

**សមាហរណកម្មសហគមន៍** : មានគោលបំណងផ្តល់ឱ្យយុវជននូវលទ្ធភាពធ្វើសកម្មភាពបន្ត និងបញ្ជូនសាររបស់គេជូនដល់សហគមន៍។ ការងារនេះនឹងនាំឱ្យក្រុមយុវជនមានបទពិសោធន៍ដ៏មានប្រសិទ្ធភាព ដោយហេតុថាពួកគេដើរតួជាអ្នកអប់រំដោយខ្លួនឯងផ្ទាល់តែម្តង។

## ២-ដើម្បីអនុវត្តយុទ្ធនាការប្រព័ន្ធផ្សព្វផ្សាយ




**ព័ត៌មានជាមូលដ្ឋាន** : គឺជាគំនិតមូលដ្ឋានពាក់ព័ន្ធការងាររបស់កុមារដែលត្រូវចាត់ទុកជាការចាប់ផ្តើមបង្ហាញនូវបញ្ហា។

**ផ្ទាំងរូបភាព** : គឺជាមានគោលបំណងឱ្យកុមារយល់បានដោយងាយតាមការមើលឃើញនូវការងាររបស់ពួកគេ និងឃើញអ្វីដែលពួកគេមិនដែលបានឃើញតាមប្រព័ន្ធផ្សព្វផ្សាយ និងធ្វើឱ្យពួកគេពិចារណាចំពោះបញ្ហាថាតើបញ្ហាទាំងនេះមានន័យដូចម្តេច។

**ការស្រាវជ្រាវ និងព័ត៌មាន** : មានគោលបំណងឱ្យធ្វើលំហាត់បង្កើនការយល់ដឹងពីគំនិតផ្តួចផ្តើម។

**សម្ភាសន៍ និងអង្កេត** : មានគោលបំណងបង្កលក្ខណៈងាយស្រួលដល់យុវជនឱ្យមានទំលាប់ធ្វើបទសម្ភាសន៍តម្រង់ទិស និងវិភាគរាល់ការស្ទង់មតិទាំងឡាយ។ ជាក់ស្តែងការងារនេះ គឺជាការដាស់សតិសម្បជញ្ញៈឱ្យភ្ញាក់រលឹក។



**ការនិពន្ធរឿង** : មានគោលបំណងពង្រឹងសមត្ថកិច្ច និងបទពិសោធន៍អក្សរសាស្ត្រ ដែលសំខាន់សម្រាប់ធ្វើការទំនាក់ទំនងជាមួយប្រព័ន្ធផ្សព្វផ្សាយ។

**ការពិភាក្សា (ជម្រើស)** : មានគោលបំណងបង្ករលក្ខណៈងាយស្រួលដល់ការស្រាវជ្រាវ និងព័តិមានក៏ដូចជាងាយស្រួលដល់ការបង្កើតអត្ថបទអក្សរសាស្ត្រដែរ។ នេះគឺជាលំហាត់ដែលទាមទារឱ្យការចូលរួមពីប្រព័ន្ធផ្សព្វផ្សាយផងដែរ។ លំហាត់នេះនឹងជួយដល់យុវជនឱ្យចេះរបៀបធ្វើការពិភាក្សាលើប្រធានបទណាមួយដែលមានប្រយោជន៍ ដោយមានការចូលរួមផ្ទាល់ពីប្រព័ន្ធផ្សព្វផ្សាយ។

## ប្រព័ន្ធផ្សព្វផ្សាយ (សារព័ត៌មាន វិទ្យុ ទូរទស្សន៍)

មានគោលបំណងលើកតម្កើងយុទ្ធនាការដោយមានការចូលរួមផ្ទាល់ពីប្រព័ន្ធផ្សព្វផ្សាយដោយផ្អែកទៅលើមូលដ្ឋានព័តិមាន និងសមត្ថកិច្ចទទួលបាន ពីមេរៀនកន្លងមក។

## ៣-ដើម្បីសម្តែងសិល្បៈ

**ព័ត៌មានជាមូលដ្ឋាន** : គឺជាគំនិតដើមបង្អស់ដែលស្តែងចេញពីការងាររបស់កុមារ ហើយត្រូវបានចាត់ទុកជាការចាប់ផ្តើមបង្ហាញនូវបញ្ហាដំបូងបង្អស់។

**ផ្ទាំងផ្ទុំរូបភាព** : មានគោលបំណងបង្កលក្ខណៈឱ្យមានការយល់ដឹងអំពីការងាររបស់កុមារ តាមការមើលឃើញ និងយល់ដឹងអ្វីដែលគេពុំធ្លាប់មើលឃើញតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ព្រមទាំងដឹកនាំពួកគេឱ្យពិចារណាអំពីពលកម្មកុមារ និងឱ្យពួកគេចាប់ផ្តើមរៀនសម្តែងសិល្បៈផ្សារភ្ជាប់ទៅនឹងការងាររបស់កុមារ។

**ការស្រាវជ្រាវ និងព័ត៌មាន** : មានគោលបំណងពង្រឹងសតិសម្បជញ្ញៈ

**ការប្រកួតសិល្បៈ** : មានគោលបំណងជម្រុញឱ្យមានការបង្កើតទម្រង់សិល្បៈផ្សេងៗដែលពណ៌នាអំពីបញ្ហាការងាររបស់កុមារ ដូចជាផ្ទាំងគំនូរ រូបចម្លាក់ជាដើម ដើម្បីពង្រឹងការយល់ដឹង និងការប្រណាំងប្រជែងរវាងសហគមន៍។

**ផ្អែកតាមការកំណត់ពេលវេលា**



ការប្រើប្រាស់ពេលវេលា ដើម្បីអនុវត្តសៀវភៅទាំងនេះតែងតែផ្អែកទៅលើគោលដៅ និងការឯកភាពរបស់ក្រុម។ ជាឧទាហរណ៍ ប្រសិនបើនៅក្នុងសាលារៀនកម្មវិធីនេះត្រូវអនុវត្តមួយ ឬពីពេលក្នុងមួយសប្តាហ៍តែប៉ុណ្ណោះ។ ផ្ទុយទៅវិញ បើនៅក្នុងថ្នាក់អប់រំក្រៅប្រព័ន្ធគ្រូអាចប្រើពេលវេលាច្រើនដើម្បីអនុវត្តសៀវភៅ ស្ទើម ទាំងអស់នោះ។ គ្រូអាចប្រើពេលវេលា១សប្តាហ៍ ៣ខែ-៦ខែ ឬ ១ឆ្នាំ ក៏បាន។ ប៉ុន្តែយើងសូមឱ្យអស់លោកពិចារណាឱ្យបានល្អិតល្អន់អំពីការប្រើប្រាស់ពេលវេលាសម្រាប់បកស្រាយពន្យល់

**ផ្អែកតាមធនធាន**

សៀវភៅណាមួយ។ គ្រូអាចបន្ទាយ ឬ បំពេញពេលវេលាតាមការចាំបាច់នៃលំហាត់ ឬមេរៀន។

នៅពេលបង្កើតសៀវភៅទាំងនេះ IPEC ចាប់អារម្មណ៍ទៅលើភាពខុសគ្នារវាងប្រទេសនានាផ្នែកខាងធនធាន និងលទ្ធភាពចូលរៀន។ កម្មវិធីនេះអាចយកទៅអនុវត្តបានចំពោះអ្នកទាំងឡាយណាដែលចូលរៀននៅថ្នាក់អប់រំក្រៅប្រព័ន្ធ ឬនៅក្នុងសាលាក្នុងប្រព័ន្ធតែប៉ុណ្ណោះ។ ម្យ៉ាងទៀតសៀវភៅខ្លះអាចអនុវត្តបានដោយប្រើសម្ភារមានកំណត់។ យើងសង្ឃឹមថាគ្រូខ្លះអនុវត្តទៅតាមបរិបទពិភពលោកនឹងមានលទ្ធភាពអនុវត្តសៀវភៅខ្លះនៅក្នុងក៏រិត ឬវិធានការណាមួយកាលណាកម្មវិធី ស្គ្រីម នេះត្រូវបានអនុវត្តទូលំទូលាយជាងនេះពេលនោះយើងសង្ឃឹមថានឹងបានទទួលគំនិតបង្កើតសៀវភៅថ្មីថែមទៀតពិសេសសម្រាប់ស្ថានភាពនៃធនធានដែលនៅមានក៏រិតនៅឡើយ។ យើងសង្ឃឹម ថានឹងបង្កើនការសម្របសម្រួលកម្មវិធី ស្គ្រីម នេះទៅតាមការយល់ដឹងនៅពេលពិនិត្យឡើងវិញ ក្នុងពេលអនុវត្ត និងទៅឆ្លុះបញ្ចាំងហេតុការណ៍ដែលតម្រូវឱ្យធ្វើជាចាំបាច់។



## ម៉ូឌុលត្រូវការធនធានជាអប្បបរិមា

- ព័ត៌មានជាមូលដ្ឋាន
- ការនិពន្ធរឿង
- ការពិភាក្សា
- រូបភាព
- ការសម្តែងតួរ
- សមាហរណកម្មសហគមន៍

**កំណត់សម្គាល់ :** ម៉ូឌុលដែលមានចំណងជើងថាផ្ទាំងផ្គុំរូបភាព (Collage) អាចអនុវត្តបានដោយប្រើសម្ភាសន៍ ប៉ុន្តែម៉ូឌុលនេះ (មេរៀននេះ) ពិបាកបង្កើតខ្លាំងណាស់នៅក្នុងបរិបទខ្លះ។ ជាការសំខាន់គឺគ្រូត្រូវជ្រើសរើសយកមេរៀនណាដែលអាចសម្របសម្រួលបាន។ មានតែគ្រូទេដែលដឹងនូវអ្វីដែលគ្រូត្រូវធ្វើ។ សមាសភាពដែល

មានលក្ខណៈបន្តគ្នា មាននៅក្នុងកម្មវិធីទាំងមូលដែលកំណត់ក្នុងម៉ូឌុលទាំងអស់នេះដោយចាប់ផ្តើមពីការធ្វើឱ្យមានការភ្ញាក់អារម្មណ៍ យល់ដឹងសំដៅទៅរកបញ្ហាវិជ្ជមានចំពោះអ្វីដែលកំពុងកើតឡើង ក្នុងសង្គមរួចឈានទៅដល់ការបញ្ចេញសកម្មភាពជាក់ស្តែង។ ការជ្រើសរើសម៉ូឌុលយកទៅអនុវត្តត្រូវតែ ផ្សារភ្ជាប់ទៅនឹងលំដាប់នៃដំណើរការរបស់វាខាងលើនេះ។

## ការចាប់អារម្មណ៍របស់បុគ្គល និងក្រុម

ជាការសំខាន់គឺត្រូវផ្តល់ឱ្យកុមារនូវលទ្ធភាពសម្តែងគ្រប់បែបយ៉ាងក្នុងការអនុវត្តកម្មវិធី ស្រ្តីម ។ ការរំជួលចិត្តរបស់គេអាចត្រូវបានស្តែងចេញមកតាមរយៈសកម្មភាព តាមរយៈអក្សរសាស្ត្រ តាមរយៈសិល្បៈល្ខោន ប៉ុន្តែត្រូវប្រយ័ត្នចំពោះការប៉ះទង្គិចទៅលើបុគ្គលក៏ដូចជាទៅលើក្រុម។ របៀបសម្តែងមានច្រើនណាស់អ្នកអប់រំត្រូវរកឱ្យឃើញនូវរបៀបណាដែលងាយស្រួល ហើយសមស្របទៅតាមប្រពៃណី និងវប្បធម៌របស់មូលដ្ឋាន។ នៅពេលចាប់ផ្តើមអនុវត្តកម្មវិធីគ្រូគប្បីស្នើឱ្យសមាជិកនៃក្រុមមានសៀវភៅកំណត់ហេតុផ្ទាល់ខ្លួនមួយ សម្រាប់កត់ត្រានូវការពិភាក្សា និងវាយតម្លៃផលប៉ះពាល់នៃកម្មវិធីទៅលើយុវជនបានសេចក្តីថា យុវជន គ្រូ សហគមន៍បានយល់ដឹងអំពីកម្មវិធី ស្រ្តីម នេះដល់កំរិតណាហើយ។ នៅក្នុងសៀវភៅកំណត់ហេតុផ្ទាល់ខ្លួនរបស់គេយុវជនអាចកត់ត្រានូវការរំជួលចិត្ត ការចាប់អារម្មណ៍ និងការភ្ញាក់រំលឹកដោយសារខ្លឹមសារនៃប្រធានបទពិភាក្សា។ ពួកគេអាចកត់ត្រានូវអ្វីដែលគេពេញចិត្ត និងអ្វីដែលគេមិនពេញចិត្ត ឬអ្វីដែលបកស្រាយមិនគ្រប់គ្រាន់ ព្រមទាំងកត់ត្រាអ្វីដែលគេដក់ក្នុងអារម្មណ៍នៅពេលពួកគេបានចូលរួមចំពោះអ្វីដែលមានសារៈសំខាន់ខ្លាំង។

កំណត់ត្រាផ្ទាល់ខ្លួន



កំណត់ត្រាក្រុម

កំណត់ហេតុផ្ទាល់ខ្លួននឹងជួយយុវជនឱ្យចេះវាយតំលៃកម្មវិធីនៅពេលអនុវត្តចប់ និងបទពិសោធន៍ទទួលបាន ប្រសិនបើការវាយតម្លៃនោះ ត្រូវធ្វើក្នុងពេលខ្លីណាមួយ។ ប៉ុន្តែការលំបាកអាចមាន

ចំពោះបុគ្គលក្នុងការកត់ត្រា និងវាយតម្លៃអ្វីដែលកើតឡើងចាប់តាំងពីដើមដំបូងនៃគម្រោងរហូតដល់ចប់។ ក្នុងកាលៈទេសៈនេះកំណត់ហេតុ ផ្ទាល់ខ្លួនមានសារៈសំខាន់ណាស់។ ប៉ុន្តែគេមិនអាចបង្ខំអ្នកណាមួយឱ្យមានកំណត់ហេតុផ្ទាល់ខ្លួនឡើយ។ ត្រូវពិភាក្សាណែនាំឱ្យយុវជន យល់ដឹងនឹងទទួលយកគំនិតនេះដោយខ្លួនឯងយ៉ាងស្រួល គំនិតបង្កើតកំណត់ហេតុផ្ទាល់ខ្លួន ត្រូវបានគេអនុវត្តដោយផ្ទាល់ក្នុងករណីដែលមានសមាជិកតិចតួចនៃក្រុមមាន "សៀវភៅកំណត់ហេតុផ្ទាល់ខ្លួន" គំនិតនេះមានសារៈសំខាន់ណាស់នៅក្នុងករណីស្ថានភាពដែលកម្មវិធី អក្ខរកម្មជាប្រធានបទត្រូវយកចិត្តទុកដាក់។

យើងស្នើឱ្យមានកាសរសេរកំណត់ហេតុផ្ទាល់ខ្លួនរបស់ក្រុម ដែលត្រូវបានចាត់ទុកជាលំហាត់របស់ក្រុមនៅពេលបញ្ចប់សកម្មភាពរបស់ កម្មវិធីប្រចាំថ្ងៃ។ ប្រសិនបើការងារនេះត្រូវធ្វើឡើងក្នុងន័យជាលំហាត់របស់ក្រុម បុគ្គលជាច្រើននឹងចូលរួមសកម្មភាពនោះ។ ប្រសិនបើគេត្រៀមសរសេរកំណត់ហេតុនៅពេលចប់សកម្មភាពនីមួយៗ ការងារនេះត្រូវបានចាត់ទុកជាការចូលរួមការពិភាក្សាបញ្ចប់របស់សៀវភៅនីមួយៗ។ ត្រូវអនុវត្ត "ការកត់ត្រា កំណត់ហេតុផ្ទាល់ខ្លួន" ក្នុងន័យលំហាត់បំផុសគំនិតឱ្យផុលផុស។ នៅក្នុងកំហាត់នេះយុវជនត្រូវបានអញ្ជើញឱ្យចូលរួមសម្តែងនូវការចាប់អារម្មណ៍យោបល់ផ្ទាល់របស់ពួកគេទៅលើសៀវភៅនេះទៅលើសកម្មភាពរបស់គេ និង លំហាត់របស់ពួកគេ។ ត្រូវបង្កើតការផ្លាស់ប្តូរវេននៅក្នុងនោះសមាជិកម្នាក់ៗនៃក្រុមដើរតួជាអ្នករាយការណ៍នៃការប្រជុំបញ្ចេញគំនិត ជួនកាលមានអ្នកស្ម័គ្រចិត្តកត់ត្រាលទ្ធផលនៃការប្រជុំបញ្ចេញគំនិត។ ប្រសិនបើការងារខាងលើនេះមិនអាចធ្វើបានទេនោះអ្នកធ្វើជាអ្នករាយការណ៍តែម្តងក៏បាន។

ប៉ុន្តែចូរអ្នកកុំភ្លេចថាវត្តមានរបស់អ្នកអាចរំខានដល់ការបញ្ចេញគំនិតរបស់ពួកគេ។ ប្រសិនបើអ្នកយល់ឃើញថាករណីនេះអាចកើតឡើង។ អ្នកគប្បីស្នើឱ្យយុវជនរៀបការប្រជុំដោយខ្លួនគេឱ្យបានសម្រេច

ក្នុងរយៈពេលពី ៥-១៥ នាទី ប៉ុណ្ណោះ។ ការទុកចិត្តនេះអាចធ្វើឱ្យចំណងមិត្តភាពក្នុងក្រុមមានភាពរឹងប៉ឹងកាន់តែខ្លាំងឡើង។

ត្រូវលើកទឹកចិត្តឱ្យពួកគេ ឱ្យបើកចំហរគំនិតរបស់គេ កុំបិលាក់លៀម ហើយត្រូវស្មោះត្រង់នៅពេលប្រជុំ ហើយសូមឱ្យអ្នករាយការណ៍កត់ត្រាឱ្យអស់នូវអ្វីដែលត្រូវបានលើកឡើង ទោះបីខុសឬត្រូវក៏ដោយ។ ប៉ុន្តែចូរអ្នកពន្យល់ដល់ពួកគេនូវទស្សនៈដែលមានន័យ : “ការទិទៀនស្ថាបនា” ដោយធ្វើយ៉ាងណាឱ្យពួកគេបញ្ចេញនូវការមិនសប្បាយចិត្តចំពោះខ្លឹមសារនៃសៀវភៅដោយបង្ហាញនូវហេតុផលព្រមទាំងសំណើថ្មីមកជំនួសខ្លឹមសារនោះវិញ។

អង្គការ IPEC រីករាយនឹងទទួលរាល់ការពិចារណានិងយល់ឃើញរបស់ពួកគេ។

សូមឱ្យពួកយើងដឹងជានិច្ចនូវរាល់សកម្មភាពបន្តទៅមុខទៀត។ គឺបញ្ជាក់ត្រារាល់អារម្មណ៍យល់ដឹង របស់ក្រុមចំពោះគម្រោងគឺតម្រូវឱ្យបង្កើត “គំនូរនៅតាមជញ្ជាំង” វិធីសាស្ត្រនេះបំផុសឱ្យមានចម្លើយវិជ្ជមានខ្លាំងណាស់ពីសំណាក់យុវជនពីព្រោះ “គំនូរនៅតាមជញ្ជាំង” នាំឱ្យគំនិតផុសឡើងដោយគ្មានការបង្ខំឡើង។ ហើយរឿងនេះមានលក្ខណៈដូច “គំនិតស្ថាបនា” ដែលគេអួតសរសើរនៅក្នុងសៀវភៅរបស់កម្មវិធី ស្ក្រីម។ គំនិតខាងលើនេះតម្រូវឱ្យយើងបិទផ្ទាំងរូបភាពនៅលើជញ្ជាំងនៃបន្ទប់ដែលយើងធ្វើការក្នុងនោះជាមួយឈប់ធ្វើការ ដើម្បីកុំឱ្យវាខូច។



ជញ្ជាំងបិទរូប និងអក្សរ

ក្រដាសរូបភាពត្រូវមានទំហំធំ ហើយបិទឱ្យបានច្រើននៅលើជញ្ជាំង។ ក្រដាសរឹងជាប់ជាងក្រដាសស្តើងៗ។ បើមានលទ្ធភាពត្រូវស្វែងរកក្រដាសរឹងមានពណ៌យកទៅបិទលើជញ្ជាំងឱ្យជាប់ល្អតែម្តង។

ចូរអ្នកបិទក្រដាសរឹងដែលមានរូបភាពនៅពេលដំបូងបង្អស់ដែលអ្នកអនុវត្តសៀវភៅនេះជាមួយក្រុម។ ចូរពន្យល់ដល់ពួកគេឱ្យដឹងឈ្មោះរូបភាព និងពន្យល់ឱ្យដឹងថាហេតុអ្វីបានជាក្រុមត្រូវប្រើរូបភាពនេះ។ សូមស្នើដល់សមាជិកក្រុមដែលស្ទាត់ជំនាញឱ្យសរសេរ

ចំណាងជើងរបស់រូបភាព ហើយបិទវានៅលើក្រដាសសម្រាប់ជាមធ្យោបាយសម្តែងនូវអ្វីដែលគេយល់ដឹងក្នុងពេលអនុវត្តគម្រោង។

ត្រូវអនុញ្ញាតឱ្យពួកគេសរសេរ គូរូប បិទរូប និងអត្ថបទនៅលើជញ្ជាំង។ ក្រុមនឹងក្លាយទៅជាម្ចាស់ និងជាអ្នកទទួលខុសត្រូវថែរក្សាជញ្ជាំង។ ម្យ៉ាងទៀតគេអាចនិយាយថាពួកគេជាអ្នករ៉ាប់រងមិនឱ្យមានការខូចខាតរូបរាងរូបភាព និងជញ្ជាំងឡើយ។ ប្រសិនបើពួកគេមានគំនិតក្នុងពេលធ្វើលំហាត់ ឬក្នុងពេលសំឡឹងមើលរូបកុមារកំពុងធ្វើការ សូមអនុញ្ញាតពួកគេទៅសរសេរនៅលើជញ្ជាំងភ្លាមតែម្តង។ សូមអ្នករៀបចំឱ្យមានខ្មៅដៃ ឬខ្មៅដៃពណ៌នៅក្បែរជញ្ជាំងជានិច្ច។ ពួកគេអាចសរសេរ ពាក្យស្លោក ប្រធានបទ ពាក្យគន្លឹះ ឬឃ្លាប្រយោគនៅលើក្រដាសបិទជាប់លើជញ្ជាំង។ ពួកគេអាចបិទលើជញ្ជាំងរូបភាពក្មេងធ្វើការងារ រូបភាពអំពើហិង្សា រូបភាពល្អមើល ឬរូបភាពដែលធ្វើឱ្យមានការរំខានសៅហ្មង។ ពួកគេអាចគូរូបភាពតំណាងសាមគ្គីភាព ការភ័យខ្លាច ការឈឺចាប់ ឬស្នេហា។ ត្រូវលើកទឹកចិត្តពួកគេឱ្យអានកំណាព្យ អត្ថបទអក្សរសាស្ត្រ និងស្វែងរកអត្ថបទដកស្រង់សមស្របទៅនឹងប្រធានបទ។ ពួកគេអាចចម្លងយកទៅបិទលើជញ្ជាំង។ គេអាចសរសេរអត្ថបទកំណាព្យ ឬអត្ថបទសំរាយយកទៅបិទលើជញ្ជាំងផងដែរ។



ចូរអ្នកលើកទឹកចិត្តដល់ពួកគេឱ្យស្នើអ្នកចូលរួមឱ្យសរសេរអំពីអ្វីមួយនៅលើក្រដាសបិទលើជញ្ជាំង។

ប្រសិនបើតំណាងសហគមន៍ត្រូវបានអញ្ជើញឱ្យមកនិយាយទៅកាន់ក្រុមឱ្យមកសង្កេត ឬចូលរួមសកម្មភាពរបស់ពួកគេ ភ្ញៀវទាំងនោះអាចសរសេរអ្វី១នៅលើជញ្ជាំងនៅពេលចប់សម័យប្រជុំ។

អ្នកអាចសន្និដ្ឋានថា នៅពេលដំបូងក្រុមមិនសូវហ៊ានសរសេរនៅលើជញ្ជាំងឡើយ។ បន្ទាប់មកក្រោយពីបានរៀនមេរៀនខ្លះមកដូចជាការសរសេរអត្ថបទអក្សរសាស្ត្រជាដើម ពួកគេនឹងចេះសរសេរយ៉ាងងាយ ហើយសកម្មជាងមុនបន្តិច។ នៅពេលប្រជុំដំបូងរបស់អ្នក អ្នកត្រូវទាញអារម្មណ៍របស់ពួកគេឱ្យសំឡឹងមើលអ្វីដែលនៅលើជញ្ជាំង។ នៅពេលបញ្ចប់ការប្រជុំអ្នកត្រូវដឹកនាំក្រុមឱ្យសរសេរឱ្យពេញក្រដាសបិទលើជញ្ជាំង។ នៅពេលចប់គម្រោង

អ្នកត្រូវរក្សាឱ្យគង់វង្ស "រូបបិទលើជញ្ជាំងនោះ"។ រូបភាព ឬសំណេរទាំងនោះមានតម្លៃខ្លាំងណាស់ ព្រោះវាបញ្ជាក់ជាសក្ខីភាពនូវមូលហេតុរួមហើយ ដំណើរដ៏មានឥទ្ធិពលខ្លាំងរបស់ក្រុមយុវជន។ ក្រុម IPEC យើងខ្ញុំចង់មើលឃើញឧទាហរណ៍ជាក់ស្តែងនៅលើ "រូបភាពបិទលើជញ្ជាំង" របស់ប្រទេសទាំងអស់នៃពិភពលោក។ យើងចង់ឱ្យអ្នកថតយកគ្រប់ " រូបភាពបិទលើជញ្ជាំង" ជាផ្នែកៗ។ យើងអាចរៀបរូបភាពទាំងនោះឡើងវិញ អានអត្ថបទសំណេរសង្កេតមើលអ្វីដែលពួកយុវជនបានយល់ដឹងជាបទពិសោធន៍។

## សមាហរណកម្មសហគមន៍

ទោះបីសៀវភៅដែលមានចំណងជើងថា "សមាហរណកម្មសហគមន៍" មាននៅក្នុងកម្មវិធី ស្ក្រីម ក៏ដោយរឿងសំខាន់គឺ បញ្ហាត្រូវតែស្តែងចេញតាមរយៈសកម្មភាពអនុវត្តគម្រោងគ្រោងទុកក្នុងសៀវភៅនីមួយៗ។ ប្រសិនបើអ្នកប្រើសៀវភៅទាំងនេះសម្រាប់ការ "អប់រំក្នុងប្រព័ន្ធ" អ្នកត្រូវណែនាំគ្រូឱ្យបញ្ជ្រាបគម្រោងនោះទៅក្នុងមុខវិជ្ជាផ្សេងៗ។ ការបញ្ជ្រាបនេះនឹងធ្វើឱ្យយុវជនយល់បានច្រើនឡើងៗនូវអ្វីដែលពាក់ព័ន្ធទៅនឹងពលកម្មរបស់កុមារ។ មុខវិជ្ជាជាច្រើន អាចទទួលការបញ្ជ្រាបអំពីពលកម្មកុមារបានដូចជា ភូមិសាស្ត្រសេដ្ឋកិច្ច(ភាពក្រីក្រ ការអភិវឌ្ឍន៍ផលប៉ះពាល់នៃបំណុលនយោបាយកសិកម្ម) ការគ្រប់គ្រងសហគ្រាស (ច្បាប់ការងារ លក្ខខ័ណ្ឌការងារការដឹកនាំការងារ) សាសនា (អំពើល្អ អំពើអាក្រក់ ការគោរពសិទ្ធិមនុស្ស) ភាសា (អក្សរ សាស្ត្រ ការបង្កើតអក្សរសាស្ត្រ) ប្រវត្តិសាស្ត្រ (ការងាររបស់កុមារក្នុងអតីតកាល) វិទ្យាសាស្ត្រ (ជីវវិទ្យា អាហាររូបត្ថម)។ ការបញ្ចូលគ្រប់មុខវិជ្ជាទៅក្នុងគម្រោងនេះនឹងផ្តល់នូវធនធាន និងសម្ភារព្រមទាំងការគាំទ្ររួមពីសាលាយ៉ាងពិតប្រាកដ។

ការធ្វើបញ្ជ្រាបលើកដំបូងតម្រូវឱ្យធ្វើការវិភាគឱ្យបានល្អិតល្អន់នូវរាល់មុខវិជ្ជាដែលពាក់ព័ន្ធក្រុមរបស់អ្នក។ ត្រូវធ្វើវិភាគថាតើការ

បញ្ហាបនេះមានប្រយោជន៍ ឬអត់ចំពោះការងារកុមារ ។ ដំណាក់កាលបន្ទាប់មកទៀត តម្រូវឱ្យប្រាស្រ័យទាក់ទងផ្ទាល់ជាមួយនឹងទីចាត់ការរបស់សាលា (នាយក) ដើម្បីពិភាក្សារិះរកលទ្ធភាព បន្ទាប់មកតម្រូវឱ្យទាក់ទងគ្រូបង្រៀនម្នាក់ម្តងៗ ។ ប្រសិនបើការបញ្ហាបត្រូវអនុញ្ញាតដោយទីចាត់ការ និងគ្រូបង្រៀននោះ គម្រោងរបស់អ្នកមានកម្លាំង និងមានការគាំទ្រហើយ ។



ត្រូវរៀបចំការប្រជុំបំផុសគំនិតជាមួយអ្នករួមការងារនៅក្នុងសាលារបស់អ្នក ស្នើឱ្យពួកចូលរួមជួយបញ្ជ្រាបគម្រោងរបស់អ្នកទៅក្នុងការបង្រៀនរបស់អ្នករួមការងារ (គ្រូ) ទាំងនោះ ។ គ្រូខ្លះរីករាយនឹងរៀបចំផែនការបញ្ជ្រាបនោះឱ្យបានល្អ ។ គ្រូខ្លះមិន ចុះសម្រុងជាមួយអ្នក ចំពោះរឿងនេះ យើងមិនត្រូវធ្វើការបង្ខិតបង្ខំទេ ។ ប្រសិនបើបានធ្វើការបញ្ជ្រាបសព្វគ្រប់ហើយ យើងសូមឱ្យរៀបចំផែនការបញ្ជ្រាបឱ្យបានល្អ ដោយប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់ ។ ជាការឥតប្រយោជន៍ ប្រសិនបើអ្នកស្នើឱ្យគ្រូបង្រៀនមុខវិជ្ជា និយាយអំពីការគ្រប់គ្រងសហគ្រាស មុនពេលដែលយុវជនបានយល់ដឹងច្បាស់អំពីពលកម្មរបស់កុមារ ។

យើងសូមឱ្យអ្នករៀបចំផែនការប្រជុំគ្រូដែលចូលរួមអនុវត្តគម្រោងចាប់តាំងពីដើមទី ។ ត្រូវរៀបចំការប្រជុំឱ្យតាមពេលទំនេររបស់គ្រូទាំងអស់នោះ ព្រោះការងារនិងពេលវេលារបស់គាត់មានកំណត់ច្បាស់លាស់ ។

វារៈរបៀបនេះនៃការប្រជុំត្រូវរៀបចំឱ្យបានច្បាស់លាស់ ដើម្បីឱ្យការពិភាក្សាទទួលបានលទ្ធផលល្អ ។ ក្នុងឋានៈជាអ្នក

សហការ និងទទួលខុសត្រូវ ការប្រជុំនេះបង្កលក្ខណៈឱ្យអ្នកដឹងនូវការប្រព្រឹត្តទៅនៃប្រតិបត្តិការ ក៏ដូចជាផ្តល់ព័ត៌មានដល់អ្នករួមការងាររបស់អ្នក និងទីចាត់ការសាលា ស្តីពីការរីកចំរើនលទ្ធផលនៃការបង្រៀន ព្រមទាំងហេតុការណ៍នៅពេលខាងមុខ។ ប្រសិនបើអ្នកមានលទ្ធភាព អ្នកត្រូវបញ្ចូលធនធានមនុស្សនៅក្រៅសាលាថែមទៀត មនុស្សដែលមានសមត្ថកិច្ច និងបទពិសោធន៍នៅវិស័យណាមួយ ដូចជាល្ខោន អត្ថបទអក្សរ សាស្ត្រ សិល្បៈ គមនាគមន៍ ឬមនុស្សធ្វើការបំរើការប្រព័ន្ធផ្សព្វផ្សាយ។ កាលណាអ្នកយល់ឃើញថាជាការមានប្រយោជន៍ អ្នកត្រូវអញ្ជើញវាគ្មិន ឬមនុស្សដែលមានការចាប់អារម្មណ៍ឱ្យមកថ្លែងសុន្ទរកថាទៅកាន់ក្រុមរបស់អ្នក និងឱ្យសង្កេតមើលអ្វីដែលយុវជនកំពុងធ្វើ ព្រមទាំងឱ្យស្តាប់អ្វីដែលក្រុមនិយាយ។ ការងារនេះអាចផ្តល់ ព័ត៌មានទូលំទូលាយដល់សហគមន៍ដើម្បីឱ្យមនុស្សទាំងឡាយយល់ដឹងអ្វីដែលយើងកំពុងតែព្យាយាមធ្វើ ហើយ យើងអាចទទួលការចូលរួមវិភាគទាន ការគាំទ្រពីសហគមន៍។

នៅពេលដែលក្រុមបានបញ្ចប់សៀវភៅណាមួយយើងត្រូវធ្វើលទ្ធផលដល់គ្រូបង្រៀនផ្សេងទៀត ព្រមទាំងសហគមន៍ឱ្យបានទូលំទូលាយផងដែរ។ ក្នុងន័យខាងលើនេះ យើងគម្បីបិទផ្សាយព័ត៌មាននៅតាមសាលាឬកន្លែងសាធារណៈដើម្បីឱ្យសហគមន៍ជ្រួតជ្រាប។

## ការលើកកំពស់ និងការផ្សព្វផ្សាយ

ក្រុមអាចបង្ហាញនូវលទ្ធផលនៃសកម្មភាពស្រាវជ្រាវទៅលើពលកម្មកុមារ និងពណ៌នាគោលបំណងរបស់គម្រោង ដើម្បីផ្សព្វផ្សាយដល់ក្រុមកុមារពលកម្មផ្សេងទៀត។ ក្នុងលំដាប់ដែលសៀវភៅផ្សេង ត្រូវបានអនុវត្តបានសំរេចនោះ ក្រុមអាចត្រៀមការផ្លាស់ប្តូរដំណឹងនៅលើក្តារខៀនផ្សព្វផ្សាយ។ ការងារនេះធានាផលប្រយោជន៍របស់ ក្រុមក៏ដូចជារបស់សមាជិកក្រុមគ្រូបង្រៀននៅពេលដែលគេពិនិត្យឃើញការរីកចម្រើនស្តែងចេញពីគម្រោង។

ឧត្តមសិក្សានិងមជ្ឈដ្ឋានសិក្សា

ទៅអនុវត្តសៀវភៅដែលមានចំណងជើងថា "ប្រព័ន្ធផ្សព្វផ្សាយ" ក្រុមនឹងចេះដឹងអំពីរបៀបទាក់ទងនិងផ្តល់លទ្ធភាពការងារ តាមរយៈប្រព័ន្ធផ្សព្វផ្សាយគ្រប់ប្រភេទ។ សកម្មភាពនេះនឹងពង្រីងវិធីផ្សព្វផ្សាយដល់ទីឆ្ងាយ និងដល់សហគមន៍ ឱ្យកាន់តែទូលំទូលាយ។

កម្មវិធីស្រ្តីមត្រូវបានគេទទួលស្គាល់ដោយសារកម្មវិធីនេះត្រូវបានមើលឃើញថាមានជ្រួតជ្រាបដល់គ្រប់ស្រទាប់នៃសង្គម និងគ្រប់កំរិតនៃការអប់រំ។ សូមព្យាយាមបញ្ចូលទៅកម្មវិធីនេះ នូវនិស្សិតកំរិតទី៣ អ្នក ធ្វើការក្នុងរង្វង់អប់រំ ឬបញ្ញវ័ន្ត ដូចជាអ្នកនិពន្ធ អ្នកស្រាវជ្រាវ សាស្ត្រាចារ្យ គ្រូពេទ្យ ។ល។ ក្រុមខាងលើពិតជាជួយគាំទ្រគម្រោងនេះព្រមទាំងយុទ្ធនាការពិភពលោក ដើម្បី លុបបំបាត់ពលកម្មកុមារនេះមិនខានឡើយ។ ចូរអ្នកទាក់ទងផ្ទាល់រាល់សាកលវិទ្យាល័យ សាលាជាន់ខ្ពស់នៅតាមតំបន់ អ្នកប្រវត្តិសាស្ត្រ អ្នកនិពន្ធ ព្រោះអ្នកទាំងអស់នោះ អ្នកបើកច្រកថ្មីជូនលោកអ្នក។

និស្សិត និងសាស្ត្រាចារ្យផ្នែកសង្គមសាស្ត្រ អភិវឌ្ឍសង្គម សិទ្ធិមនុស្ស ទំនាក់ទំនងមហាជន ប្រព័ន្ធផ្សព្វ ផ្សាយសារព័ត៌មាន គរុកោសល្យ គឺជាមនុស្សដែលចាប់អារម្មណ៍ចំពោះគម្រោងរបស់អ្នក និងត្រៀមជួយអ្នក។ និស្សិត និងសាស្ត្រាចារ្យអាចនឹងធ្វើការជាមួយក្រុមរបស់អ្នក។

- ទំនាក់ទំនងជាមួយមហាជន : និស្សិតផ្នែកខាងការផ្សព្វផ្សាយ (medias) អាចផលិតឯកសារខ្លីៗ ដូចវីដេអូ ធ្វើយុទ្ធនាការតាមរយៈប្រព័ន្ធផ្សព្វផ្សាយក្នុងន័យបណ្តុះបណ្តាល។ ខ្លឹមសារនៃគម្រោងទាំងនោះត្រូវទុកឱ្យនិស្សិតជ្រើសរើស ដោយខ្លួនឯង។ ប្រសិនបើមានឱកាសក្រុមអ្នកអាចស្នើដល់និស្សិតទាំងនោះ ឱ្យយកប្រធានបទពលកម្មកុមារតែម្តងក៏បាន ហើយពួកគេប្រហែលជាអាចទទួលយកមិនខានឡើយ។ ការងាររបស់និស្សិតនឹងគាំទ្រការងាររបស់ពួកគេនឹងអាចផ្តល់ដល់ក្រុមរបស់អ្នកនូវឧបករណ៍ផ្សព្វផ្សាយដ៏មានឥទ្ធិពលខ្លាំង ដើម្បីឱ្យមានការចាប់អារម្មណ៍ខ្លាំងពីសហគមន៍។ ការងាររបស់ពួកនឹងដាស់ឱ្យ ភ្ញាក់រលឹកនូវសតិសម្បជញ្ញៈរបស់រាល់ស្ថាប័នអប់រំ ព្រមទាំងដាក់គ្រាប់ពូជបណ្តុះគំនិតក្នុងចំណោមបុគ្គលិកសិក្សាថែមទៀតផង ស្តីពីការលុបបំបាត់ពលកម្មរបស់កុមារនេះ។

■ សិក្សាសង្គម : ពាក្យច្រើននៃវិធីសិក្សាសង្គមតែងតែមានគម្រោងអនុវត្តផ្ទាល់នឹងកន្លែងតែម្តង។ ស្ថាប័នទាំងឡាយអាចមានលទ្ធភាពធ្វើការស្រាវជ្រាវ ស្តីពីបញ្ហាពលកម្មរបស់កុមារ ឬការធ្វើអាជីវកម្មលើកុមារតែម្តង។ ប្រសិនបើអ្នករស់នៅក្នុងប្រទេសដែលមានពលកម្មកុមារនិស្សិតអាចប្រើប្រាស់បទពិសោធន៍ ក្នុងការអនុវត្តជាក់ស្តែង ដើម្បីជួយអ្នកដោយដឹកនាំការអង្កេតស្រាវជ្រាវរកមូលហេតុដែលនាំឱ្យមានកុមារធ្វើការក្នុងរោងចក្រសហគ្រាសជាក់ស្តែង។ ម្យ៉ាងទៀតពួកគេអាចជួយអ្នកក្នុងការដាក់ឱ្យអនុវត្តសៀវភៅទាំងឡាយ ស្តីពីពលកម្មកុមារនៅក្នុងថ្នាក់រៀនរបស់គេ ឬនៅក្នុងកម្មវិធីអប់រំក្រៅសាលាទៀតផង។ នេះគឺជាឧទាហរណ៍ខ្លះក្នុងចំណោមឧទាហរណ៍ជាច្រើន។ ចូរអ្នករៀបចំការប្រជុំជាមួយប្រធានគ្រប់គ្រងមុខវិជ្ជាជាមួយសាកលវិទ្យាធិការ ឬនាយកសាលាជាន់ខ្ពស់ ដើម្បីឱ្យនិស្សិតជួយគាំទ្រគម្រោងរបស់អ្នក។

## សាមគ្គីភាពរវាងយុវជន បណ្តាញយុវជន និងសាលារៀន

កម្មវិធីស្រ្តីមគឺជាមូលដ្ឋានសម្រាប់ទ្រទ្រង់បណ្តាញសាមគ្គីភាពរបស់ក្រុមដែលមានប្រហាក់ប្រហែលគ្នា។ កម្មវិធីប្រភេទនេះគេឱ្យឈ្មោះថា "កុមារទៅកាន់កុមារ" ឬ "សាលាទៅកាន់សាលា" ប្រព័ន្ធទាក់ទងរបស់យុវជនមានសក្តានុពលរបស់វាដែលឱ្យយុវជនមានលទ្ធភាពបង្កើតចលនាពិភពលោកសម្រាប់ផ្សារភ្ជាប់វប្បធម៌ទៅនឹងសង្គម។



កាលណាអ្នកអប់រំណាមួយ បុគ្គលណាមួយ ឬអង្គការណាមួយនៅក្នុងពិភពលោកសម្រេចចិត្តអនុវត្តកម្មវិធីស្រ្តីមនេះយើងត្រូវផ្តល់យោបល់ថាមួយផ្នែកនៃការងាររបស់ក្រុមគឺតម្រូវឱ្យកសាងចំណងសាមគ្គីភាព ការទំនាក់ទំនងជាមួយនឹងមនុស្សផ្សេងទៀត ដែលបានចូលរួមក្នុងកម្មវិធី។

ចំណោងសាមគ្គីភាពនេះជម្រុញកម្មវិធី និងការងាររបស់ក្រុមគ្រប់បែបយ៉ាង។ ចំណោងសាមគ្គីភាពបង្កើតនូវគំនិតមនុស្សធមិដល់ក្រុមថែមទៀត។ ពួកយុវជនមានអារម្មណ៍ថាពួកគេមិនស្ថិតនៅ ឯកោឡើយក្នុងការងារដែលគេកំពុងធ្វើ។ ពួកគេស្ថិតនៅក្នុងផ្នែកមួយនៃប្រព័ន្ធពិភពលោកនៃយុវជនដែលធ្វើការរួមគ្នាការពារសិទ្ធិក៏ដូចជារួមចំណែកលុបបំបាត់ពលកម្មកុមារឱ្យអស់។ ពួកគេអាចទាក់ទងយុវជនផ្សេងទៀត ក្នុងពិភពលោកទាំងមូល ចែករម្លែកបទពិសោធន៍គ្នាទៅវិញទៅមក ស្រាវជ្រាវរកឃើញរបៀបដែលគេរៀនសូត្រពីសៀវភៅរឿងល្ខោន និងអត្ថបទអក្សរសាស្ត្រដែលពួកគេបានកសាងឡើងជួបគ្នាប្រាស្រ័យទាក់ទងគ្នា សួរសុខទុក្ខគ្នានៅពេលអនាគតដ៏ខ្លីខាងមុខនេះ។

គំនិតសាមគ្គីភាពមានកើតច្បាស់លាស់ណាស់។ ក្នុងរយៈពេលសាកល្បងកម្មវិធីនៅក្នុងសាធារណរដ្ឋអៀរឡង់ ក្រុមនិស្សិតរៀបចំការរៃអង្គាសមូលនិធិសម្រាប់ជួយដល់យុវជន និងកុមារនៅប្រទេសហ្សដានី (Jordanie) និងនៅប្រទេសណេប៉ាល់ (Nerpal) ដោយផ្ញើសម្ភារៈសិក្សាសម្រាប់អនុវត្តកម្មវិធី ស្ក្រីម នេះ។ នេះគឺកាយវិការសាមញ្ញ ក៏ប៉ុន្តែអាចបំបែករបាំងរារាំងការអភិវឌ្ឍន៍សង្គម និងសមាហរណកម្មពិភពលោក។ ចំណោងមិត្តភាពរវាងយុវជនក្នុងពិភពលោកអាចមានទម្រង់ផ្លែកពីគ្នា ហើយសង្ឃឹមថាគំនិតជាច្រើននឹងផុសចេញមកនៅពេលដែលកម្មវិធី ស្ក្រីម ត្រូវបានអនុវត្ត។ អ្នកនឹងទទួលបាននូវអាស័យដ្ឋានដែលយើងអាចប្រាស្រ័យទាក់ទងនៅពេលអនុវត្តចប់សៀវភៅដែលមានចំណងជើង "សេចក្តីណែនាំសម្រាប់អ្នកប្រើប្រាស់"នេះ។ លើសពីនេះទៅទៀតទម្រង់បែបបទចូលរួមអនុវត្តកម្មវិធី ស្ក្រីម យើងមានក្នុងផ្នែកឧបសម្ព័ន្ធសម្រាប់បំពេញរួចផ្ញើទៅ IPEC នៃក្រុង Geneve នៅពេលអ្នកបានបញ្ចប់ការងារនេះ។

ក្រោយពេលទទួលទម្រង់បែបបទនេះ IPEC នឹងធ្វើមកឱ្យអ្នកវិញនូវវិញ្ញាបនប័ត្រស្ក្រីមដើម្បីអរគុណដល់អ្នកអំពីរឿងដែលអ្នក និងយុវជននៃក្រុមរបស់អ្នកបានចូលរួមយុទ្ធនាការលុបបំបាត់ពលកម្មកុមារក្នុងពិភពលោក។ ប្រសិនបើអ្នកមិនផ្ញើរបាយការណ៍មកឱ្យយើងទេ យើងមិនដឹងថាអ្នកបាននឹងកំពុងចូលរួមយុទ្ធនាការនៅក្នុងប្រទេសណានិងនៅក្នុងស្ថានភាពដូចម្តេច?

# ការវាយតម្លៃ

ការដាក់សៀវភៅនេះឱ្យមានដំណើរការអនុវត្តអាចបង្កើតបាននូវរឿងរ៉ាវណាមួយ ដូច្នេះការពិចារណាយ៉ាងល្អិតល្អន់ក្នុងពេលដាក់សៀវភៅនេះឱ្យអនុវត្ត បង្ហាញឱ្យឃើញថាមានប្រយោជន៍ និងផ្តល់គំនិតស្ថាបនា ចំពោះអ្នកដូចជាចំពោះ IPEC ។ ដើម្បីឱ្យការវាយតម្លៃមានដំណើរការងាយស្រួល សូមមើលបែបបទអង្កេតនៅក្នុងចុងនៃសៀវភៅណែនាំនេះ ។

បន្ទាប់ពីអនុវត្តសៀវភៅនីមួយៗ ត្រូវពិចារណាឱ្យល្អិតល្អន់ចំពោះទិដ្ឋភាពដូចតទៅ ប្រសិនបើអ្នកធ្វើការវាយតម្លៃដោយខ្លួនឯងផ្ទាល់ទៅលើការប្រជុំរៀនសូត្រ ប្រសិនបើអ្នកធ្វើការម្នាក់ឯងគ្មាននរណាជាជំនួយ ។

## ការវាយតម្លៃរបស់អ្នកអប់រំ

- **ការរំជួលចិត្ត :** សមាជិកទាំងឡាយមានប្រតិកម្មដូចម្តេចខ្លះនៅពេលប្រជុំរៀនសូត្រ? តើអ្នកមានអារម្មណ៍ថាពួកគេបានយល់ច្បាស់នូវស្មារតី និងខ្លឹមសារក្នុងសៀវភៅនេះឬទេ? តើបានកត់សម្គាល់ឃើញមានអ្នកខ្លះដកខ្លួនឆ្ងាយពីក្រុមឬទេ? តើអ្នកប្រើវិធីអ្វីដើម្បីជំនះឧបសគ្គខាងលើ នេះនៅពេលអនុវត្តសៀវភៅផ្សេងបន្តទៅទៀត? ។
- **ការពាក់ព័ន្ធ:** តើយុវជនទាំងអស់ចាប់អារម្មណ៍យកចិត្តទុកដាក់ឬទេ នៅពេលប្រជុំរៀនសូត្រធ្វើលំហាត់នោះ? តើអ្នកមានអារម្មណ៍ថាអាចដឹកនាំការប្រជុំរៀនសូត្រដោយរបៀបផ្សេងៗគ្នាឬទេ? តើអ្នកប្រើវិធីណាដើម្បីលើកទឹកចិត្តនិងជម្រុញឱ្យមានទំនាក់ ទំនងត្រឹមត្រូវរវាងយុវជន? តើអ្នកបានដើរពីក្រុមមួយទៅក្រុម មួយដើម្បីនិយាយទៅកាន់ពួកគេនិងឱ្យដំបូន្មានដល់ពួកគេឬទេ? តើជំនួយពីក្រោយមានសារៈសំខាន់ឬទេ ក្នុងការអនុវត្តសៀវភៅនេះ (module)
- **ការប្តេជ្ញាចំពោះអនាគត :** តើអ្នកជឿថាយុវជននឹងបន្តការចូលរួមអនុវត្តសៀវភៅនេះ និងដំណើរការរបៀបនេះឬទេ?



តើអ្នកសង្ឃឹមថាពួកគេត្រៀមនឹងចូលរួមបន្តទៅទៀតឬទេ. តើអ្នកមានអារម្មណ៍ថាមានពួកគេមានគំនិតសមហេតុផល និងការប្តេជ្ញាចិត្តចំពោះការងារនេះឬទេ? តើគិតឃើញថាមពលរបស់ក្រុម ត្រូវបានពង្រឹងឬទេ? តើពួកគេបង្ហាញថាពួកគេមានចិត្ត ស្មោះត្រង់នៅពេលពួកគេមានប្រតិកម្មរវាងពួកគេ និងរវាងអ្នក?

តើពួកគេចូលរួមយ៉ាងចំហរអស់ពីចិត្តពីថ្លើមចំពោះអង្គប្រជុំឬទេ?

តើពួកគេនាំគ្នានិយាយយ៉ាងផុលផុសឬទេ? ។ អ្នកអាចកត់សម្គាល់ អ្នកដែលយកចិត្តទុកដាក់ និងអ្នកដែលមិនចាប់អារម្មណ៍ចំពោះអ្វីដែលអ្នកនិយាយឬទេ? តើអ្នកអាចនិយាយជាមួយអ្នកដែលសោះអង្គើយដូចម្តេច ដើម្បីកុំឱ្យបែកអារម្មណ៍ អ្នកដែលកំពុងតែមានគំនិតចូលរួម? តើអ្នកគប្បី និយាយរឿងដដែល ៗដែលធ្វើរួចហើយឬ? អ្នកត្រូវតែធ្វើដូច្នេះឬយ៉ាងណា? តើពួកគេត្រៀមនឹងចាប់ផ្តើមសៀវភៅថ្មីទៀតឬទេ?

- **ការអភិវឌ្ឍធនធានមនុស្ស :** អ្នកគិតថាត្រូវទាក់ទងមនុស្សដែលបង្ហាញខ្លួនថាគេមានការចាប់អារម្មណ៍ និងស្នើពួកគេធ្វើជាធនធានមនុស្ស ដើម្បីដឹកនាំសកម្មភាពរៀនសូត្រឱ្យបានទូលំទូលាយសម្រាប់សិល្បៈ ឬសម្រាប់កុមារជាច្រើនទៀតឬទេ?

ការពិចារណា និងសំណួរទាំងអស់ខាងលើនេះមិនមែនចប់អស់សេចក្តីទេ អ្នកត្រូវប្រមើលមើលដោយខ្លួនឯងថែមទៀត។ កំណត់ត្រារបស់អ្នករបាយការណ៍ និងការចាប់អារម្មណ៍ និង យោបល់អ្នកគឺជាការ សំខាន់សម្រាប់ការវាយតម្លៃនៅពេលចប់ការប្រជុំនីមួយៗ។

## ការវាយតម្លៃរបស់យុវជន

ផលប៉ះពាល់នៅពេលយូរខាងមុខនៃកម្មវិធី ស្រ្តីម ពិបាកវាយតម្លៃខ្លាំងណាស់ ពីព្រោះការងារនេះទាមទារការតាមដានជាប់លាប់បុគ្គលដែលចូលរួមអនុវត្តកម្មវិធី។ ក៏ប៉ុន្តែយើងសូមឱ្យអ្នកស្នើដល់សមាជិកក្រុមឱ្យវាយតម្លៃគម្រោងនិងសកម្មភាពនៅពេលចប់លំហាត់ដោយសរុប។ លើសពីនេះទៅទៀត យើងសូមឱ្យអ្នកស្នើដល់គ្រូ និងធនធានមនុស្សមកពីក្រៅឱ្យផ្តល់អ្នកនូវរាល់សេចក្តីអត្ថាធិប្បាយបកស្រាយទាំងអស់។

ចូរអ្នកធ្វើវិភាគលំហាត់វាយតម្លៃចាប់ពីពេលអ្នកមានលទ្ធភាព។ ការវិភាគនេះសម្រាប់ធ្វើជារបាយការណ៍សរុបនៃលំហាត់ទាំងមូល នៅពេលចប់គម្រោង។ ផ្អែកទៅលើមូលដ្ឋានខាងលើនេះ អ្នកអាចមានយោបល់ផ្ទាល់ខ្លួនរបស់អ្នក អំពីផលប្រយោជន៏របស់គម្រោង។ ចូរអ្នកកុំភ្លេចថា IPEC ចង់បានរបាយការណ៍វាយតម្លៃ និងការបកស្រាយរបស់បុគ្គលនីមួយៗ ។ ប្រតិកម្មនេះអាចចូលរួមការអភិវឌ្ឍន៏សៀវភៅនោះថ្មីទៀតក្រោយៗទៀត និងការវាយតម្លៃផលប៉ះពាល់នៅតំបន់ផ្សេងៗនៃពិភពលោក។

## ការយល់របស់អ្នក

នៅពេលចុងក្រោយបង្អស់ គឺការជ្រើសរើសផ្ទាល់របស់អ្នក ដែលជាការសំខាន់កំណត់នូវរបៀបដែលពួកអ្នកអនុវត្តសៀវភៅនេះ ព្រមទាំងផលចំណេញដែលអ្នកនិងក្រុមរបស់អ្នកទទួលយកបាន។ បំណងរបស់ IPEC គឺចង់ឱ្យគេប្រើប្រាស់សៀវភៅនេះឱ្យបានទូលំទូលាយ។ ភាពស្ថិតនៅយូររបស់កម្មវិធីនិងការអនុវត្តបន្តរបស់យុវជនអ្នកបណ្តុះបណ្តាលត្រូវផ្សារភ្ជាប់នឹងការអប់រំជាស្នូលក្នុងចំណោម យុវជន ឬកុមាររវាងប្រព័ន្ធជាតិ តំបន់ និងអន្តរជាតិ។ យើងសង្ឃឹមថាក្រុមយុវជននឹងប្រើប្រាស់ចំណេះដឹងអស់ទាំងនេះ និងបទពិសោធន៍បានល្អឥតខ្ចោះ។ ការអប់រំសម្រាប់កុមារ ឬយុវជនដូចជាគឺជាការបង្កើតផលប៉ះពាល់នៃការបង្រៀនរបស់គេឱ្យបានកាន់តែច្រើនឡើង។ យុវជនដែលត្រូវបានគេការពារនោះ នាំគ្នាពិភាក្សាអំពីអ្វីដែលគេកំពុងតែធ្វើជាមួយគូកនរបស់គេ គ្រួសាររបស់គេ ក៏ដូចជា ជាមួយមនុស្សនៅក្នុងសហគមន៍របស់គេ។ ផលប្រយោជន៍ដ៏សំខាន់និងទូលំទូលាយអាចកើតមានឡើងដោយសារការលើកទឹកចិត្តឱ្យយុវជននិយាយយ៉ាងចំហនិងដោយសេរី ស្តីពីអ្វីដែលពួកគេកំពុងធ្វើ។ លើកទឹកចិត្តឱ្យពួកគេឱ្យផ្តល់ព័ត៌មានឱ្យបានច្រើន។ ចូរបង្កើតសម័យប្រជុំរៀនសូត្រផ្សេងទៀត ហើយអញ្ជើញនិស្សិតចាស់ដែលធ្លាប់បានចូលរួមពីមុនឱ្យធ្វើជាធនធានមនុស្ស ហើយនិយាយអំពីបទពិសោធន៍របស់គេ និងដឹកនាំសម័យប្រជុំតាមវេនរបស់គេម្តង។

ចូរអ្នកចាត់តាំងយុវជនដែលបានសម្គាល់ថាមានសមត្ថភាពឱ្យមកជួយអ្នកចាប់តាំងពីដើមដំបូងនៃការរៀនតាមសាលាចំណេះទូទៅ។ កុមារឆ្លើយចំពោះកុមារដូចគ្នាដោយស្មោះអស់ពីដួងចិត្ត។ យុវជន មានសេចក្តីទុកចិត្តជាមួយយុវជនដូចគ្នាច្រើនជាមួយតំណាងអាជ្ញាធរ និងឪពុកម្តាយ។

រាល់ការធ្វើឱ្យសៀវភៅកាន់តែប្រសើរឡើងត្រូវបានស្វាគមន៍។

ជំពូកតទៅនេះបង្ហាញឱ្យឃើញច្បាស់នូវសារៈសំខាន់នៃប្រត្តិកម្មដែលមានបន្តបន្ទាប់ ដើម្បីជួយគាំទ្រដំណើរវាយតម្លៃនេះ។ ប៉ុន្តែយើងដឹងថាមនុស្សខ្លះ ឬអង្គការខ្លះដែលប្រើប្រាស់កម្មវិធី ស្ក្រីម បានសម្របសម្រួលសៀវភៅនេះឱ្យស្របតាមវប្បធមិប្រពៃណី ទំនៀមទំលាប់នៅតាមមូលដ្ឋានក្រុមមនុស្សខ្លះសម្រេចចិត្តបកប្រែសៀវភៅទាំងនេះជាភាសារបស់គេផ្ទាល់។ ទម្រង់នៃការអភិវឌ្ឍន៍នេះជាសញ្ញានៃការរីកចម្រើនក្នុងការធ្វើឱ្យបានសម្រេចកម្មវិធី ស្ក្រីម ព្រមទាំងត្រូវបានគេអបអរសាទរទទួលយ៉ាងរីករាយ។ អ្វីៗដែលយើងសួរទៅកាន់មនុស្សដែលចាប់ផ្តើមដំណើរការនេះគឺត្រូវផ្តល់ទៅឱ្យ IPEC ជាព័ត៌មាន ហើយត្រូវធ្វើជូនផងដែរនូវសៀវភៅបកប្រែ ឬសម្របសម្រួលនោះ។ ក្នុពិភពលោកប្រហែលជាមានក្រុមខ្លះទាញយកផលប្រយោជន៍ពីការងាររបស់អ្នក ហើយចង់ចែករម្លែកបទពិសោធន៍ឱ្យបានទូលំទូលាយក្នុងពិភពលោកតាម ដែលអាចធ្វើបាន។ ជាយោបល់ការដាក់ឱ្យអនុវត្តនូវវិធីសាស្ត្រគរុកោសល្យ គឺជាគន្លឹះនៃជ័យជំនះរបស់កម្មវិធី ស្ក្រីម ។ យើងជម្រុញឱ្យអ្នកអប់រំនៃពិភពលោក ឱ្យធ្វើការជាមួយនឹងកម្មវិធីនេះ។ ក្នុងបំណងបន្ថយតម្លៃបោះពុម្ពយើងអញ្ជើញ អ្នកអប់រំឱ្យធ្វើការថតចម្លងសៀវភៅអស់ទាំងនេះ រួចចែកដល់អ្នករួមការងារជាមួយគ្នា និងដល់អង្គការជាច្រើនឱ្យអស់លទ្ធភាព។ សៀវភៅក្បួនគរុកោសល្យត្រូវបានគេឯកភាពយល់ព្រមឱ្យចែកចាយ ដោយមិនយកលុយ ។ អ្នកអាចផ្តល់ព័ត៌មានដល់មនុស្សទាំងឡាយដែលចាប់អារម្មណ៍ថាសៀវភៅ ទាំងអស់អាចត្រូវបាន ផ្ញើដោយសេរីតាមរយៈគេហទំព័ររបស់ IPEC ។

## ផលត្រឡប់បន្តបន្ទាប់

យើងបានការធ្វើអត្ថាធិប្បាយបកស្រាយជាបន្តបន្ទាប់តាមលំដាប់ពេលវេលាដែលអ្នកធ្វើការជាមួយសៀវភៅទាំងអស់នេះ។ យើងប្រាថ្នាចង់ស្តាប់និស្សិតរបស់អ្នក ការពាររបស់អ្នក និងយុវជននៃក្រុមរបស់អ្នក។ សៀវភៅទាំងនេះគឺសារពាង្គកាយមួយរស់រវើក ហើយសៀវភៅនេះធ្វើឱ្យមានលក្ខណៈនិងខ្លឹមសារឱ្យហេតុការណ៍ ឬ ត្រូវបានពិនិត្យកែលំអឡើងជាប្រចាំទៅតាមពន្លឺបានមកពីប្រតិសកម្ម។ ការចូលរួមវិភាគរបស់អ្នកគឺជាគន្លឹះសំខាន់បំផុត និងជាមូលដ្ឋាននៃការគុណភាព និងភាពស្ថិតស្ថេររបស់សៀវភៅ។

យើងចង់ទទួលយក "ការសិក្សាករណី" ស្តីពីការអនុវត្តសៀវភៅអស់នេះ។ ប្រសិនបើអ្នកមានសម្ភារជារូបថត ឬជាវីដេអូ ស្តីពីវិធី ឬដំណើរការអនុវត្ត យើងដឹងគុណដល់អ្នក ប្រសិនបើអ្នកថតចម្លងរួចធ្វើមកឱ្យយើងខ្ញុំ។ វិធីអប់រំត្រូវមានលក្ខណៈជាត្រីភាគី គឺក្រុមយុវជននឹងរៀនសូត្រពីអ្នក អ្នករៀនសូត្រពីយុវជន និងពីពួកយើង យើងរៀនសូត្រពីយុវជន និងពីអ្នក។ ដូច្នេះសារៈសំខាន់នៃប្រតិសកម្ម និងគុណភាពនឹងស្តែងចេញពីវិធីអប់រំខាងលើនេះ ។ ជាឧទាហរណ៍យើងចង់ឃើញផ្សព្វផ្សាយតាមសារព័ត៌មាននូវលទ្ធផលអនុវត្តន៍សៀវភៅដែលមានចំណងជើងថា "សៀវភៅព័ត៌មាន" តូច១ ឬក្រុមធំ។ យើងចង់បានផងដែរនូវអត្ថបទថតចម្លងដែលបានចុះផ្សាយតាមសាព័ត៌មាន។ សូមកុំភ្លេចនិយាយលំអិតដូចជាអំពីប្រទេស តំបន់ដែលអ្នករស់នៅឈ្មោះរបស់កាសែតដែលបានចុះផ្សាយ ឬអត្ថបទកាត់ចេញពីសារព័ត៌មាន។ ម្យ៉ាងទៀតនៅពេលអ្នកបានបញ្ចប់កម្មវិធីស្រ្តីម យើងសូមឱ្យអស់លោកអ្នកមេត្តាបំពេញក្រដាសបែបបទភ្ជាប់មកក្នុងសៀវភៅស្រាប់។ ដោយឈរលើគោលការណ៍តាមបែបបទដែលបានទទួលរួចហើយនោះ IPEC នឹងផ្ញើវិញ្ញាបនប័ត្រមក ឱ្យអ្នកដើម្បីអរគុណអំពីការងារដែលអ្នកនិងក្រុមរបស់អ្នកបានទទួល ឬអំពីយុទ្ធនាការដែលអ្នកបានឧបត្ថម្ភគាំទ្រក្នុងបំណងកាត់ផ្តាច់ឬសគល់ពលកម្មរបស់កុមារ។

ប្រសិនបើដោយចៃដន្យ ក្រដាសបែបបទត្រូវបានយល់មិនច្បាស់នៅក្នុង ឬក៏សៀវភៅគរុកោសល្យត្រូវខូច អ្នកអាចទទួលបានអត្ថបទចម្លងនៅតាមគេហទំព័ររបស់ IPEC ដែលអាស័ដ្ឋានដូចតទៅ :

www.ilo.org/public/standards/ipec/indese.htm

សម្រាប់ IPEC មួយផ្នែកនៃព័ត៌មានតម្រូវឱ្យដឹងអំពីការប្រើប្រាស់ច្រើន ឬមិនសូវច្រើននូវសៀវភៅទាំងនេះ អ្នកណាខ្លះប្រើប្រាស់ដោយមូលហេតុអ្វី (អ្នកណាខ្លះមិនប្រើប្រាស់ព្រោះអ្វី) ផលប៉ះពាល់ទៅលើអ្នកអប់រំ និងយុវជន ជោគជ័យរបស់ពួកគេ បរាជ័យរបស់ពួកគេ និងការអភិវឌ្ឍន៍នៅពេលបន្ទាប់ ឬពេលក្រោយ ។ សូមអ្នកប្រាប់យើងឱ្យដឹងអ្វីដែលអ្នកយល់ឃើញអំពីរឿងខាងលើនេះ របៀបដែលអ្នកគិតឃើញថាត្រូវរៀបចំឱ្យកាន់តែប្រសើរថែមទៀត ។ សូមអ្នកធ្វើឱ្យពួកយើងនូវគំនិតថ្មីដែលត្រូវបញ្ចូលក្នុងកម្មវិធី ។ យើងណែនាំអ្នកទាំងអស់គ្នាឱ្យយល់និងធ្វើការបម្រើមូលហេតុរួមតែមួយគត់ ដើម្បីពង្រឹងសិទ្ធិកុមារ និងដើម្បីកាត់ផ្តាច់ឫសគល់ពលកម្មកុមារជារៀងរហូត ។ យើងអាចធ្វើបានរឿងនោះ ប៉ុន្តែវាទាមទារពេលវេលាកាលណាយើងរៀបចំកម្លាំងបានទូលំទូលាយ ហើយពេលនោះពលកម្មកុមារយើងអាចលុបបំបាត់ចោល ។

**ការប្រាស្រ័យទាក់ទង :** ដើម្បីដឹងព័ត៌មានបន្ថែម ស្តីពីកម្មវិធី ស្ក្រីម ចូរអ្នកទាក់ទងផ្ទាល់ IPEC តាមអាស័យដ្ឋានដូចតទៅ :

-កម្មវិធីអន្តរជាតិដើម្បីលុបបំបាត់ការងាររបស់កុមារ (IPEC)

-អង្គការអន្តរជាតិនៃការងារ (ILO)

- Route des Morillons CH.12 11 Geneva 22, switzerland

Telephone : +41 22 799 7747

Faze : +41 22 799 8181

Email : www.ilo.org/public/english/standards/ipec/indese.htm

## ទម្រង់បែបបទចូលរួម

ប្រសិនបើអ្នកបានធ្វើការជាមួយកម្មវិធីស្ក្រីម យើងសូមឱ្យអ្នកមេត្តាចំណាយពេលវេលាបន្តិច ដើម្បីបំពេញ "ទម្រង់បែបបទចូលរួម" ដែលដាក់ជូនបន្ទាប់មកនេះ ។ ក្រោយបានទទួលទម្រង់បែបបទដែលអ្នកបានបំពេញល្អរួចហើយ IPEC នឹងផ្ញើមកឱ្យអ្នកវិញនូវវិញ្ញាបនប័ត្រដែលបញ្ជាក់ថា អ្នកនឹងក្រុមរបស់អ្នកបានចូលរួមគាំទ្រយុទ្ធនាការបំបាត់ពលកម្មកុមារក្នុងពិភពលោក ។

ឈ្មោះពេញលេញ/ពណ៌នារបស់ក្រុម

ឈ្មោះពេញលេញនៃអង្គការ/ឈ្មោះអាគារសិក្សា

អាស័យដ្ឋានពេញលេញក្នុងនោះមានលេខទូរស័ព្ទ, ទូរសារចម្លង និងគេហទំព័រ

ឈ្មោះពេញលេញអ្នកដែលបំពេញទម្រង់បែបបទចូលរួម

មុខងារ/ការទទួលខុសត្រូវនៃអ្នកដែលបំពេញទម្រង់បែបបទ និងរបាការណ៍ របស់គាត់ និងក្រុមរបស់គាត់

កាលបរិច្ឆេទនៃគម្រោងរបស់អ្នក (ពីពេលចាប់ផ្តើមដល់ចប់)

ឈ្មោះ, ភេទ, អាយុរបស់យុវជនរាប់បញ្ចូលក្នុងគម្រោងរបស់អ្នក។ ប្រសិនបើជាការចាំបាច់ត្រូវប្រើសន្លឹកផ្សេងបន្ថែមទៀតដោយរបៀបណា អ្នកបានដឹងថាមានកម្មវិធី ស្ត្រីម ឈ្មោះថា "បញ្ឈប់ពលកម្មកុមារ"សៀវភៅណាខ្លះ អ្នកបានយកទៅអនុវត្តឱ្យមានដំណើរការ? ហេតុអ្វីបានជាអ្នកប្រើប្រាស់សៀវភៅនេះជាពិសេស? អ្នកបានរៀបចំគម្រោងបែបនេះជាមួយនឹងក្រុមយុវជនផ្សេងទៀត ដោយប្រើឈុតសៀវភៅគរុកោសល្យនៃកម្មវិធី ស្ត្រីម ឬទេ? សូមមេត្តាបញ្ជាក់ហេតុផលនៃចម្លើយ ទោះបីចម្លើយនោះយ៉ាងណាក៏ដោយ។

## ការអង្កេតវាយតម្លៃ

យើងដឹងគុណអ្នក ប្រសិនបើអ្នកអាចបំពេញការអង្កេតវាយតម្លៃនេះ ទោះបីអ្នកមិនទាន់មានវិធានការឆ្លើយចំពោះសំណួរទាំងអស់នេះក៏ដោយ យើងសូមឱ្យអ្នកឆ្លើយដោយរបៀបស្មោះត្រង់ ហើយលំអិតឱ្យបានល្អឱ្យអស់លទ្ធភាព។ អ្នកមិនត្រូវបានបង្ខំឱ្យឆ្លើយចំពោះសំណួរទាំងអស់ទេ បើអ្នកមិនមានករណីនេះ ឬប្រសិនបើរឿងនោះចំពោះអ្នកហាក់ដូចជាពិបាក។ ទោះបីអ្នកសម្រេចចិត្តយ៉ាងណាក៏ដោយ សូមព្យាយាមធ្វើចម្លើយរបស់អ្នក នៅពេលចប់ការអនុវត្តកម្មវិធី។ យើងសង្ឃឹមថាកម្មវិធី ស្ត្រីម នឹងមានសន្ទុះខ្លាំងដោយសារការអនុវត្តប្រកបដោយលក្ខណៈជាប្រព័ន្ធកាន់តែខ្លាំងឡើងៗ។ យើងនឹងទទួលបទពិសោធន៍របស់អ្នកដ៏បូទ្ធានមានពីអ្នក និងការកត់សម្គាល់ពីអ្នកដោយហេតុថាអ្វីៗទាំងអស់ជួយយើងក្នុងការញ៉ាំងកម្មវិធីឱ្យទាន់សភាពការបច្ចុប្បន្ន និង ការប្រសើរឡើងជានិច្ច និងជួយយើងក្នុងការកសាងសៀវភៅថ្មីៗទៀតក្នុងបំណងពង្រីកសកម្មភាពឱ្យបានទូលំទូលាយនៅតាមបរិបទសង្គម និងវប្បធម៌។ ប្រសិនបើចម្លើយរបស់អ្នកវែងពេក សូមកុំស្ទាក់ស្ទើរ សូមប្រើក្រដាសបន្ថែមទៀត។

គ្រប់ចម្លើយទាំងអស់ត្រូវបានសិក្សាបកស្រាយដោយរបៀបសម្ងាត់។ គោលដៅតែមួយគត់របស់យើងស្គាល់ឱ្យច្បាស់ អ្នកទាំងឡាយណាដែលប្រើ

ប្រាស់កម្មវិធីព្រមទាំងមូលហេតុ ដើម្បីបង្កើតមូលដ្ឋាននៃប្រធានបទ ស្តីពីក្រុមផ្សេងៗដែលធ្វើការជាមួយកម្មវិធី ស្រ្គីម ។ សហប្រតិបត្តិការរបស់អ្នកនឹងត្រូវបានស្វាគមន៍ ហើយគំនិត ការកត់សម្គាល់ និងការផ្តល់យោបល់ នឹងវាយតម្លៃយ៉ាងខ្ពស់ដោយអង្គការ IPEC/ILO អ្នកអាចពន្យល់ហេតុអ្វីបានជាអ្នក និងក្រុមរបស់អ្នកអនុវត្តកម្មវិធី ស្រ្គីម ? តើក្រុមរបស់អ្នកមានហេតុផលអ្វីខ្លះទៅដែលជម្រុញពួកគេឱ្យអនុវត្តកម្មវិធីនេះ?

អ្នកធ្វើការជាមួយក្រុមរបស់អ្នក ប៉ុន្មានម៉ោងក្នុងមួយសប្តាហ៍? យើងចង់ដឹងនូវកាលៈទេសៈទាំងមូល ឬស្ថានភាពពិសេសពាក់ព័ន្ធនឹងក្រុមរបស់អ្នក ប៉ុន្តែយើងដឹងថាអ្នកមិនចូលចិត្តបង្ហាញព័ត៌មានស្ងាត់កំបាំង ដោយសារចង់ការពារយុវជនដែលគ្រប់គ្រង។ ប៉ុន្តែបើអ្នកគិតឃើញថាប្រើឈ្មោះប្រឌិត ដើម្បីលាក់មុខពួកគេអាចស្ថិតនៅសន្តិសុខ។ ចូរអ្នកកុំស្ទាក់ស្ទើរក្នុងការពិចារណាថ្លឹងថ្លែងសំណួររបស់យើងខ្ញុំ។ រឿងខាងលើនេះនឹងជួយយើងក្នុងការងារស្រាវជ្រាវនិងវាយតម្លៃ។ មានទិដ្ឋភាពដែលធ្វើឱ្យយើងចាប់អារម្មណ៍ដូចជា : ក្មេងទាំងនោះជាជនពិការឬយ៉ាងណា? ពួកគេបានទទួលការរំលោភជិះជាន់ធ្វើអាជីវកម្មលើរូបកាយឬទេ? តើសមាជិកក្រុមកំពុងតែស្ថិតនៅក្នុងស្ថានភាពខាងលើនេះឬ? កុមារធ្វើការកន្លះពេលឬ? មានបញ្ហាកុមារពលកម្មឬទេ? តើអ្នកប្រឈមមុខនឹងបញ្ហានេះដូចម្តេច? អ្នកយល់ឃើញកម្មវិធី ស្រ្គីម បានការពារនិងជួយយុវជនទាំងនោះឬទេ? ចូរអ្នកពណ៌នារបៀបដែលអ្នកនិងក្រុមអ្នកបានបញ្ចូលតួសម្តែងផ្សេងទៀតទៅក្នុងសហគមន៍ ក្នុងនោះមានសាលារៀនដែលអ្នកធ្វើការជាដើម។ អ្នកបានបញ្ចូលដូចជាក្រុមត្រីភាគី បុគ្គលិកសិក្សាផ្សេងទៀត ក្រុមសមូសភាពមួយចំនួន...។ល។

អ្នកបានអំពាវនាវមនុស្សពីក្រោយឱ្យជួយក្នុងការអនុវត្តសៀវភៅទាំងនេះដូចជា អ្នកនិពន្ធ តួសម្តែងក្រុម សិល្បៈ ឬអ្នកសារព័ត៌មានឬទេ? តើសមូហភាព (ក្នុងនេះមានសាលារៀនជាដើម) បានដកស្រង់ផលកម្រៃពីគម្រោងនេះឬទេ? នៅពេលដែលត្រូវរៀបចំការបង្រៀនពិសេសផ្សារភ្ជាប់ទៅនឹងពលកម្មកុមារ តើព័ត៌មានដកស្រង់ចេញពីសៀវភៅទាំងអស់គ្រប់គ្រងសម្រាប់អ្នកឬទេ?

តាមយោបល់អ្នក តើមានចំណុចខ្លាំង និងចំណុចខ្សោយអ្វីខ្លះ នៅក្នុងសៀវភៅទាំងអស់នេះ? សូមអ្នកបរិយាយ។ តើធនធានព័ត៌មាន ឬហិរញ្ញវត្ថុជាកត្តាសម្រាប់អនុវត្តសៀវភៅទាំងនេះឬ? តើត្រូវអនុវត្តតាមវិធីណា? តើអ្នកសន្និដ្ឋានថាគម្រោងទាំងនេះមាននៅក្នុងប្រព័ន្ធអប់រំឬទេ? អ្នកឧបត្ថម្ភគាំទ្រយុទ្ធនាការប្រភេទនេះឬទេ? សូមពន្យល់ប្រាប់ហេតុផលនៃចម្លើយរបស់អ្នក ទោះបីចម្លើយនោះមានទម្រង់ និងអត្ថន័យបែបណាក៏ដោយអ្នកគិតឃើញថា យុវជនបានទាញយលផលប្រយោជន៍ពីគម្រោងទៅតាមការចេះដឹងរីកបំព្រង របស់គេ និងរបស់សង្គមឬទេ? សូមឆ្លើយដោយលំអិតក្បោះក្បាយ។ តាមយោបល់អ្នក តើអាកប្បកិរិយា និងការសិក្សារបស់គេមានការប្រែប្រួលឬទេ? ដោយរបៀបណា? គំនិតច្នៃប្រឌិតបែបណាខ្លះ ក្រុមយុវជនបានទទួលយកនៅពេលអនុវត្តគម្រោង? សៀវភៅណាខ្លះដែលយុវជនចាប់អារម្មណ៍ឱ្យតម្លៃខ្លាំង? សៀវភៅខ្លះដែលយុវជនមិនសូវចាប់អារម្មណ៍? ចូរអ្នកបង្ហាញឱ្យឃើញនូវភាពសមហេតុផលដែលធ្វើឱ្យយុវជនពេញចិត្ត? មិនសប្បាយចិត្ត?

ប្រសិនបើអ្នកសម្រេចចិត្តអនុវត្តកម្មវិធីនេះសារជាថ្មី តើអ្នកនឹងផ្លាស់ប្តូរ អ្វីខ្លះ? ព្រោះអ្វី?

តើអ្នកបានស្នើរដល់ក្រុមរបស់អ្នកឱ្យវាយតម្លៃបទពិសោធន៍ទទួលបានពីកម្មវិធីឬទេ? តើមានចម្លើយយ៉ាងណាខ្លះ? អរគុណចំពោះការធ្វើរបាយការណ៍វាយតម្លៃ និងចម្លើយរបស់បុគ្គលនីមួយៗ។

សូមមេត្តាផ្ញើមកឱ្យយើងខ្ញុំនូវសម្ភារស្តែងចេញពីការងាររបស់ក្រុមអ្នក ដែលអាចជួយដល់ការវាយតម្លៃជាបន្តបន្ទាប់។ ឧទាហរណ៍ ដូចជា : សេចក្តីថ្លែងការសាព័ត៌មាន អត្ថបទស្តីពីប្រព័ន្ធផ្សព្វផ្សាយ កាសែតថត បទសំភាសន៍ អត្ថបទថតចម្លងពីសារពតិមាន។ល។

តើយុវជន និងក្រុមអ្នក ការធ្វើការកត់សម្គាល់ បញ្ចេញគំនិត ឬសំណើរសុំឱ្យមានការកែលំអឱ្យបានកាន់តែប្រសើរឡើងនូវកម្មវិធី ស្រ្តីម បញ្ឈប់កុំឱ្យមានពលកម្មកុមារឬ? ជាឧទាហរណ៍ដូចជាគំនិតសម្រាប់កសាងសៀវភៅថ្មី សំណើឱ្យកែលំអ និងសម្របសម្រួលសៀវភៅទៅតាមលក្ខណៈឬ បរិបទពិសេសៗ។

តើអ្នកនិងក្រុមរបស់អ្នកអាចជួយ IPEC ក្នុងផ្សព្វផ្សាយកម្មវិធី ស្ក្រីមឬទេ? ចូរអ្នកប្រាប់យើងខ្ញុំអំពីរបៀបដែលពួកយើងជួយអ្នក និងអំពីរបៀបដែលអ្នកជួយយើង។

ចូរអ្នកប្រើចន្លោះក្រដាសខាងលើ ដើម្បីសរសេរផ្តល់មកឱ្យយើងនូវការកត់សម្គាល់របស់អ្នកដែលពាក់ព័ន្ធនឹងសម្ភារអប់រំទស្សនៈ ការអភិវឌ្ឍន៍នៅពេលអនាគត និងបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នក ។ល។

## គណៈកម្មការដឹកនាំ និងគ្រប់គ្រង

| | |
|---|---|
| ១_លោក ភុង ហនស៊ីន | ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ២_លោក តូច ជឿន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣_លោក គួច គូលំអ | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៤_លោក ចាប គឹមជុន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៥_លោក ណុប ទឹម | ជំនួយការនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |

## គណៈកម្មការរៀបរៀង និងចងក្រង

| | |
|---|---|
| ១_លោក ភុង ហនស៊ីន | ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ២_លោក តូច ជឿន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣_លោក គួច គូលំអ | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៤_លោក ចាប គឹមជុន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៥_លោក ណុប ទឹម | ជំនួយការនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៦_លោក ឡូង់ សុផាត | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |

## គណៈកម្មការបកប្រែ

| | | | |
|---|---|---|---|
| ១_លោកស្រី កង សុថាវី | ប្រធានការិយាល័យក្រោយអក្ខរកម្ម | ២_លោកស្រី តុប ប៊ុនថា | ប្រធានការិយាល័យអក្ខរកម្ម |
| ៣_លោក ពៀម ភីណារ៉េត | អនុប្រធានការិយាល័យរដ្ឋបាល | ៤_លោក តេះ ដារី | អនុប្រធានការិ.ផែនការនិងគ្រប់គ្រងទិន្នន័យ |
| ៥_លោក ជិន និវត្តន៍ | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៦_លោកស្រី ទី វត្តី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៧_លោក ភូ យន់ | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៨_លោកស្រី ស៊្រុន ម៉ាទី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៩_កញ្ញា អ៊ុក ធារី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ១០_លោក គ្រួច លក្ខិណា | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ១១_លោកស្រី លី ខេង | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | | |

## គណៈកម្មការផ្ទៀងផ្ទាត់

| | | | |
|---|---|---|---|
| ១_លោក សំ ចាន់ទិត | អនុប្រធានការិយាល័យអក្ខរកម្ម | ២_លោក រង់ សូវង្ស | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣_លោក ឈុំ ច័ន្ទមុនីរ៉េត | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៤_លោកស្រី ជា សុផល | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៥_លោក កែវ គង់ | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៦_កញ្ញា ម៉ៅ ផល្លី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៧_លោកស្រី ស៊្រុន ម៉ាទី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | | |

## គណៈកម្មការឌីហ្សាញ និងកុំព្យូទ័រ

| | |
|---|---|
| ១_លោក ឈិន វិត | ប្រធានការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ២_លោក ពេជ្រ និពន្ធ | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៣_លោកស្រី ឈុំ សោភ័ណ | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៤_លោកស្រី សួច ផាន់ណា | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៥_លោកស្រី ទី វ៉ាដា | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៦_កញ្ញា សន សុម៉ាលី | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |

# បញ្ឈប់ពលកម្មកុមារ

## Stop Child Labour

**Supporting Children's Rights through Education, the Arts and the Media (SCREAM)**


### សូមថ្លែងអំណរគុណ

- ដល់អង្គការពលកម្មអន្តរជាតិ (ILO) ដែលបានជួយឧបត្ថម្ភថវិកា ក្នុងការបកប្រែ រៀបរៀង និងបោះពុម្ព។
- ចំពោះលោក **មេនណាឌី ប៉ូល យ៉ូសេហ្វ** ប្រធានទីប្រឹក្សាបច្ចេកទេស និងលោក **ថេង ឆវីរិទ្ធ** មន្ត្រីកម្មវិធីនៃ *អង្គការពលកម្មអន្តរជាតិ* (ILO) កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ (IPEC) គាំទ្រកម្មវិធីពេលវេលាកំណត់(TBP SP) នៅកម្ពុជាដែលបានជួយផ្តល់ការណែនាំផ្សេងៗ និងការគាំទ្របច្ចេកទេស ព្រមទាំងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងនេះ ដើម្បី **ស្គ្រីម** (SCREAM) កើតមានឡើងនៅកម្ពុជា។

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពីក្រសួងអប់រំ យុវជន និងកីឡា តាមសេចក្តីប្រកាស
លេខ 101 អយក ប្រក ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៦



នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ : លេខ ១៦៨ មហាវិថីព្រះនរោត្តម សង្កាត់បឹងកេងកង១
ខណ្ឌ ចំការមន រាជធានីភ្នំពេញ

**ទូរស័ព្ទលេខ** **: (០២៣ ៧២៦ ៥៦៣ / ២១៩ ២៥៨**

**Email** **: nfe@camnet.com.kh**



ISBN-9789995088217

9 789995 088217